# មានមនុស្សទើបមានសេដ្ឋកិច្ច

## ការវិវត្តភពផែនដី ជីវិត និងរចនាសម្ព័ន្ធ សង្គមសេដ្ឋកិច្ចមនុស្សជាតិ

# NO HUMAN BEING, NO ECONOMY

## Evolution of the Earth, Life and Socio-Economic Sructure of Humanity




**ហ៊ីង ថូរ៉ាក់ស៊ី**

**HING THORAXY**



**Phnom Penh**
**2024**

# មានមនុស្សទើបមានសេដ្ឋកិច្ច

## ការវិវត្តភពផែនដី ជីវិត និងរចនាសម្ព័ន្ធ
## សង្គមសេដ្ឋកិច្ចមនុស្សជាតិ

# NO HUMAN BEING, NO ECONOMY

## Evolution of the Earth, Life
## and Socio-Economic Sructure of Humanity


បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី

**HING THORAXY, Academician**



**Phnom Penh**
**2024**

# អារម្ភកថា

បច្ចុប្បន្ន នៅលើផែនដីយើងនេះ មនុស្សលោករស់នៅហាក់មិនសូវជាចាប់អារម្មណ៍ អំពីអតីតនិងអនាគតនៃផែនដីរបស់ខ្លួនទេ។ គេគិតតែពីបញ្ហាជីវភាព ការរស់នៅប្រចាំថ្ងៃ ប្រទេសនីមួយៗគេគិតពីបញ្ហាក្នុងប្រទេស និងបញ្ហាអន្តរជាតិដែលពាក់ព័ន្ធនឹងប្រទេសរៀងៗខ្លួន។ មូលហេតុដោយសារថា នេះគឺជារយៈពេលដ៏វែងឆ្ងាយពេក ហួសពីកម្មវិធីសម្រាប់គ្រោងទុក ដើម្បីធ្វើផែនការឬគោលនយោបាយ។

ធម្មជាតិ ជាភាវៈកើតឡើងដោយឯកឯង គ្មានដើម និងគ្មានចុង។ មនុស្ស ជាផ្នែកតូចមួយនៃធម្មជាតិនៃចក្រវាល។ នៅក្នុងអត្ថិភាពរបស់ខ្លួន មនុស្សបានបង្កើតនូវអ្វីៗជាច្រើនសម្រាប់ខ្លួនឯង សម្រាប់សហគមន៍ដែលខ្លួនរស់នៅ។ មានមនុស្ស ទើបមានប្រវត្តិសាស្ត្រ របស់មនុស្ស ទើបមានសេដ្ឋកិច្ច នយោបាយ សាសនា ។ល។

សម្រាប់ការកកើតនិងការរលាយទៅវិញរបស់មនុស្សជាតិ ផ្នែកសាសនា បានយកបញ្ហាទាំងនេះមកគិត និងបានប្រមើលពីបញ្ហាអនាគតនៃមនុស្ស នៃផែនដីនេះ។ ប៉ុន្តែ មេសាសនាធំៗ កាលពីជំនាន់បុរាណមិនអាចនឹងគិតដល់ឱ្យបានប្រាកដដោយសារថា វិទ្យាសាស្ត្រ បច្ចេកវិទ្យា កាលនោះ មិនទាន់មានការរីកចម្រើននៅឡើយ ហើយក៏គ្មានសក្ខីកម្មជាមូលដ្ឋានវិទ្យាសាស្ត្រយកមកបង្ហាញ។ ដូច្នេះ ទោះបីជាពួកលោកមានប្រាជ្ញាខ្លាំងយ៉ាងណាក៏ដោយ ក៏ពួកលោកមិនមានមូលដ្ឋានវិទ្យាសាស្ត្រច្បាស់លាស់ ដើម្បីគិតពិចារណា ដូច្នេះលោកបានត្រឹមតែទស្សន៍ទាយ ប្រមើលមើលអំពីអនាគតនៃពិភពលោក ទៅតាមការយល់ឃើញផ្ទាល់ខ្លួនប៉ុណ្ណោះ។ ដូចជា នៅក្នុងព្រះពុទ្ធសាសនាជាដើម គេបានទស្ស

ន៍ទាយថា នៅក្រោយសម័យព្រះសិអាមេត្រី នឹងមានភ្លើងឆេះកល្ប ធាតុអាកាសក្តៅខ្លាំងណាស់ សុទ្ធតែភ្លើង ធ្វើឱ្យហួតទឹកទន្លេ បឹងបួរ សមុទ្រ ធ្វើឱ្យមនុស្សលោក សត្វ ស្លាប់អស់ រលាយព្រៃឈើ ។ល។ ទាល់តែរាប់សែនកប្ប រាប់អសង្ខេយ្យ ទើបមានផែនដីថ្មីកើតឡើង ជីវិតថ្មីកើតវិញមានឡើងម្តងទៀត។ ខាងគ្រិស្តសាសនាក៏មានការទស្សន៍ទាយអំពីការរលាយនៃភពផែនដីដែរ។

សំណេរនេះចងក្រងឡើង ដើម្បីពិនិត្យមើលជារួមឡើងវិញ អំពីប្រវត្តិមនុស្ស ប្រវត្តិភពផែនដី និងព្រះអាទិត្យ តើចេញពីណា ហើយចុងក្រោយបញ្ចប់នៅកន្លែងណា។

នេះជាសក្ខីកម្មដើម្បីបង្ហាញថា មនុស្សនាំគ្នាឈ្លោះដណ្តើមគ្នាច្បាំងគ្នា ដែលនេះជាលក្ខណៈធម្មជាតិរបស់មនុស្ស ហើយចុងក្រោយទៅគឺគ្មានបានយកអ្វីសោះទៅជាមួយ សូម្បីតែព្រលឹងវិញ្ញាណ។

ដូច្នេះ សន្តិភាព សុខដុមភាព ការរស់នៅស្រុះស្រួលជាមួយគ្នា ការចែកគ្នារស់ ជាភារៈសំខាន់សម្រាប់មនុស្សជាតិ។ គ្មានអ្វីសំខាន់ជាងសន្តិភាពទេ។

ថ្ងៃ ចន្ទ ទី ៥ រោច ខែ មិគសិរ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

ភ្នំពេញ ថ្ងៃទី ១ ខែមករា ឆ្នាំ២០២៤

**បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី**

**បណ្ឌិតវិទ្យាសាស្ត្រសេដ្ឋកិច្ច**

# មាតិកា

| ជំពូក | ទំព័រ |
|---|---|
| អារម្ភកថា | ៣ |
| ១- ប្រវត្តិកកើតចក្រវាលនិងប្រព័ន្ធព្រះអាទិត្យ | ៧ |
| ២- ប្រវត្តិកកើតជីវិតលើភពផែនដី | ២៦ |
| ៣- ប្រវត្តិកកើតមនុស្សលើភពផែនដី | ៣៦ |
| ៤- ការកកើតរដ្ឋបុរេបុព្វកាល | ៤៨ |
| ៥- អាណាចក្រធំនិងជម្លោះដណ្ដើមអំណាច | ៥៥ |
| ៦- ការវិវត្តនិងការបម្លាស់ទីរបស់មនុស្ស | ៧៦ |
| ៧- មានមនុស្សទើបមានសេដ្ឋកិច្ច | ៨៧ |
| ៨- បញ្ហាជម្លោះដណ្ដើមអំណាចសម័យថ្មី | ១០៣ |
| ៩- បដិវត្តន៍ឧស្សាហកម្មសតវត្សរ៍ទី១៨ និងទី១៩ | ១១៥ |
| ១០- ការវិវត្តសង្គមកម្ពុជា | ១២២ |
| ១១-អនាគតនៃប្រទេសក្នុងតំបន់និងក្នុងពិភពលោក | ១៣៣ |
| ១២- និយមន័យជីវិតនៅលើផែនដី | ១៤០ |
| ១៣- អវសានជីវិតក្នុងប្រព័ន្ធព្រះអាទិត្យ | ១៤៦ |
| សេចក្ដីសន្និដ្ឋាន | ១៦២ |

# ជំពូកទី១
# ប្រវត្តិកកើតចក្រវាលនិងប្រព័ន្ធព្រះអាទិត្យ

## បុព្វកថា

ជាទូទៅ មនុស្សមិនសូវបានយកចិត្តទុកដាក់ក្នុងការគិត អំពីការចាប់ផ្ដើមនៃការរស់រានរបស់ខ្លួនទេ ហើយក៏មិនសូវបានគិតច្រើនអំពីការបញ្ចប់របស់ខ្លួនដែរ ប៉ុន្តែអ្វីដែលមនុស្សខ្វល់ គឺមនុស្សខ្វល់អំពីការរស់និងបញ្ហាផ្សេងៗនៅពេលបច្ចុប្បន្ននេះទៅវិញ។ សម្រាប់ប្រទេសនីមួយៗក៏ដូច្នោះដែរ គេសរសេរប្រវត្តិរបស់ប្រទេសខ្លួន ដើម្បីឱ្យប្រជាជនបានដឹងយល់និងរួបរួមគ្នា ហើយគេសរសេរតែអ្វី ដែលជាអំពើវិជ្ជមានសម្រាប់ប្រទេសគេ ឧទាហរណ៍ បើលើកទ័ពទៅវាយយកប្រទេសគេផ្សេងមកត្រួតត្រា ក៏គេមានហេតុផលដែរ។ បើនិយាយតាមសាសនា វិញ គឺគេចាប់ផ្ដើមពីអ្វីៗ គឺព្រះជាអ្នកបង្កើត ហើយបញ្ចប់ដោយព្រះ។ ដូច្នេះតាមសាសនា គេមិនចាំបាច់រកអំណះអំណាងតាមបែបវិទ្យាសាស្ត្រ (emperical evidence) មកពន្យល់ទេ ។ នៅពេលដែលយើងដឹងច្បាស់ថាយើងកើតចេញពីណា ហើយទៅណា នោះ យើងនឹងមានការគិត ការពិចារណា បានទូលំទូលាយជាងមុន ។ អ្វីៗជាអំណាចរបស់ធម្មជាតិមនុស្សអាចកែប្រែធម្មជាតិបាន តែមិនបានច្រើនណាស់ណាទេ ដូចជាការឈូសភ្នំ បូមទឹកទន្លេ ។ល។ ដើម្បីអភិវឌ្ឍន៍ មនុស្សខិតខំកែប្រែធម្មជាតិ និងឆ្នៃប្រឌិតផ្សេងៗ ពេលខ្លះ ក៏បំផ្លាញធម្មជាតិ ដូចជាការកាប់ព្រៃឈើ ការគាស់កកាយយកថ្ម ... ដើម្បីសាងសង់ ឬដើម្បីប្រយោជន៍បុគ្គល។ មនុស្សអាចបង្កើតគ្រាប់បែក នុយក្លេអ៊ែរ ដើម្បីកម្ទេចទីក្រុង ឬសម្លាប់មនុស្សគ្នាឯងបាន ប៉ុន្តែគ្រាប់បែកទាំងនេះ មិនអាចធ្វើឱ្យស្រទាប់

ផែនដី ដែលមានកម្រាស់៣០០គីឡូម៉ែត្រ និងជម្រៅម៉ាក់ម៉ាដ៏ក្តៅ ១០,០០០គីឡូម៉ែត្រ ខូចបានទេ ។ នៅពេលដែលមនុស្ស ធ្វើហួសពីដែនកំណត់របស់ខ្លួន ពេលនោះ ធម្មជាតិអាចនឹងកែសម្រួល ឱ្យមនុស្សវិនាសទៅវិញបាន ។ ដូចជា ព្យុះ ទឹកជំនន់ ស៊ូណាមិ គ្រោះរាំងស្ងួត ជំងឺឆ្លងធំៗ ជាដើម ។

**សម្រាប់ពេលវេលា**




**សម្រាប់ទំហំនិងចម្ងាយ**




នៅក្នុងរូបភាពនេះ យើងឃើញថា តាមពិតទៅ ពេលវេលានិងចម្ងាយ គឺគ្មានទីចាប់ផ្តើមនិងគ្មានទីបញ្ចប់ទេ ។ រីឯទំហំនិងចម្ងាយដ៏ដូច្នេះដែរ យើងមិនឃើញមានព្រំដែនថាតូចបំផុតប៉ុនណា និងធំបំផុតប៉ុនណាទេ ។

ប៉ុន្តែ គេអាចចាប់គិតអំពីវត្ថុអ្វីមួយ ដែលមានរូបភាពជាក់ស្តែង ដូចជា ពេលកកើតនៃផែនដី ឬពេលកកើតនៃព្រះអាទិត្យជាដើម ឬក៏គេអាចគិតចម្ងាយពីផែនដីទៅកាន់ផ្កាយណាមួយបាន ។

## ១. ប្រវត្តិនៃហ្គាឡាក់ស៊ី

ពេលយប់មេឃស្រឡះល្អ យើងសម្លឹងមើលទៅលើមេឃ ដោយភ្នែកទទេ យើងអាចឃើញ កញ្ចុំផ្កាយនិងស្រមោលសៗ មានសណ្ឋានដូចជា ពពកសដុំៗ នោះហើយគឺជា ហ្គាឡាក់ស៊ី ។ ហ្គាឡាក់ស៊ី មានចំនួនច្រើនណាស់នៅលើមេឃ ។

ហ្គាឡាក់ស៊ី (galaxy) គឺជាប្រព័ន្ធនៃផ្កាយ ដែលប្រមូលផ្តុំគ្នាដោយសារកម្លាំងទំនាញ នៅក្នុងនោះមាន ផ្កាយធំ ផ្កាយតូច ធូលី ឧស្ម័ន សារធាតុខ្មៅ ។ល។ ព្រះអាទិត្យក៏ជាផ្កាយមួយដែរ ក្នុងចំណោមផ្កាយនានានៅក្នុងចក្រវាល ។

ពាក្យថា ហ្គាឡាក់ស៊ី (galaxy) ជាពាក្យភាសាក្រិក មានន័យថា ១- ដែលលាយឬធ្វើពីទឹកដោះ ២- មិនថ្លា ល្អក់ ពណ៌ដូចទឹកដោះគោ ។

ហ្គាឡាក់ស៊ីខ្លះមានទំហំតូចៗ ជាបណ្តុំផ្កាយ ដែលមានចំនួនផ្កាយតែប៉ុន្មានរយលានផ្កាយទេ ($10^8$) ។ ហ្គាឡាក់ស៊ីខ្លះទៀតមានទំហំធំ ជាបណ្តុំផ្កាយ ដែលមានចំនួនផ្កាយក៏ច្រើន មានចំនួនផ្កាយរាប់ទ្រីលាន ($10^{14}$) ។

តាមការសិក្សានៅឆ្នាំ ២០១៦ ចំនួន ហ្គាឡាក់ស៊ី ដែលគេបានរកឃើញនៅក្នុងចក្រវាលយើង មានចំនួន **២ទ្រីលាន** ($2 \times 10^{12}$) ដែលកាលពីពេលមុន គេរកឃើញតែ ២០០ប៊ីលានទេ ($2 \times 10^{11}$) ។ គេប៉ាន់ស្មានថា ផ្កាយទាំងអស់មានចំនួនប្រមាណជា ($1 \times 10^{24}$) គឺថា មានច្រើន

ជាងចំនួនគ្រាប់ខ្សាច់ទាំងអស់ ដែលមាននៅលើភពផែនដីយើងសព្វថ្ងៃទៅទៀត ។

ផែនដីយើងសព្វថ្ងៃនេះ ស្ថិតនៅក្នុង ហ្គាឡាក់ស៊ី មួយឈ្មោះ មីលគីវេ (Milky Way) ។ នៅក្នុង ហ្គាឡាក់ស៊ី មីលគីវេ យើងនេះ មានផ្កាយទាំងអស់ចំនួន **៥០០ ពាន់លាន**ដួង។



NGC 4414, a typical spiral galaxy in the constellation Coma Berenices, is about 55,000 light-years in diameter and approximately 60 million light-years from Earth.

នេះជារូបភាពមួយនៃ ហ្គាឡាក់ស៊ី ដែលមានចម្ងាយ៦០លានឆ្នាំពន្លឺពីផែនដី ។

សូមបញ្ជាក់ថា ១វិនាទីនៃពន្លឺ មានចម្ងាយ ៣០០ ០០០ គីឡូម៉ែត្រ (1 light-second = 299 792 458m) ។

១ឆ្នាំពន្លឺ = 365.25 light-days = 31 557 600 light-seconds =

គឺមានចម្ងាយ = 9.461 x $10^{12}$ km ។

បន្ទាត់ផ្ចិត (diameter) នៃហ្គាឡាក់ស៊ីយើង (Milky Way Galaxy) មានប្រវែង 100 000 ឆ្នាំពន្លឺ និងមានចម្ងាយពី ហ្គាឡាក់ស៊ី អង់ដ្រូម៉េដា (Andromeda Galaxy) ដែលជិតបំផុត គឺ២លាន៥សែនឆ្នាំពន្លឺ ។ ចម្ងាយពីព្រះអាទិត្យយើង ទៅដល់ចំណុចកណ្តាលនៃ Milky Way Galaxy មាន ២៦០០០ឆ្នាំពន្លឺ។

## ២. ការកើតប្រព័ន្ធព្រះអាទិត្យនិងភពផែនដី

### ២.១. ការចាប់កំណើតដំបូង

យោងតាមការសិក្សាប្រវត្តិសាស្ត្រ អ្នកបុរាណវិទូ អ្នកតារាវិទូ បានបង្ហាញអំពីប្រវត្តិនៃផែនដីនិងប្រព័ន្ធព្រះអាទិត្យ។ ប្រមាណជា៤៥០០លានឆ្នាំមុន បន្ទាប់ពីសារធាតុប្រមាណជា ៩៩,៩% នៃប្រព័ន្ធព្រះអាទិត្យបានប្រមូលផ្តុំគ្នាបង្កើតទៅជាព្រះអាទិត្យនោះ សារធាតុប្រមាណជាង ០,១% ដែលនៅសេសសល់បានប្រមូលផ្តុំគ្នាបន្តិចម្តងៗបង្កើតទៅជាភព ក្នុងនោះក៏មានភពផែនដីរបស់យើងមួយផងដែរ[1]។

ព្រះអាទិត្យយើងស្ថិតនៅក្នុង ហ្គាឡាក់ស៊ី មួយមានឈ្មោះថា ហ្គាឡាក់ស៊ី មីលគីវេ (Milky Way Galaxy) ដែលមានបន្ទាត់ផ្ចិតទំហំ១០០ពាន់

[1] អត្ថបទដោយ **សេង ឌីណា** វិទ្យុបារាំង RFI

ឆ្នាំពន្លឺ និងមានផ្កាយដូចគ្នានឹងព្រះអាទិត្យយើងដែរ ចំនួន៥០០ពាន់លានដួង ។




ប្រព័ន្ធព្រះអាទិត្យស្ថិតនៅក្នុងហ្គាឡាក់ស៊ី មីលគីវេ ដែលមានបន្ទាត់ផ្ចិតទំហំ២០០ពាន់ឆ្នាំពន្លឺ និងមានផ្កាយចំនួន៥០០ពាន់លានដួង

## កំណើតនៃព្រះអាទិត្យ

ព្រះអាទិត្យ គឺជាផ្កាយមួយដួងគត់ មានទំហំដ៏ធំ ដោយប្រមូលផ្តុំម៉ាស់រហូតដល់ ៩៩% នៃប្រព័ន្ធព្រះអាទិត្យទាំងមូល ដែលមានភពរណបនានាជាច្រើនវិលជុំវិញ។ ព្រះអាទិត្យមានចម្ងាយ ១៤៩,៥ លានគីឡូម៉ែត្រ ពីផែនដីយើង។

ព្រះអាទិត្យ គឺជាប្រភពថាមពលមួយ មិនអាចខ្វះបាន សម្រាប់ជីវិតលើភពផែនដី។ បើគ្មានថាមពលពីព្រះអាទិត្យទេនោះ ជីវិតលើភាព

ផែនដីយើងនេះ ក៏មិនអាចចាប់កំណើត និងរីកលូតលាស់ រហូតមកទល់នឹងសព្វថ្ងៃនេះបានទេ។ ប៉ុន្តែ ព្រះអាទិត្យ ក៏មានអាយុជីវិតរបស់ខ្លួនឯងដែរ គឺមិនមែនមានអត្ថិភាពជាអមតៈទេ។ តើព្រះអាទិត្យរបស់យើងនឹងក្លាយទៅជាយ៉ាងណា នាពេលអនាគត[2] ?

ព្រះអាទិត្យរបស់យើង បានចាប់កំណើត តាំងពី៤៥០០លានឆ្នាំ ដោយចាប់កំណើតចេញពីសារធាតុ ដែលមានទម្រង់ជាល្អងធូលី តូចល្អិត ហើយប្រមូលផ្តុំគ្នា ជា ស្វ៊ែរឧស្ម័ន មានធាតុផ្សំជា អ៊ីដ្រូសែន (Hydrogen) និង អេល្យូម (Helium)។ បន្ទាប់មក បន្តិចម្តងៗ ក្នុងរយៈពេលរាប់សិបលានឆ្នាំ មានការប្រមូលផ្តុំសារធាតុ កាន់តែធំទៅៗ ធ្វើឱ្យសម្ពាធ និងសីតុណ្ហភាព កាន់តែខ្លាំងឡើង ដែលធ្វើស្នូលកើនឡើងរាប់លានអង្សា។ សីតុណ្ហភាពនិងសម្ពាធដ៏ខ្លាំងនេះ ធ្វើឱ្យមានប្រតិកម្មនុយក្លេអ៊ែរ ដែលធ្វើឱ្យអាតូមអ៊ីដ្រូសែន ប្រែក្លាយទៅជា អាតូមថ្មីមួយឈ្មោះថា អាតូមអេល្យូម។ ប្រតិកម្មនុយក្លេអ៊ែរ នេះហើយ ធ្វើឱ្យព្រះអាទិត្យ អាចបញ្ចេញកម្តៅនិងពន្លឺ ដូចដែលយើងឃើញសព្វថ្ងៃនេះ ។ អ្វីៗក៏មិនអមតៈ មិនចេះចប់ដែរ ដំណើរនៃចំហេះនេះ រយៈពេលយូរៗទៅ ធ្វើឱ្យបរិមាណអ៊ីដ្រូសែននៅក្នុងព្រះអាទិត្យ ក៏ថយចុះបន្តិចម្តងៗ។ នៅរៀងរាល់១វិនាទី ប្រតិកម្មនុយក្លេអ៊ែរ នៅក្នុងស្នូលនៃព្រះអាទិត្យ បរិមាណអ៊ីដ្រូសែនចំនួន ៦០០លានតោន ត្រូវបានរលាយចូលគ្នា ក្លាយទៅជាអេល្យូម ។

---

[2] ដកស្រង់ពីអត្ថបទលោក **សេង ឌីណា** វិទ្យុបារាំង RFI




ដំណើរការនៃការឆេះនេះ (ប្រតិកម្មនុយក្លេអ៊ែរ) មានជាប្រចាំតាំងតែពី ៤៥០០លានឆ្នាំមកហើយ ហើយក៏ចេះតែបន្តទៅទៀត។

នៅក្នុងស្នូលនៃព្រះអាទិត្យ មានសីតុណ្ហភាព ១៥លានអង្សាសេ ( 0C) កម្ដៅដ៏ខ្លាំងនេះ បានមកពីការសង្កត់បញ្ចូលគ្នានៃអាតូម អីដ្រូសែន (hydrogen) ឱ្យក្លាយទៅជាអាតូម អាល្យូម (helium) ។ សីតុណ្ហភាពលើផ្ទៃព្រះអាទិត្យ មានប្រមាណពី ៤,០០០ ទៅ ៥,៥០០ អង្សាសេ[3] ។

ឥទ្ធិពលដ៏ធំសម្បើមនៃព្រះអាទិត្យទៅលើផែនដីនេះ ត្រូវបានទទួលស្គាល់តាំងពីសម័យបុរេប្រវត្តិមកម្ល៉េះ។ ព្រះអាទិត្យត្រូវបានជំនឿវប្បធម៌មួយចំនួនចាត់ទុកថាជាអាទិទេព។ ការវិលនៃផែនដី តាមគន្លងរបស់ខ្លួនជុំវិញព្រះអាទិត្យ គឺជាមូលដ្ឋាននៃប្រតិទិនសូរិយគតិមួយចំនួន។ ប្រតិទិនដែលលេចធ្លោកំពុងប្រើប្រាស់សព្វថ្ងៃ គឺប្រតិទិនហ្គ្រេហ្គោរៀន (Gregorian) ដែលផ្អែកលើការបកស្រាយស្ដង់ដារនៃសតវត្សទី១៦ នៃការសង្កេតចលនារបស់ព្រះអាទិត្យជាក់ស្ដែង។

[3] Space.com



រូបថត ក្រូម៉ូស្វែរនៃព្រះអាទិត្យ (១២មករា ឆ្នាំ២០១៧)
ដោយ Hinode spacecraft

## ប្រវត្តិភពនានានៃប្រព័ន្ធព្រះអាទិត្យ

គេសន្មតថា អ្វីៗកើតពីល្អងធូលីដ៏តូចល្អិតដែលស្ថិតនៅជុំវិញព្រះអាទិត្យ ក្រោមឥទ្ធិពលនៃកម្លាំងទំនាញល្អងធូលីដ៏តូចល្អិតទាំងនោះបានប្រមូលផ្តុំគ្នាទៅជាបំណែកកាន់តែធំឡើងៗ រហូតដល់រាប់លានឆ្នាំក្រោយមកក៏មានម៉ាស់ និងកម្លាំងទំនាញគ្រប់គ្រាន់បង្កើតទៅជុំមានរាងជាស្វ៊ែរ ហើយដែលគេហៅថា «**ជាភព**» (planet)។ ភពផែនដី (Earth) ដែលទើបនឹងចាប់កំណើតឡើងដំបូងនោះ ក៏ត្រូវរងនូវការប៉ះទង្គិចជាប់ជាប្រចាំជាមួយនឹងបំណែកអាចម៍ផ្កាយ ឬផ្កាយដុះកន្ទុយដែលស្ថិតនៅក្នុងគន្លងតារាវិថីក្បែរគ្នា ហើយការប៉ះទង្គិចគ្នានោះបានធ្វើឱ្យផែនដីអាចប្រមូលផ្តុំធាតុផ្សំបានកាន់តែច្រើនឡើង ហើយទំហំក៏កាន់តែរីកធំឡើងទៅតាមនោះផងដែរ។ ក៏ប៉ុន្តែ នៅពេលនោះ ផែនដីរបស់យើងមិនមែនប៉ះទង្គិចតែជាមួយនឹងបំណែកអាចម៍ផ្កាយ ឬផ្កាយដុះកន្ទុយនោះទេ តែ

មានការប៉ះទង្គិចដ៏អស្ចារ្យមួយទៀត ដែលបានបន្សល់ទុកនូវផលវិបាកដ៏សំខាន់បំផុតដល់ភពផែនដីនិងមនុស្សជាតិយើងរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។



ប្រព័ន្ធព្រះអាទិត្យ (solar system)

នៅប្រមាណជា ១០០លានឆ្នាំ ក្រោយការចាប់កំណើតនៃប្រព័ន្ធព្រះអាទិត្យ ពេលដែលផែនដីបានកើនទំហំជិតប៉ុននឹងសព្វថ្ងៃកូនភពតូចមួយ ដែលគេឱ្យឈ្មោះថា "តេយ៉ា" (Theia) មានទំហំប៉ុនភពអង្គារ (ប្រហែលពាក់កណ្តាលនៃភពផែនដី) បានហោះមកបុកនឹងភពផែនដី។ កម្លាំងទង្គិចបានធ្វើឱ្យភពទាំងពីរត្រូវរលាយចូលគ្នា ក៏ប៉ុន្តែក្នុងពេលជាមួយគ្នាដោយសារតែការទង្គិចគ្នានេះកើតឡើងក្នុងទិសដៅបញ្ឆិត ដូច្នេះផ្នែកខ្លះនៃកូនភពតេយ៉ា ព្រមទាំងផ្នែកខ្លះនៃផែនដីត្រូវខ្ទាតចេញទៅក្នុងទីអវកាស ហើយក្លាយទៅជាបំណែកខ្លះតូច ខ្លះធំ ស្ថិតនៅវិលជុំវិញភពផែនដី។




ឈ្មោះភពនានាក្នុងប្រព័ន្ធព្រះអាទិត្យ

(solar system planets)

បំណែកអស់ទាំងនេះហើយ ដែលក្រោយមកបានប្រមូលផ្តុំគ្នាបន្តិចម្តងៗ បង្កើតបានទៅជាព្រះចន្ទ ដែលវិលជុំវិញភពផែនដីរបស់យើងរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។ ឥទ្ធិពលនៃកម្លាំងទង្គិចនៅពេលនោះ បានធ្វើឱ្យអ័ក្សផែនដី ពោលគឺអ័ក្សនៃចលនាវិលជុំវិញខ្លួនឯងរបស់ភពផែនដី ត្រូវទ្រេត ហើយភាពទ្រេតនៃអ័ក្សផែនដីនេះ គឺជាកត្តាដ៏សំខាន់មួយដែលធ្វើឱ្យផែនដីរបស់យើងមានអាកាសធាតុ ដែលចែកចេញជារដូវកាលយ៉ាងទៀងទាត់រហូតមកទល់នឹងពេលបច្ចុប្បន្ន។

លើសពីនេះទៀត វត្តមានរបស់ព្រះចន្ទនៅវិលជុំវិញភពផែនដី និងដែលមានទំហំរហូតដល់ទៅជិត ៣០% នៃទំហំផែនដី បានបង្កើតឱ្យមានជាតុល្យភាពនៃកម្លាំងទំនាញមួយ ដែលជួយឱ្យអ័ក្សផែនដីរបស់យើងមានលំនឹង ដែលជាកត្តាដ៏ចម្បងមួយធ្វើឱ្យអាកាសធាតុនៅលើភពផែនដីមានលំនឹងមិនសូវប្រែប្រួលខ្លាំង ដែលជាកត្តាដ៏សំខាន់សម្រាប់ការវិវត្តនៃជីវិត។ ព្រះចន្ទ ក៏បានជួយឱ្យចលនាវិលជុំវិញខ្លួនឯងរបស់ផែនដីត្រូវបន្ថយល្បឿនផងដែរ ដែលជាហេតុធ្វើឱ្យថ្ងៃនៅលើភពផែនដីមានរយៈពេល

កាន់តែវែង ពោលគឺ មួយថ្ងៃដែលពីមុនមានត្រឹមតែ៦ម៉ោងនោះ ត្រូវអូស បន្លាយពេលបន្តិចម្តងៗរហូតដល់ ២៤ម៉ោង ដូចជាពេលបច្ចុប្បន្ននេះ។



មនុស្សដើរលើឋានព្រះចន្ទ

ក្រោយមកទៀត នៅពេលដែលបំណែកភាគច្រើនដែលនៅលើគន្លងជាមួយគ្នាបានប៉ះទង្គិច ហើយរលាយចូលគ្នាជាមួយនឹងភពផែនដី ហេតុការណ៍ប៉ះទង្គិចគ្នាក៏កើតមានកាន់តែតិចទៅៗ ហើយសីតុណ្ហភាពលើភពផែនដីក៏ចាប់ផ្តើមថយចុះ។ ដល់ពេលមួយ ស្រទាប់ខាងលើនៃភពផែនដីក៏ចាប់ផ្តើមកករឹងទៅជាផ្ទៃកមួយដែលគេឱ្យឈ្មោះថា "សម្បកផែនដី" ចំណែកឯសារធាតុដែកនិងនីកែលដែលធ្លាក់ចុះទៅខាងក្រោមក៏ប្រមូលផ្តុំគ្នាបង្កើតទៅជា "ស្នូលផែនដី"។ ស្នូលផែនដីដែលសម្បូរទៅដោយសារធាតុដែកនេះហើយ ដែលបង្កើតឱ្យមានជាដែនម៉ាញេទិក នៅជុំវិញភពផែនដី ហើយជារបាំងជួយការពារផែនដីពីកម្លាំងខ្យល់ពីព្រះអាទិត្យ

(Solar Wind) ក៏ដូចជាសារធាតុវិទ្យុសកម្មផ្សេងទៀតមកពីទីអវកាស ដែលនេះគឺជាកត្តាដ៏ចម្បងមួយសម្រាប់ការកកើតជីវិត នៅពេលក្រោយមកទៀត។ ក៏ប៉ុន្តែ មុននឹងជីវិតអាចកកើតឡើងបាននៅលើភពផែនដី គេត្រូវការនូវធាតុផ្សំដ៏ចម្បងមួយគឺ ទឹក។

នៅក្នុងពេលបច្ចុប្បន្ននេះ គេដឹងថា ផ្ទៃនៃភពផែនដីរហូតដល់ទៅជាង ៧០% ត្រូវគ្របដណ្ដប់ទៅដោយទឹកសមុទ្រ។ មានចម្ងល់បានចោទឡើងថា តើទឹកដ៏ច្រើនសន្ធឹកសន្ធាប់នេះមានប្រភពដើមចេញមកពីណា។

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវចុងក្រោយបង្អស់ អ្នកវិទ្យាសាស្ត្របានកំណត់ថា ប្រភពនៃម៉ូលេគុលទឹក ($H_2O$) ដើមដំបូងលើភពផែនដីត្រូវចែកចេញជាពីរផ្នែក ដោយមួយផ្នែក គឺមានប្រភពចេញពីធាតុផ្សំដើមដំបូងរបស់ភពផែនដី ពោលគឺម៉ូលេគុលទឹកស្ថិតនៅក្នុងបំណែកតូចធំទាំងឡាយដែលប្រមូលផ្ដុំគ្នាបង្កើតជាភពផែនដី។ មួយផ្នែកទៀតគឺម៉ូលេគុលទឹក ដែលមានប្រភពចេញពី អាចម៍ផ្កាយ (Asteroid) ឬផ្កាយដុះកន្ទុយ (Comet) ដែលធ្លាក់មកលើផែនដីនៅពេលក្រោយៗមកទៀត។ ក៏ប៉ុន្តែ កាលពីដំបូងឡើយដោយសារតែផែនដីមានសីតុណ្ហភាពក្ដៅខ្លាំងពេកម៉ូលេគុលទឹកអស់ទាំងនេះមិនអាចស្ថិតនៅជាសភាពរាវ នៅលើផ្ទៃដីបាននោះទេ ផ្ទុយទៅវិញវាត្រូវប្រមូលផ្ដុំគ្នាជាចំហាយទឹក ស្ថិតនៅពាសពេញក្នុងបរិយាកាសនៃភពផែនដី។ រហូតទាល់តែដល់ពេលដែលសីតុណ្ហភាពធ្លាក់ចុះដល់កម្រិតមួយទាបល្មម ទើបចំហាយទឹកនេះប្រមូលផ្ដុំគ្នាទៅជាពពក រួចហើយបង្កើតបានជាភ្លៀងធ្លាក់ចុះមកលើផ្ទៃដី ហើយបន្តិចម្ដងៗទឹកភ្លៀងទាំងនេះបានប្រមូលផ្ដុំគ្នាលើផ្ទៃដី ដំបូងបង្កើតបានជាថ្លុក ត្រពាំងបឹងបួរ ហើយក្នុងរយៈពេលរាប់លានឆ្នាំក្រោយមកទៀតបរិមាណទឹកនៅ

លើផ្ទៃដីក៏កើនឡើងកាន់តែខ្លាំង ហើយរីកសាយភាយរហូតបង្កើតបានទៅជាមហាសមុទ្រ។

គិតត្រឹមប្រមាណជា ៣៨០០លានឆ្នាំមុន ពោលគឺប្រមាណជា ៧០០លានឆ្នាំ ក្រោយការចាប់កំណើតនៃប្រព័ន្ធព្រះអាទិត្យ ផែនដីរបស់យើងបានចាប់កំណើតឡើងទៅជាភពមួយ ដែលមាន "ស្នូល" និងដែនម៉ាញ៉េទិក, មានព្រះចន្ទ និងមានចលនាវិលជុំវិញអ័ក្សប្រកបដោយលំនឹង ព្រមទាំងមានសីតុណ្ហភាពធ្លាក់ចុះទាបល្មម ដែលអាចឱ្យទឹកអាចស្ថិតនៅជាសភាពរាវ ហើយប្រមូលផ្តុំគ្នាជាមហាសមុទ្រនៅលើផ្ទៃដីជាប់ជាប្រចាំ។ ក្នុងពេលជាមួយគ្នា ថាមពលនៃកម្តៅក្នុងស្នូលផែនដីបានរុញដីបាតសមុទ្រឱ្យប៉ោងឡើងបង្កើតទៅជាភ្នំភ្លើង និងជាកូនកោះតូចៗ ដែលប្រមូលផ្តុំគ្នាបន្តិចម្តងៗទៅជាដីគោក និងរាប់រយលានឆ្នាំក្រោយៗមកទៀតបង្កើតបានទៅជាទ្វីប។

## ២.២. អាយុកាលរបស់ភពផែនដី

### <u>មូលហេតុអ្នកវិទ្យាសាស្ត្រកំណត់ថាផែនដីរបស់យើងមានអាយុ ៤៥០០លានឆ្នាំ</u>

ការសិក្សាស្រាវជ្រាវអំពីអាយុកាលរបស់ភពផែនដី គឺបានចាប់ផ្តើមឡើងជាង ៤០០ឆ្នាំមកហើយ ដែលមានអ្នកប្រាជ្ញខ្លះថាអាយុកាលផែនដីគឺប្រមាណជាង៥០លានឆ្នាំ និងរហូតមានខ្លះទៀតថា ផែនដីមានអាយុកាលប្រមាណជាង ៥០០លានឆ្នាំ។ ប៉ុន្តែបច្ចុប្បន្ន គេបានឯកភាពគ្នាថា ផែនដីមានអាយុកាលប្រមាណ ៤៥០០លានឆ្នាំ ដែលបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាទូទាំងសាកលលោក ដែលការសន្និដ្ឋាននេះបានធ្វើឡើង

ដោយអ្នកបុរាណវិទូនិងអ្នកវិទ្យាសាស្ត្រ តាមរយៈការសិក្សាលើតំបន់មួយចំនួនលើភពផែនដីដែលមានវ័យចំណាស់បំផុត។

អ្នកវិទ្យាសាស្ត្រនិងអ្នកបុរាណវិទូបានជ្រើសរើសយកដុំថ្មមួយដែលមានឈ្មោះថា CASTAJINES ស្ថិតនៅភាគខាងជើងនៃទីក្រុងកេប៊ិច ប្រទេសកាណាដា និងការសិក្សាលើដុំថ្មនៃឋានព្រះច័ន្ទមួយផ្សេងទៀត នោះក៏មិនសូវជាខុសគ្នាដែរនាំឱ្យគេសន្និដ្ឋានថា ភពផែនដីមានអាយុកាលប្រមាណ៤៥០០លានឆ្នាំ[4]។




គេមានការមូលមតិគ្នាថា ផែនដីមានអាយុកាលប្រមាណ ៤៥០០ លានឆ្នាំ ដែលសារធាតុប្រមាណជា ៩៩,៩% នៃប្រព័ន្ធព្រះអាទិត្យបានប្រមូលផ្តុំគ្នាបង្កើតទៅជាព្រះអាទិត្យនោះសារធាតុប្រមាណជាង ០,១% ដែលនៅសេសសល់បានប្រមូលផ្តុំគ្នាបន្តិចម្តងៗបង្កើតទៅជាភព ក្នុងនោះក៏មានភពផែនដីរបស់យើងមួយផងដែរ [5]។

[4] Video ចេញផ្សាយដោយ www.Cambo-Space.com ថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៨

[5] អត្ថបទ វិទ្យុបារាំង RFI

អ្នកវិទ្យាសាស្រ្តបានចំណាយពេលរាប់រយឆ្នាំដើម្បីធ្វើការកំណត់អំពីអាយុកាលផែនដី[6]។ តាមរយៈការសិក្សាលើផ្ទាំងថ្មនៅលើសំបកផែនដី ក៏ដូចជាផ្ទាំងថ្មនៅលើឋានព្រះចន្ទ និងបំណែកអាចម៍ផ្កាយ អ្នកវិទ្យាសាស្រ្តបានគណនានិងសន្មត់ថា ផែនដីមានអាយុកាលប្រមាណ ៤៥០០ លានឆ្នាំ ដែលមានគម្លាតឆ្គងប្រហែល ៥០លានឆ្នាំ។[7]

ប៉ុន្តែ តាមរយៈផែនដីវិទ្យា គេចែកអាយុកាលនៃផែនដីបានដោយសារតែការវិវត្តរបស់ស័ក មានដូចជា[8] ដំណាក់កាល**ប៉ាលេអូសូអ៊ិច** (Paléozoïque), ដំណាក់កាល**មេសូសូអ៊ិច** (Mésozoïque) និងដំណាក់កា**លសេណូសូអ៊ិច** (Cénozoïque) ដែលអ្នកបុរាណវិទូ និងអ្នកស្រាវជ្រាវបានសន្មត់ថាផែនដីមានអាយុកាលប្រមាណជាង ៤៥០០ លានឆ្នាំ ហើយដែលមនុស្សទូទាំងពិភពលោកបានដឹងនិងទទួលស្គាល់យ៉ាងទូលំទូលាយរហូតមកដល់បច្ចុប្បន្ននេះ។

### ២.៣. ផែនដីជាជង្រុកមាសសម្រាប់ជីវិត

ភពផែនដី គឺជាភពមួយក្នុងចំណោមភពទាំង៨ នៅក្នុងប្រព័ន្ធព្រះអាទិត្យ ក៏ប៉ុន្តែផែនដី គឺជាភពដែលមិនស្ថិតនៅជិតព្រះអាទិត្យពេក ដែលនាំឱ្យមានកម្តៅខ្លាំងជ្រុល ហើយក៏មិននៅឆ្ងាយពីព្រះអាទិត្យពេក ដែលនាំឱ្យមានត្រជាក់ខ្លាំង ប៉ុន្តែស្ថិតនៅក្នុងរយៈចម្ងាយដ៏សមស្របមួយប្រកបដោយអំណោយផលដល់ការចម្រើនលូតលាស់នៃជីវចម្រុះ ដែលក្នុងនោះក៏រួមទាំងមនុស្សជាតិយើងផងដែរ។

---

[6] អត្ថបទ www.space.com

[7] អត្ថបទ www.space.com (February 07, 2019 )

[8] អត្ថបទ http://www.khsearch.com

ផែនដីបានឆ្លងកាត់នូវដំណើរការផ្លាស់ប្តូរ និងការប្រែប្រួលជាច្រើន ដំណាក់កាលមុននឹងមានលក្ខណៈអំណោយផលដូចសព្វថ្ងៃនេះ។ កាលពីប្រមាណជា ៥០ លានឆ្នាំមុននោះ នៅក្នុងអំឡុងពេលប្រហាក់ប្រហែលគ្នានឹងការចាប់រីកលូតលាស់នៃពពួកថនិកសត្វ ផ្លាកតិចតូនិកឥណ្ឌាដែលបានបែកចេញពីអាហ្វ្រិក កាលពីពេលប្រេះបែកនៃមហាទ្វីប ភែនជៀ (Pangea) នៅប្រមាណជាជិត២០០លានឆ្នាំមុននោះ ក៏បានរំកិលមកជួបនឹងផ្លាកតិចតូនិកអាស៊ី ហើយជំនួប រវាងផ្លាកតិចតូនិកទាំងពីរនេះ បានបង្កើតឱ្យមាននូវជួរភ្នំដ៏វែង និងដ៏ខ្ពស់មួយ គឺជួរភ្នំហិមាល័យ ដែលមានបណ្តោយរហូតដល់ទៅ ២៤០០គីឡូម៉ែត្រ ហើយមានភ្នំដ៏ខ្ពស់បំផុតមួយនៅលើពិភពលោក គឺភ្នំអេវើរែស (Everest) ដែលមានកម្ពស់រហូតដល់ទៅ ៨៨៤៨ម៉ែត្រ។

ជួរភ្នំហិមាល័យនេះ បូករួមជាមួយនឹងខ្ពង់រាបទីបេដែលនៅក្បែរនោះ បានក្លាយទៅជាប្រភពទឹកដ៏សំខាន់មួយ ដែលផ្គត់ផ្គង់ទឹកទៅដល់បណ្តាទន្លេជាច្រើននៅក្នុងតំបន់អាស៊ី ជាពិសេស គឺទន្លេធំៗ ដែលជាទីចាប់កំណើតនៃអរិយធម៌២ ក្នុងចំណោមអរិយធម៌ដ៏ចំណាស់បំផុតទាំង៤ នៅក្នុងប្រវត្តិរបស់មនុស្សជាតិ គឺចិន និងឥណ្ឌា។

ក៏ប៉ុន្តែ មុននឹងឈានដល់ដំណាក់កាលនៃការកកើតអរិយធម៌នេះ ភពផែនដីរបស់យើង ត្រូវឆ្លងកាត់នូវដំណើរវិវត្តន៍ជាច្រើនលានឆ្នាំទៀត ដែលរួមមានទាំងការប្រែប្រួលអាកាសធាតុពីក្តៅ ទៅជាយុគសម័យទឹកកក ពីតំបន់ដែលគ្របដណ្តប់ទៅដោយព្រៃខ្ពស់ៗ ទៅជាតំបន់ដែលគ្រប់ដណ្តប់ទៅដោយវាលស្មៅ មុននឹងឈានទៅដល់ដំណាក់កាលនៃការលេចមុខនៃមនុស្សជាតិយើង កាលពីប្រមាណ ២០ម៉ឺនឆ្នាំមុន។

*លក្ខណៈពិសេសនៃភពផែនដីក្នុងប្រព័ន្ធព្រះអាទិត្យ*

ជាការពិតណាស់ ផែនដី ដែលគេហៅថាជា «ជង្រុកមាស» នោះគឺជាភពមួយដែលមានលក្ខណៈពិសេសជាងគេក្នុងចំណោមភពទាំងអស់ក្នុងប្រព័ន្ធព្រះអាទិត្យទាំងមូល។ ភពផែនដី ជាទីឋានតែមួយគត់ដែលអាចឱ្យមនុស្ស សត្វ និងរុក្ខជាតិ រស់នៅបាន ដោយសារអាកាសធាតុមិនក្ដៅខ្លាំង និងមិនត្រជាក់ខ្លាំង ព្រមទាំងប្រភពទឹក និងអុកស៊ីសែនដ៏ចាំបាច់ក្នុងការទ្រទ្រង់ជីវិត។

ជាងនេះទៅទៀតផែនដីមានលក្ខណៈពិសេស ដោយសារតែៈ

១- ផែនដី ដែលបច្ចុប្បន្នវិលយឺតជាងមុន ក្នុងល្បឿន ១៧០គីឡូម៉ែត្រក្នុងមួយម៉ោង និងមានរយៈពេល ២៣ម៉ោង ៥៦នាទី និង៤វិនាទី (ឬស្មើនឹង២៤ម៉ោង) គឺយឺតជាងកាលពីរាប់លានឆ្នាំមុន។

២- ផែនដីនៅចម្ងាយ ប្រហែល១៥០លានគីឡូម៉ែត្រ ពីព្រះអាទិត្យដែលមិនក្ដៅពេក ហើយក៏មិនត្រជាក់ពេក ដែលអាចឱ្យជីវិតរស់នៅបាន។

៣- មានផ្ទៃទឹកច្រើនជាង ៧១% (ភាគរយ) ដែលអាចរក្សាលំនឹងអាកាសធាតុបានប្រសើរជាងកាលពីរាប់លានឆ្នាំមុន។

៤- ផែនដីមានប្រព័ន្ធស្រទាប់អូហ្សូន ដែលហ៊ុមព័ទ្ធជុំវិញដើម្បីការពារផែនដីពីកម្ដៅព្រះអាទិត្យ។

## ២.៤. ការប្រឈមរបស់ផែនដីក្រោយការចាប់កំណើត

ដូចដែលយើងបានដឹងហើយថា ភពផែនដីបានចាប់កំណើតឡើងកាលពីប្រមាណ ៤៥០០ លានឆ្នាំមុន ដោយការប្រមូលផ្ដុំនៃល្អងធូលីដែលនៅសេសសល់ពីការបង្កើតប្រព័ន្ធព្រះអាទិត្យ និងបានវិវត្តធំឡើងៗ ក្នុងរយៈពេលរាប់រយឆ្នាំក្រោយមក។ ក្នុងរយៈពេលរាប់លានឆ្នាំក្រោយមកទៀតផែន

ដីត្រូវទទួលរងនូវការប៉ះទង្គិចជាច្រើនលើកច្រើនសារដោយកម្មេច និងដុំអាចម៍ផ្កាយដែលធ្លាក់ស្រោចលើភពផែនដី និងការបុកគ្នារវាងភពផែនដី និងកូនភព «តេយ៉ា» ដែលមានទំហំប្រហាក់ប្រហែលនឹងភពអង្គារ និងដែលជាហេតុធ្វើឱ្យភពផែនដីផ្លាស់ប្តូរសណ្ឋានជាខ្លាំង ព្រមទាំងផលវិបាកផ្សេងៗ

សម្រាប់មនុស្សជាតិរហូតមកទល់នឹងពេលបច្ចុប្បន្ន។

# ជំពូកទី២
# ប្រវត្តិកកើតជីវិតលើភពផែនដី

## ១. ការកកើតដំបូងនៃជីវិត

គិតត្រឹមប្រមាណជា ៣៨០០លានឆ្នាំមុន ពោលគឺ ប្រមាណជា ៧០០លានឆ្នាំ ក្រោយការចាប់កំណើតនៃប្រព័ន្ធព្រះអាទិត្យ ផែនដីរបស់យើងបានចាប់កំណើតឡើងទៅជាភពមួយ ដែលមាន "ស្នូល" និងដែនម៉ាញេទិក មានព្រះចន្ទ និងមានចលនាវិលជុំវិញអ័ក្សប្រកបដោយលំនឹង, មានមហាសមុទ្រ និងមានដីគោក។ ក៏ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ភពផែនដីក៏នៅមិនទាន់ក្លាយជាទីកន្លែង ដែលពោរពេញទៅដោយជីវិតស្រស់ថ្លាដូចជាពេលបច្ចុប្បន្ននេះនៅឡើយទេ។

តាមប្រវត្តិភូគព្ភសាស្ត្រនៃផែនដី (Geological history of the Earth) ចំនួនស័ក (Eras) ក្នុង១០០០លានឆ្នាំចុងក្រោយ ចែកចេញជា ៤ផ្នែកទៅតាមវេលាភូគព្ភសាស្ត្រ (Name of Geologic Time) គឺ :

- នវប្រូតេរ៉ូស្សូអ៊ិច (Neoproterozoic= ១០០០~៥៣៨,៨ លានឆ្នាំមុន)
- ប៉ាលេអូស្សូអ៊ិច (Paleozoic= ៥៣៨,៨ ~ ២៥១,៩ លានឆ្នាំមុន)
- មេស្សូស្សូអ៊ិច (Mesozoic= ២៥១,៩ ~ ៦៦លានឆ្នាំមុន)
- សេណូស្សូអ៊ិច (Cenozoic= ៦៦លានឆ្នាំមុនដល់បច្ចុប្បន្ន)

យ៉ាងតិច៥ដង។   ក្រៅពីយុគសម័យទឹកកកនេះ   នៅលើផែនដីយើង




* Ma= mega annum= ១លានឆ្នាំ

## យុគទឹកកក (Ice ages)

(២៨០០លានឆ្នាំ - ២១00 លានឆ្នាំ)

នៅក្នុងប្រវត្តិផែនដីយើង មានយុគទឹកកក(សម័យទឹកកក) ចំនួនយ៉ាងតិច៥ដង។   ក្រៅពីយុគសម័យទឹកកកនេះ   នៅលើផែនដីយើងហាក់មិនមានទឹកកកក្រាស់គ្របដណ្ដប់ទេ ។




រូបពណ៌ខៀវជាយុគទឹកកក

ភពផែនដីមានទឹក ក៏ប៉ុន្តែដើម្បីអាចឱ្យជីវិតសព្វសារពើ រួមទាំងជីវិតមនុស្សយើងផងអាចរស់នៅបាន គេត្រូវការលក្ខខណ្ឌដ៏ចាំបាច់មួយចំនួនផ្សេងទៀត ជាពិសេសគឺត្រូវការបរិយាកាស ដែលសម្បូរទៅដោយអុកស៊ីសែន។ នៅក្នុងបរិយាកាសនៃភពផែនដីកាលពីដំបូង គឺមានពោរពេញទៅដោយឧស្ម័នកាបូនិក នីត្រូសែន និងមេតាន ចំណែកឯអុកស៊ីសែនវិញមានតិចតួចតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយបានជាវាពិបាកនឹងធ្វើឱ្យជីវិតអាចចាប់កំណើតនិងរីកលូតលាស់ឡើងបាន ជីវិតមិនអាចចាប់កំណើតបាននៅលើដីនិងក្នុងបរិយាកាស ក៏ប៉ុន្តែ នៅឯក្រោមផ្ទៃសមុទ្រឯណោះវិញ ដំណើរវិវត្តន៍ដ៏សំខាន់មួយបានចាប់ផ្ដើមឡើង។

នៅក្នុងទឹកសមុទ្រសារធាតុសាមញ្ញៗមួយចំនួន រួមមាន អ៊ីដ្រូសែនដែលជាសារធាតុដើមកើតចេញក្រោយពីការផ្ទុះបន្ទុះ Big Bang បូករួមជាមួយនឹងសារធាតុផ្សេងទៀត ដែលកើតចេញពីផ្កាយ រួមមាន អុកស៊ីសែនកាបោន និងនីត្រូសែន ព្រមទាំងសារធាតុខ្លះទៀត ដែលធ្លាក់មកលើភពផែនដីជាមួយនឹងអាចម៍ផ្កាយ បានប្រមូលផ្ដុំគ្នាបង្កើតទៅជាធាតុផ្សំដ៏សំខាន់ៗសម្រាប់ការកកើតនៃជីវិត។ ជីវិតដែលចាប់ផ្ដើមឡើងជាដំបូងនៅពេលនោះ មិនមែនជាជីវិតក្នុងទម្រង់សាំញ៉ាំ ដូចជា មនុស្ស សត្វ ឬរុក្ខជាតិនោះទេ ក៏ប៉ុន្តែ ជាប្រភេទជីវិតក្នុងទម្រង់ដ៏សាមញ្ញ ដែលមានកោសិកាទោល គឺប្រភេទបាក់តេរី។

នៅក្នុងចំណោមបាក់តេរីអស់ទាំងនោះ មានបាក់តេរីមួយប្រភេទ (Cyanobactérie) រស់នៅដោយប្រើពន្លឺព្រះអាទិត្យដើម្បីស្រូបយកឧស្ម័នកាបូនិកទៅបំប្លែងជាសារធាតុគីមី ដើម្បីចិញ្ចឹមជីវិត នៅក្នុងយន្តការមួយដែលគេឱ្យឈ្មោះថា "**រស្មីសំយោគ**" (Photosynthèse) ហើយនៅក្នុងយន្តការរស្មីសំយោគនេះ វាបញ្ចេញមកវិញនូវកាកសំណល់ដ៏សំខាន់មួយ ដែលដើរតួនាទីដ៏ចម្បងនៅក្នុងដំណើរវិវត្តន៍នៃភពផែនដីគឺអុកស៊ីសែន។

បន្តិចម្តងៗ នៅក្នុងរយៈពេលប្រមាណជា ២ ពាន់លានឆ្នាំក្រោយមកទៀតទឹកសមុទ្រ ព្រមទាំងខ្យល់ក្នុងបរិយាកាសនៃភពផែនដីរបស់យើងត្រូវគ្របដណ្តប់ទៅដោយអុកស៊ីសែន ម៉ូលេគុលអុកស៊ីសែននៅក្នុងខ្យល់បានធ្វើឱ្យផ្ទៃមេឃត្រូវប្រែពណ៌ទៅជាខៀវ ដូចគ្នាដែរចំពោះផ្ទៃសមុទ្រដែលទទួលពន្លឺពីបរិយាកាស។

## ២. ការវិវត្តនៃយុគសម័យរបស់ជីវិតលើភពផែនដី

កាលពីដំបូងឡើយក្រោយការកកើតភពផែនដី និងការស្គាល់នូវស៊ីតុណ្ហភាពសមស្របដែលអាចទ្រទ្រង់ជីវិតបាននោះ ជីវិតលើភពផែនដីក៏មិនមែនជាជីវិតក្នុងទម្រង់សាំញ៉ាំ ដូចជា មនុស្ស សត្វ ឬរុក្ខជាតិនោះទេ ក៏ប៉ុន្តែជាប្រភេទជីវិតក្នុងទម្រង់ដ៏សាមញ្ញដែលមានកោសិកាទោល គឺប្រភេទបាក់តេរី។ នៅពេលគេនិយាយអំពីជីវិត គេត្រូវនឹកឃើញដល់លក្ខខណ្ឌដ៏ចាំបាច់គឺប្រភពទឹក និងបរិយាកាសដែលសម្បូរទៅដោយអុកស៊ីសែន ហើយទឹកនិងអុកស៊ីសែននេះបានអនុញ្ញាតឱ្យជីវិតអាចវិវត្តទៅជាទម្រង់ផ្សេងៗ ដែលអាចកំណត់អត្តសញ្ញាណបានថាជាជីវិត។

ខាងក្រោមនេះ យើងសូមលើកយកនូវប្រវត្តិនៃការផ្លាស់ប្ដូរយុគសម័យនៃជីវិតនៅលើភពផែនដីនៅប្រមាណ ៥០០ លានឆ្នាំចុងក្រោយ ដែលជាជីវិតអាចមើលឃើញបាន (Visible Life)[9] និងដែលគេធ្វើការបែងចែកជាដំណាក់កាល (ឬស័ក) ធំៗ ចំនួន ៣ ដូចខាងក្រោម៖[10]

- **ដំណាក់កាលទី១"ប៉ាឡេអូសូអ៊ិក"** (Paléozoïque) (៥៤០លាន-២៥០លានឆ្នាំមុន)

ដំណាក់កាល "ប៉ាឡេអូសូអ៊ិក" (Paléozoïque) ឬ ជាភាសាអង់គ្លេស (Paleozoic)[11] គឺជាសម័យកាលភូគព្ភសាស្ត្រ (Geological) ដំបូងបង្អស់ ដែលមាន ៦ សម័យកាល គឺកំប្រ៊ីយាង អរដូវីស្យាង, ស៊ីឡូរ្យាង



ដេវូនីញាង, កាបូនីផែ, និងពែមីញាង។ ដំណាក់កាល «**ប៉ាឡេអូសូអ៊ិក**» មានរយៈពេលរាប់ចាប់ពីការរីកដុះដាលដ៏លឿននៃជីវិត នៅក្រោយយុគ

[9] https://www.earthfacts.com/evolution-and-life/stageslifeearth/

[10] អត្ថបទដកស្រង់ពី វិទ្យុបារាំង RFI

[11] Merriam-Webster

សម័យទឹកកក កាលពីជាង ៥០០លានឆ្នាំមុន (Cambrian explosion) រហូតមកទល់នឹងហេតុការណ៍ស្លាប់រង្គាលផុតពូជសត្វដែលគេហៅថា "Great Permian Extinction" កាលពី២៥០លានឆ្នាំមុន។

ការស្លាប់រង្គាល(Great Perminian Extinction) កាលពី២៥០លានឆ្នាំនោះ បណ្តាលមកពីការកើនឡើងកម្តៅនៃបរិយាកាសផែនដី រួមជាមួយនឹងការប្រែប្រួលនៅក្នុងមហាសាគរ។ នៅចុងក្រោយនៃការស្លាប់រង្គាលនេះ គឺមានការផ្ទុះភ្នំភ្លើង ជាច្រើនដំណាលគ្នា ។

- **ដំណាក់កាលទី២ "មេសូហ្សូអ៊ិក" (Mésozoïque) (៦៦ - ៦៥លានឆ្នាំមុន)**

ដំណាក់កាល "**មេសូហ្សូអ៊ិក**" **(Mésozoïque)** ឬជាភាសាអង់គ្លេស **(Mesozoic)** គឺជាសម័យកាលនៅចន្លោះសម័យភូគព្ភសាស្ត្រ (Geological) គឺនៅប្រមាណ២៥២ ទៅ ៦៦លានឆ្នាំមុន ដែលមានពីរសម័យកាល គឺទ្រីយ៉ាសសូរ៉ាសិុក និងកាលសម័យក្រេតាសេ។



ដំណាក់កាលនេះ ជាសករាជនៃសត្វដាយណូស័រ មានរយៈពេលរាប់ចាប់ពីក្រោយហេតុការណ៍ស្លាប់រង្គាល "Great Permian Extinction" រហូតមកទល់នឹងការស្លាប់ផុតពូជសត្វដាយណូស័រ កាលពីជាង ៦៥ លានឆ្នាំមុន។

- **ដំណាក់កាលទី៣ "សេណូសូអ៊ិក"** (Cénozoïque)

ដំណាក់កាល សេណូសូអ៊ិក (Cénozoïque) ឬភាសាអង់គ្លេស Cenozoic នៅប្រមាណ ៦៦លានឆ្នាំមុន ដែលគេហៅថាជាសម័យ(សត្វល្មូន) និងមានពីរសម័យកាល គឺទែត្យារី និងក្វាទែណារី។

ដំណាក់កាលនេះ មានរយៈពេលរាប់ចាប់ពីក្រោយការស្លាប់ផុតពូជសត្វដាយណូស័រ បន្តរហូតមកទល់នឹងពេលបច្ចុប្បន្ន ហើយនេះគឺជាដំណាក់កាលមួយ ដែលភពផែនដីរបស់យើងស្ថិតក្រោមការត្រួតត្រានៃពពួកថនិកសត្វ។



តាមការពិតទៅ ថនិកសត្វបានចាប់ផ្តើមមានវត្តមាននៅលើភពផែនដីយើងនេះតាំងពីជាង២០០លានឆ្នាំមុនមកម្ល៉េះ ពោលគឺនៅក្នុងអំឡុងពេលប្រហាក់ប្រហែលគ្នានឹងពពួកសត្វដាយណូស័រ ក៏ប៉ុន្តែ ដោយសារតែមានការគម្រាមកំហែងពីសំណាក់ដាយណូស័រ ពពួកថនិកសត្វដើមដំបូងនោះមិនមានឱកាសក្នុងការរីកលូតលាស់ធំធាត់បាននោះទេ។ ថនិកសត្វភាគច្រើននៅពេលនោះមានទំហំប៉ុនសត្វកណ្តុរ ហើយច្រើនតែរស់នៅលាក់ខ្លួននៅតាមកន្លុកកន្លៀត ឬនៅក្រោមដី ដើម្បីគេចចេញពីសត្វឌីណូស័រ។

ក៏ប៉ុន្តែ នៅទីបំផុតទៅ នៅពេលដែលភពផែនដីរបស់យើងត្រូវប្រឈមនឹងគ្រោះមហន្តរាយដ៏ធំដោយការធ្លាក់អាចម៍ផ្កាយ កាលពីជាង៦៥លានឆ្នាំមុន ការណ៍ដែលមានទំហំតូច និងសមត្ថភាពក្នុងការរស់នៅក្រោមដីនេះហើយ ដែលជួយឱ្យពពួកថនិកសត្វមានឱកាសរស់ច្រើនជាងពួកដាយណូស័រ។

នៅក្នុងពេលដែលសត្វដាយណូស័រមួយចំនួនធំត្រូវស្លាប់ដោយ កម្តៅពីហេតុការណ៍ធ្លាក់អាចម៍ផ្កាយ ពពួកថនិកសត្វមួយចំនួនធំបានរួចជីវិត ដោយសារតែពួកគេរស់នៅតាមកន្លុកកន្លៀតនិងនៅក្រោមដី។ ហើយក្រោយមកទៀត នៅពេលដែលឥទ្ធិពលនៃការធ្លាក់អាចម៍ផ្កាយបានធ្វើឱ្យភពផែនដីត្រូវប្រឈមនឹងបញ្ហាអាកាសធាតុ បណ្តាលឱ្យសត្វ និងរុក្ខជាតិមួយផ្នែកធំត្រូវស្លាប់អស់ ហើយស្បៀងអាហារក៏ត្រូវខ្សត់ខ្សោយ ពពួកសត្វដាយណូស័រដែលមានទំហំធំ និងត្រូវការចំណីអាហារច្រើនក៏ត្រូវស្លាប់ជាបន្តបន្ទាប់រហូតដល់ផុតពូជអស់។ ចំណែកពពួកថនិកសត្វវិញ ដែលមានទំហំតូចមិនសូវត្រូវការចំណីអាហារច្រើន

និងថែមទាំងមានទម្លាប់ស៊ីសត្វល្អិត និងគ្រប់អ្វីៗផ្សេងទៀត ដែលគេអាចរកឃើញក្រោមដីផងនោះ ក៏អាចសម្របខ្លួនទៅនឹងបញ្ហាអាកាសធាតុ ហើយអាចឆ្លងផុតពីគ្រោះអត់ឃ្លាន។

នៅប្រមាណជា ៥០លានឆ្នាំមុន ពោលគឺ ១៥លានឆ្នាំក្រោយហេតុការណ៍ធ្លាក់អាចម៍ផ្កាយដែលសម្លាប់សត្វដាយណូស័រ អាកាសធាតុនៅលើភពផែនដីយើងនេះក៏បានវិលត្រឡប់មករកភាពធម្មតាឡើងវិញ។លក្ខខណ្ឌអំណោយផលសម្រាប់ជីវិតក៏កើតមានឡើងវិញ ហើយនៅពេលនោះពពួកសត្វដាយណូស័រក៏ត្រូវស្លាប់ផុតពូជអស់ លែងមានមុខនៅលើភពផែនដីយើង ដើម្បីមកតាមយាយីពពួកថនិកសត្វដូចជាពេលមុនទៀតនោះដែរ។

ចាប់ពីពេលនោះហើយ ដែលពពួកថនិកសត្វចាប់ផ្តើមរីកលូតលាស់ និងរីកសាយភាយទៅស្ទើរតែគ្រប់ទីកន្លែងនៅទូទាំងភពផែនដីយើងទាំងមូល ហើយសករាជថ្មីមួយក៏បានចាប់ផ្តើមឡើង គឺសករាជនៃថនិកសត្វ ដែលនៅបន្តរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។

យុគសម័យ(Geological column) ពេលវេលាគិតជាលានឆ្នាំ




តារាងសង្ខេប ការវិវត្តនៃជីវិតលើភពផែនដី

(តាំងពី២០០០លានឆ្នាំមកដល់បច្ចុប្បន្ន)

# ជំពូកទី៣
# ប្រវត្តិកកើតមនុស្សលើភពផែនដី

## ១- និយមន័យនៃកំណើតមនុស្ស (Genesis)

កាលពីបុរាណកាល នៅពេលដែលមនុស្សចេះរស់នៅក្នុងសហគមន៍ មនុស្សចេះគិតពីរបៀបគ្រប់គ្រងរដ្ឋ ចេះគិតពិចារណា មនុស្សចាប់ផ្តើមចង់ដឹងពីដើមកំណើតរបស់ខ្លួន។ កាលពីជំនាន់នោះ ដោយហេតុថាវិទ្យាសាស្ត្រមិនទាន់ជឿនលឿន មិនទាន់មានបច្ចេកវិទ្យា ឧបករណ៍ទំនើប មនុស្សចេះតែនាំគ្នា ខំគិតស្រមៃទៅតាមគំនិតរៀងៗខ្លួន ។

ចំពោះប្រធានបទ កំណើតផែនដីនិងមនុស្ស អ្នកមានប្រាជ្ញា អ្នកប្រាជ្ញធំៗ អរិយបុគ្គល បានសម្តែងទៅកាន់សាវករបស់ខ្លួន នូវអ្វីដែលខ្លួនបានរកឃើញ បានយល់ឃើញ បានយល់សប្តិ តាមវិធីផ្សេងៗ ឬតាមដែលទេវតាបានចុះមកប្រាប់។ល។ មនុស្សម្នាជំនាន់នោះ ក៏មានជំនឿទៅតាមការពន្យល់ ការណែនាំរបស់អរិយបុគ្គល ដែលគោលបំណងគឺដើម្បីឱ្យមនុស្សប្រព្រឹត្តអំពើល្អ។

នៅក្នុងគ្រិស្តសាសនា ព្រះគម្ពីរបរិសុទ្ធបានថែងថា ព្រះអាទិទេពជាអ្នកបង្កើតចក្រវាល បង្កើតពិភពលោក បង្កើតមេឃនិងផែនដី [12] ។ ព្រះគម្ពីរបានចែងទៀតថាព្រះ «ទ្រង់ក៏បង្កើតមនុស្ស.. » [13] សត្វ រុក្ខជាតិ

[12] ព្រះគម្ពីរបរិសុទ្ធ (Holly Bible, 1:1) លោកុប្បត្តិ ជំពូក១ វាក្យខណ្ឌ១ (ទំព័រទី១)

[13] ព្រះគម្ពីរបរិសុទ្ធ (Holly Bible, 1:27) លោកុប្បត្តិ ជំពូក១ វាក្យខណ្ឌ២៧ (ទំព័រទី២)

...។ «អ័ដាម» ជាមនុស្សទី១ ដែលព្រះបានបង្កើត និងបានបន្តពូជពង្ស រហូតដល់សព្វថ្ងៃ។



មនុស្សទី១នៅលើភពផែនដីបង្កើតដោយព្រះ

រីឯនៅប្រទេសឥណ្ឌាបុរាណ ព្រហ្មញ្ញសាសនា និងសាសនាហិណ្ឌូ គេជឿថា ព្រះព្រហ្ម ព្រះសិវៈ ជាព្រះអាទិទេពធំបំផុត ក្នុងការបង្កើតលោក។ គេមានគម្ពីរវេទ ជាក្បួនច្បាប់ក្នុងការគោរពប្រតិបត្តិ។

សម្រាប់សាសនាអ៊ិស្លាម នៅក្នុងគម្ពីរគួរអាន បានសរសេរថា ព្រះអល់ឡោះ ជាអ្នកបង្កើតដីនិងមេឃ [14]។ ព្រះអល់ឡោះ បានបង្កើត

[14] គម្ពីរគួរអាន ស៊ូរ៉ោះ អាល់ហាករ៉ោះ អាយិត(វាក្យខណ្ឌ)២១ ទំព័រ៤

មនុស្ស [15]។ អំពីកំណាកំណើតមនុស្ស នៅលើភពផែនដី មានសរសេរច្រើនកន្លែងទៀត នៅក្នុងគម្ពីរគួរអាន។

ដូច្នេះ ចំពោះសាសនាធំៗកាលពីបុរាណ គឺជាព្រះអាទិទេពជាអ្នកបង្កើតពិភពលោក និងជីវិត និងដឹកនាំគ្រប់គ្រងពិភពលោក ។

ចំណែកឯព្រះពុទ្ធសាសនាវិញ ជាសាសនាមានដើមកំណើតមកពីប្រទេសឥណ្ឌា តាំងពីជាង២៥០០ឆ្នាំមកម្ល៉េះ។ ព្រះពុទ្ធបានសម្តែងដែរ ដែលមានសរសេរនៅក្នុងគម្ពីរព្រះត្រៃបិដក អំពីការរលាយ និងការកកើតនៃជីវិតផងដែរ [16]។ ព្រះពុទ្ធបានសម្តែងថា ព្រះអង្គមានរូបរាងកាយជាមនុស្សធម្មតា លោកក៏មានការ កើត ចាស់ ឈឺ ស្លាប់ដែរ ហើយលោកមិនបានបង្កើត ផែនដី ឬមនុស្សទេ អ្វីៗកើតឡើងដោយធម្មជាតិ មិនចំណុះពីមនុស្សឡើយ។ ទស្សនៈនេះ ប្រហាក់ប្រហែលទៅនឹងគំនិតអ្នកវិទ្យាសាស្ត្របច្ចុប្បន្នដែរ។

ជារួម សម្រាប់សាសនាគេមិនចាំបាច់គិតច្រើន ពិចារណារកខុសរកត្រូវ ឬក៏ស្រាវជ្រាវច្រើន អំពីកំណើតមនុស្សឬកំណើតភពផែនដីអ្វីទេ អ្វីដែលសំខាន់គឺការជឿ។

## ២. ដំណើរវិវត្តន៍របស់មនុស្សជាតិ

### Human Evolution

[15] គម្ពីរគួរអាន ស៊ូរោះ អាត់តីន៩៥(៣) អាល់អាឡាក្កុ៩៦ អាយិត(វាក្យខណ្ឌ)១ ទំព័រ៥៩៧

[16] គម្ពីរព្រះត្រៃបិដក សុត្តន្តបិដក ភាគទី១៨ ទំព័រ១៧១ ១៧២-១៧៣

ការសិក្សាការវិវត្តនៃមនុស្សជាតិ គេខិតខំតាមដានរកមើលអំពីឧបករណ៍នានាដែលមនុស្សបានប្រើប្រាស់កន្លងមក ដោយកាលនោះមនុស្សពីបូរាណ ចេះរើសយកចេញពីធម្មជាតិដែលនៅជិតខ្លួនយកមកប្រើប្រាស់ យកមកកែឆ្នៃទៅតាមការតម្រូវការរបស់ខ្លួន។ ពេលវេលានៃដំណាក់កាលប្រវត្តិរបស់មនុស្សបែងចែកទៅតាមយុគសម័យ (Timeline of the Periods in history)៖

- យុគថ្ម (Stone Age: ៣,៣ លានឆ្នាំ ដល់ ~ ៥.000 ឆ្នាំ)

- យុគលង្ហិន( Bronze Age: ៥.000 ឆ្នាំ ~ ១.៥00 ឆ្នាំ គឺ១.២00ឆ្នាំមុនគ្រិស្តសករាជ)

- យុគដែក (Iron Age: ១.២00 មុនគ.ស.~ ៥00ឆ្នាំ មុន គ.ស.)

- យុគក្លាស៊ីក (Classical Era: ៥00ឆ្នាំ មុន គ.ស.ដល់៥00ឆ្នាំក្រោយ គ.ស.)

## ២.១. មនុស្សប្រភេទស្វាធំៗដំបូង

តាមអ្នកវិទ្យាសាស្ត្រដែលបានសិក្សាពីប្រវត្តិនៃមនុស្ស បានផ្តល់យោបល់ថា ក្រុមស្វាធំៗមានបីប្រភេទ គឺកូរី អូរ៉ង់អ៊ូតង់ និងជីមប៉ាន់ជី ជាប្រភេទដើមបំផុតនៃមនុស្សបច្ចុប្បន្ន មានន័យថាប្រភេទស្វាធំៗ និងមនុស្សមានដើមកំណើតរួមគ្នា។



ផ្អែកលើការវិភាគរូបធាតុ ADN អ្នកវិទ្យាសាស្ត្របានគិតថា ស្វាជីមប៉ាន់ស៊ី (chimpanzee monkey) ជាប្រភេទដើមបំផុតនៃមនុស្ស ហើយមនុស្សនិងស្វាជីមប៉ានស៊ី បានបំបែកគ្នាចេញពីបុព្វបទរួមក្រោយ ៦,៥០០,០០០ឆ្នាំមុន។ មនុស្សនិងសត្វស្វាប្រភេទធំ មានបុព្វជនតែមួយ (common ancestor) ដែលបានរស់នៅ ប្រមាណពី៨ទៅ៦លានឆ្នាំមុន ហើយមានវត្តមាននិងការវិវត្តនៅទ្វីបអាហ្វ្រិក។

សំណល់ផូស៊ីលមនុស្សប្រភេទស្វាធំ ត្រូវបានគេរកឃើញនៅឆ្នាំ ២០០០ នៅក្នុងប្រទេសកេនយ៉ា (អាហ្វ្រិកខាងកើត) ដែលតាមការវិភាគមានអាយុប្រហែល៦លានឆ្នាំមុន។ តាមការសិក្សាស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របាននិយាយថា កំណើតមនុស្សគឺនៅតែថ្មី បើប្រៀបធៀបទៅនឹងជីវិតសត្វនានា និងទៅប្រវត្តិនៃផែនដី។




The hominoids are descendants of a common ancestor

ចំពោះដំណើររឿងរបស់មនុស្សយើង បានចាប់ផ្តើមឡើងតាំងពីយូរយារណាស់មកហើយ គឺមុនប្រវត្តិជាសំណេរ ដែលយើងតែងតែហៅថាជាសម័យកាលបុរេប្រវត្តិ។ មុនពេលមានការបង្កើតជាអក្សរ ឬសំណេរ ដើម្បីសិក្សាស្វែងយល់ពីដំណើររឿងរបស់មនុស្ស គេបានសិក្សាតាមរយៈដូចជា ឆ្អឹង ឧបករណ៍ប្រើប្រាស់ ឬរូបគំនូរ ជាដើម ដែលគេរកឃើញតាមរយៈកំណាយបុរាណវិទ្យា។

ការប្រើប្រាស់ឧបករណ៍របស់មនុស្សជំនាន់នោះ ត្រូវបានបកស្រាយថាជាសញ្ញានៃភាពវៃឆ្លាត ហើយត្រូវបានគេសន្និដ្ឋានថាការប្រើប្រាស់ឧបករណ៍ គឺអាចជួយជំរុញសភាពការណ៍មួយចំនួននៃការវិវត្តរបស់មនុស្ស ជាពិសេស ការបន្តពង្រីកសមត្ថភាពខួរក្បាល សតិប្រាជ្ញារបស់មនុស្ស។



តាមការសិក្សាស្រាវជ្រាវបានបង្ហាញថា វត្តមានរបស់មនុស្ស ដែលមានសណ្ឋានស្ទើរតែពេញលេញនៅលើភពផែនដីតាំងពីប្រមាណជា ២០ម៉ឺនឆ្នាំមុនមកម្ល៉េះ[17] នេះជាការចាកចេញពីពពួកថនិកសត្វមួយក្រុម ដែលគេឱ្យឈ្មោះថា "**វានរជាតិ**" (Primate) បន្ទាប់ពីបានឆ្លងកាត់នូវដំណើរវិវឌ្ឍដ៏យឺតៗក្នុងរយៈពេលរហូតដល់ទៅរាប់លានឆ្នាំ រហូតដល់អាចចេះដើរជើងពីរ ចេះប្រើឧបករណ៍ និងចេះប្រើភ្លើង។ ក៏ប៉ុន្តែ បើទោះបីជាយ៉ាងនេះក៏ដោយ ពពួកវានរជាតិទាំងនោះ មិនត្រូវបានគេចាត់ទុកថាជាមនុស្ស ដែលស្ថិតនៅក្នុងតំណពូជមនុស្សជាតិយើងបច្ចុប្បន្ននេះនោះទេ។

[17] អត្ថបទរបស់ **សេង ឌីណា** ចុះផ្សាយថ្ងៃទី២៧ មករា ២០១៩



### ២.២ មនុស្សមុនអំបូរសាព្យាង

នៅពេលមនុស្សបច្ចុប្បន្នកំពុងរាលដាលលើពិភពលោក គេឃើញមានមនុស្សយុគដំបូងមានជីវិតរស់នៅខ្លះៗដែរ។ ពួកគេត្រូវបានហៅថាក្រុមប៉ាលេអូតង់ត្រូពិក និងក្រុមអាកសង់ត្រូពិក ហើយក្រុមនីមួយៗមានការរីកចម្រើនតាំងពី ១,៦០០,០០០ ទៅ ២៥០,០០០ ឆ្នាំមុន។ ហើយវារីករាលដាលពីអាហ្វ្រិក ទៅអាស៊ី និងផ្នែកខ្លះនៅអឺរ៉ុប។

### ២.៣ មនុស្សបច្ចុប្បន្ន អូម៉ូសាព្យៀង (Homo Sapiens)

អូម៉ូសាព្យាង ជាអំបូរមនុស្សបច្ចុប្បន្នមានដូចជាជនជាតិ អាហ្វ្រិក អឺរ៉ុប អាស៊ី អាមេរិកាំង ដែលស្ថិតនៅក្នុងប្រភេទតែមួយ។ វាកើតឡើងប្រហែល ២៥ម៉ឺនឆ្នាំមុន និងចាប់ផ្តើមមានភាសានិយាយប្រមាណជា ៥ម៉ឺនឆ្នាំ ។ បន្ទាប់មក ក៏មានដំណើរ បម្លាស់ទីចូលអឺរ៉ុប និងអាស៊ី ចាប់ផ្តើមនៅចន្លោះ ៧០,០០០ ទៅ ៥០,០០០ ឆ្នាំមុន។

អំបូរ «**អូម៉ូសាព្យាង**» ពោលគឺ មនុស្សជាតិយើង ដែលដើមដំបូងបានចាប់ផ្តើមលេចមុខឡើង កាលពីប្រមាណជា ២០ម៉ឺនឆ្នាំមុន នៅក្នុងតំបន់អាហ្រ្វិក មុននឹងរីកសាយភាយទៅកាន់តំបន់ផ្សេងៗទៀត។ លក្ខណៈដ៏ពិសេសរបស់អូម៉ូសាព្យាង គឺការចេះប្រើភាសាដែលមានលក្ខណៈជឿនលឿន ហើយដែលអាចនិយាយទាក់ទងគ្នា ចែករំលែកព័ត៌មាន និងបទពិសោធន៍ដល់គ្នាទៅវិញទៅមកបាន។

ឯកសារខ្លះបានបញ្ជាក់ថា មនុស្សជាតិ បានចាប់កំណើតឡើងដំបូងនៅតំបន់អាហ្រ្វិកខាងកើត កាលពីប្រមាណ១២,០០០ឆ្នាំមុន[18] និងបានរីកសាយទៅស្ទើរតែគ្រប់ទីកន្លែងនៅទូទាំងភពផែនដី។ នៅរយៈពេលក្រោយៗមកទៀត មនុស្សបានធ្វើបម្លាស់ទីដោយថ្មើរជើងពីតំបន់អាស៊ីទៅទឹកដីអាម៉េរិក តាមរយៈការឆ្លងកាត់ផ្ទាំងទឹកកក ដែលគ្របដណ្តប់លើផ្ទៃផែនដី ជាពិសេស មានការឆ្លងកាត់តាមរយៈទឹកដីរវាងរដ្ឋអាឡាស្កា (Alaska) សហរដ្ឋអាម៉េរិក និងទឹកដីប្រទេសរុស្ស៊ី និងបានរីកសាយភាយនៅទូទាំងពិភពលោក។

អ្នកស្រាវជ្រាវបានអះអាងថា ការវិវត្តរបស់មនុស្សបានពន្លឿនចាប់តាំងពីការអភិវឌ្ឍកសិកម្មកាលពី ១០,០០០ ឆ្នាំមុន និងអរិយធម៌កាលពី ៥,០០០ឆ្នាំមុន។ នេះជាលទ្ធផលត្រូវបានគេអះអាងអំពីការសិក្សានូវភាពខុសគ្នានៃហ្សែនជាច្រើននៃមនុស្សបច្ចុប្បន្ន ហើយការស្រាវជ្រាវថ្មីៗបន្ថែមទៀតបង្ហាញថា សម្រាប់លក្ខណៈខុសគ្នាមួយចំនួន បណ្តាលមកពីការវិវឌ្ឍនិងការនិវានុវត្តនៃវប្បធម៌របស់មនុស្ស ក្នុងករណីខ្លះបានត្រូវ

---

[18] អត្ថបទលោក **សេង ឌីណា** វិទ្យុបារាំង RFI

ផ្លាស់ប្តូរយ៉ាងទូលំទូលាយទៅជាទម្រង់ថ្មី ដោយសារត្រូវសម្របសម្រួលទៅតាមលក្ខខណ្ឌជាមួយធម្មជាតិដែលខ្លួនត្រូវរស់នៅ។




កាលពីដំបូងឡើយ មនុស្សចេះមានគំនិតប្រើថ្ម ឈើ (**យុគថ្មបំបែក**) ការបរិភោគសាច់ឆៅជាអាហារ ក្រោយមកទៀត មនុស្សបានវិវត្តន៍មកចេះប្រើភ្លើងដើម្បីចម្អិនអាហារ ហើយចេះរកទីតាំង ឬតំបន់ដែលមានទឹក ព្រៃ ដងទន្លេ ស្ទឹង បឹងបួរ ដើម្បីបំពេញការរស់នៅប្រចាំថ្ងៃ។

ដោយសារការកកើតច្រើន និងតម្រូវការប្រចាំថ្ងៃរបស់មនុស្សក្នុងយុគសម័យនោះចេះតែមានការកើនឡើង ដែលជាហេតុនាំឱ្យមនុស្សបានបង្កើតរបៀបរបបរស់នៅដ៏ថ្មីស្រឡាងមួយគឺ (**បដិវត្តន៍ថ្មរំលីង**)[19] ដែលរុក្ខជាតិជារបរកសិកម្ម ដោយចេះយកគ្រាប់ធញ្ញជាតិមកដាំដុះ និងយក

[19] រកឃើញដោយលោក **ចន ឡូបប៊ុក** (John Lubbock) នៅឆ្នាំ១៨៦៥

សត្វមកចិញ្ចឹមធ្វើជាអាហារជំនួសឱ្យការបរបាញ់ ឬកាប់ព្រៃវិញ ដែលជាហេតុធ្វើឱ្យមនុស្សកាន់តែមានការវិវត្តពីមួយថ្ងៃទៅមួយថ្ងៃ។

## ការវិវត្តផ្លាស់ប្តូររូបរាងនៃមនុស្ស



Homo habilis

2,5 លាន -2,0 លានឆ្នាំ



Homo Erectus

1,9 លាន -0,5 លានឆ្នាំ



Homo heidelbergensis

0,8 លាន -0,3 លានឆ្នាំ



Homo Neanderthals

300ពាន់ឆ្នាំ-130ពាន់ឆ្នាំ



50ពាន់ឆ្នាំ-25ពាន់ឆ្នាំ



ក្រោយ25ពាន់ឆ្នាំ

រយៈពេលនិងការប្រែប្រួលរូបរាងរបស់មនុស្ស (Hominin timeline) បានត្រូវគេធ្វើតារាងសង្ខេបដូចតទៅ ៖



# ជំពូកទី៤
# ការកកើតរដ្ឋបុរេប្រវត្តិកាល

## ១- ការកកើតរដ្ឋដំបូង

ការកើនឡើងនៃចំនួនមនុស្សនេះហើយបានធ្វើឱ្យមនុស្សចេះបង្កើតរបៀបរស់នៅ ការគ្រប់គ្រងសហគមន៍ ដែលបានក្លាយជាប្រវត្តិរបស់មនុស្ស (គឺការបង្កើតរដ្ឋ) ដែលដំបូងបង្អស់នៅកើតនៅប្រទេស **អេហ្សីប** នៅជាប់ដងទន្លេនីល។

ការបែងចែករដ្ឋដំបូង គឺដោយសារកត្តា២៖

**កត្តាទី១.** ការបែងចែកទឹកប្រើប្រាស់ក្នុងរបរកសិកម្ម ព្រោះអេហ្សីបជាប្រទេសកម្រមានភ្លៀងធ្លាក់ និងពឹងផ្អែកទាំងស្រុងលើ ទឹកលើដីនិងក្នុងដី ដើម្បីយកមកប្រើប្រាស់ដែលនាំឱ្យមានជម្លោះដណ្តើមទឹកដីគ្នា ជម្លោះនេះបានធ្វើឱ្យមនុស្សចេះចាត់ឱ្យមានមេដឹកនាំ ដើម្បីចាត់ចែងទឹកទាំងនោះ។

**កត្តាទី២.** ការបង្កើតរដ្ឋ តម្រូវការសន្តិសុខ ការការពារពីការលុកលុយលួចផលកសិកម្មរបស់ពួកគេ ដូចនេះហើយ មនុស្សក៏មានគំនិតឱ្យសហគមន៍របស់ពួកគេមានអ្នកដឹកនាំ ហើយបានបែងចែកផលរបស់ពួកគេម្នាក់បន្តិចៗ ដើម្បីផ្គត់ផ្គង់រដ្ឋសម្រាប់ការពារ (ហៅថាការបង់ពន្ធជូនរដ្ឋ)។

រដ្ឋដែលបានយកពន្ធពីប្រជាកសិករ គឺត្រូវមានកាតព្វកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសការពារភោគផលកសិកម្មរបស់ប្រជាពលរដ្ឋ ដែលសកម្មភាពអស់ទាំងនេះបានបន្តជាទម្លាប់ និងបានអនុវត្តរហូតមកទល់នឹងពេលបច្ចុប្បន្ន។

រហូតមកទល់នឹងបច្ចុប្បន្ននេះ វត្តមានរបស់មនុស្សបានរីកសាយភាយនៅទូទាំងពិភពលោក ដោយបែងចែកជារដ្ឋផ្សេងៗដាច់ពីគ្នា ខ្លះតូច ខ្លះធំ ដោយមានមនុស្សសរុបចំនួនជាង ៧,៥៣ ពាន់លាននាក់ នៅទូទាំងពិភពលោក (គិតត្រឹម ឆ្នាំ២០១៩)។[20] ចំនួនមនុស្សចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយតម្រូវការក៏ចេះតែកើនឡើងដែលនាំឱ្យមនុស្សចេះរកវិធីសាស្ត្រក្នុងការរកទទួលទានសម្រាប់បំពេញតម្រូវការទាំងនោះ។

## ២. អរិយធម៌ និងសង្គម

អស់រយៈពេលជាច្រើនសតវត្សមកហើយដែលការប្រែមុខមាត់ និងភាពរីកចម្រើនដែលកើតចេញពីគំនិតប្រាជ្ញារបស់មនុស្សជាតិពីជំនាន់មួយទៅជំនាន់មួយ ដែលឈានដល់ការបង្កើតជាអរិយធម៌ដ៏រុងរឿងបំផុតក្នុងសម័យអតីតកាល។

ដូចដែលអ្នកសិក្សាភាគច្រើនបានដឹងហើយថា នៅក្នុងដំណើរវិវត្តន៍នៃមនុស្សជាតិអរិយធម៌ និងសង្គម ដែលមានវ័យចំណាស់បំផុតនោះ គឺមាន **អេហ្ស៊ីប មេសូប៉ូតាមី ឥណ្ឌា** និង**ចិន**។ សម័យកាលនេះ គឺជាសម័យកាលដែលរដ្ឋបានចាប់កំណើតឡើង ដោយសារតម្រូវការចាំបាច់របស់ប្រជាកសិករ នៅក្រោយបដិវត្តន៍កសិកម្ម និងជាអរិយធម៌ដែលបានបន្សល់ទុកនូវរបកគំហើញសំខាន់ៗជាច្រើនទុកជាកេរមរតក សម្រាប់មនុស្សជាតិប្រើប្រាស់រហូតមកទល់នឹងសព្វថ្ងៃ។

ការកត់សម្គាល់នៃភាពរីកចម្រើន ក្នុងសម័យ **អេហ្ស៊ីប មេសូប៉ូតាមី ឥណ្ឌា** និង**ចិន** ប្រមាណជា ១ម៉ឺនឆ្នាំមុន រួមមាន៖

---

[20] worldometers.info/world-population

- មនុស្សចាប់ផ្តើមចេះធ្វើកសិកម្ម ដើម្បីចិញ្ចឹមជីវិតជំនួសឱ្យការបរបាញ់។
- ការតម្រូវឱ្យមានអ្នកដឹកនាំ និងរចនាសម្ព័ន្ធសហគមន៍ត្រឹមត្រូវដែលជាទម្រង់ដំបូងនៃរដ្ឋ ដើម្បីចាត់ចែងបែងចែកធនធានទឹកឱ្យបានស្មើភាពគ្នាសម្រាប់ប្រកបរបរកសិកម្ម និងរក្សាសណ្តាប់ធ្នាប់ និងការពារសុវត្ថិភាពរបស់ប្រជាកសិករ។
- ការចេះកែច្នៃឧបករណ៍ ប្រើប្រាស់សត្វសម្រាប់ប្រើប្រាស់បម្រើដល់ការប្រកបរបកសិកម្ម ។ល។

សង្គម និងអរិយធម៌បានចាប់កំណើតដំបូងគេគឺនៅតាមតំបន់ដែលមនុស្សចាប់ផ្តើមបង្កើតរបរកសិកម្ម រួមមាន ៤ សំខាន់ៗ៖[21]

- **អេហ្ស៊ីប** ជាប់នឹងទន្លេនីល
- **មេសូប៉ូតាមី** ជាប់នឹងដងទន្លេអឺប្រាត និងទន្លេទីគ្រីស
- **ឥណ្ឌា** ជាប់នឹងដងទន្លេឥណ្ឌុស
- **ចិន** ជាប់នឹងដងទន្លេលឿង។

ក្រោយពីការបង្កើតរដ្ឋនោះ «**អក្សរ**» ក៏ត្រូវបានគេបង្កើតឡើងនិងចាត់ទុកថាជាដែនកំណត់បញ្ចាក់ពីសម័យកាលបុរេប្រវត្តិ ឈានចូលក្នុងសម័យកាលប្រវត្តិសាស្ត្រផងដែរ។ ប៉ុន្តែ នៅកន្លែងណាដែលមិនទាន់មានការបង្កើតអក្សរ មនុស្សបន្តរស់នៅក្នុងសម័យកាលបុរេប្រវត្តិដដែល ហើយនៅកន្លែងផ្សេងទៀតដែលមានការបង្កើតអក្សរ មនុស្សចាប់ផ្តើមបោះជំហានចូលក្នុងសម័យកាលនៃប្រវត្តិសាស្ត្រ។ នៅអេហ្ស៊ីប មនុស្ស

---

[21] អត្ថបទដោយ **សេង ឌីណា** វិទ្យុបារាំង RFI ចុះផ្សាយ 23/06/2013

ចាប់ផ្តើមបង្កើតអក្សរ នៅប្រមាណជា ៣,០០០ ទៅ៤,០០០ឆ្នាំមុនគ.ស.ឬ (៥ ទៅ ៦ ពាន់ឆ្នាំមុនសម័យកាលបច្ចុប្បន្ន) ហើយទម្រង់រដ្ឋដំបូងបង្អស់ក្នុងប្រវត្តិមនុស្សជាតិ គឺបានចាប់កំណើតឡើងនៅ **អេហ្ស៊ីប** នេះឯង។

អេហ្ស៊ីបនៅក្នុងសម័យកាលនោះ គឺជាអាណាចក្រមួយដែលមានប្រជាជនច្រើន គឺប្រមាណពី ៧ ទៅ ៨លាននាក់ ហើយអាណាចក្រអេហ្ស៊ីបបានស្គាល់នូវភាពរុងរឿង និងឯករាជ្យអស់រយៈពេលប្រមាណ ២៥ សតវត្សរ៍ដែលមានការសាងសង់ពីរ៉ាមីតជាច្រើនបន្សល់ទុកជាអច្ឆរិយវត្ថុរបស់មនុស្សជាតិរហូតមកទល់នឹងពេលបច្ចុប្បន្ន។



បន្ទាប់ពីអេហ្ស៊ីប រចនាសម្ព័ន្ធរដ្ឋក៏បានចាប់ផ្តើមចេញជារូបរាងឡើងដែរ នៅមេសូប៉ូតាមី (អ៊ីរ៉ាក់បច្ចុប្បន្ន)។ នៅតាមដងទន្លេអឺប្រ៉ាត និងទីហ្គ្រីស គេឃើញមានអាណាចក្រជាច្រើនបានចាប់កំណើតឡើងជាបន្តបន្ទាប់ ដែលក្នុងនោះ អាណាចក្រមួយ ដែលត្រូវបានគេស្គាល់ទូទៅច្រើនជាងគេ គឺ**បាប៊ីឡូន**។ អាណាចក្របាប៊ីឡូន មានរាជធានី នៅក្បែររដ្ឋធានីបាកដាដរបស់អ៊ីរ៉ាក់នាពេលបច្ចុប្បន្ន ហើយអាណាចក្របាប៊ីឡូនសម័យបុរាណ មានមហាក្សត្រមួយអង្គ គឺព្រះចៅហាមូរ៉ាប៊ី (Hammourabi) ដែលមានឈ្មោះល្បីក្នុងការយកមាត្រាច្បាប់មកចងក្រងធ្វើជាក្រមច្បាប់ដ៏ពេញលេញមួយ ដែលគេស្គាល់ជាទូទៅថាជា "ក្រមហាមូរ៉ាប៊ី" បង្កើតឡើង តាំងពីប្រមាណជា ១៧៥០ឆ្នាំមុនគ.ស. ហើយជាក្រមច្បាប់ដ៏ពេញលេញដំបូង

គេបង្អស់នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។[22] ប៉ុន្តែកាលពីសម័យដើម អេហ្ស៊ីប និងមេសូប៉ូតាមី ដែលមានព្រំប្រទល់ដែនជាប់គ្នា នៅប៉ាឡេស្ទីន គឺជាគូប្រជែងនឹងគ្នាយ៉ាងស្រួចស្រាវ។

នៅប្រមាណ ១៥០ឆ្នាំក្រោយមក ទើបរដ្ឋចាប់កំណើតនៅ **ឥណ្ឌា** និង**ចិន** ហើយខុសពីអេហ្ស៊ីប និងមេសូប៉ូតាមី (Mesopotamia) ដែលតំបន់ជុំវិញដងទន្លេឥណ្ឌុស និងទន្លេលឿង គឺជាតំបន់ដែលសម្បូរភ្លៀង។ ហេតុដូច្នេះហើយបានជាដំណើរវិវឌ្ឍ ឆ្ពោះទៅការបង្កើតរដ្ឋ នៅឥណ្ឌា និងចិន បានធ្វើឡើងដោយសន្សឹមៗ ដោយសារតែ មនុស្សនៅក្នុងតំបន់នេះ មិនសូវជាមានតម្រូវការចាំបាច់ និងបន្ទាន់ខ្លាំង ក្នុងការបង្កើតជារចនាសម្ព័ន្ធរដ្ឋ ដើម្បីគ្រប់គ្រងបែងចែកធនធានទឹកដូចជា នៅអេហ្ស៊ីប និងមេសូប៉ូតាមី នោះទេ។

១,០០០ ឆ្នាំមុនគ.ស. (ជាង ៣,០០០ឆ្នាំ មុនសម័យកាលយើងបច្ចុប្បន្ន) អរិយធម៌ចំនួន ៤ បានចាប់កំណើតនៅលើភពផែនដី៖ អេហ្ស៊ីប មេសូប៉ូតាមី ឥណ្ឌា និងចិន ដោយមួយៗ មានប្រជាជនសរុបប្រមាណជា ១០ លាននាក់ ហើយមានទំនាក់ទំនងជាមួយគ្នាច្រើន ទាំងការធ្វើសង្គ្រាម និងការជួញដូរ។

ដូចនេះ សម័យ អេហ្ស៊ីប មេសូប៉ូតាមី ឥណ្ឌា ចិន នេះហើយ ដែលជាសម័យអរិយធម៌ដំបូងបង្អស់នៃមនុស្សជាតិ និងជាទីកន្លែងចាប់កំណើតនៃកសិកម្ម របៀបរស់នៅ ការច្នៃប្រឌិត និងរបកគំហើញមួយចំនួន ដូចជា ត្រីវិស័យ រំសេវផ្ទុះ ក្រមច្បាប់ ជាដើម គឺសុទ្ធសឹងជាមរតក ដែលបន្សល់

[22] អត្ថបទដោយ **សេង ឱណា** វិទ្យុបារាំង RFI ចុះផ្សាយ 23/06/2013

ទុកដោយអរិយធម៌ដ៏ចំណាស់ទាំង ៤ នេះ ឱ្យមនុស្សជាតិយើងបន្តប្រើប្រាស់ រហូតមកទល់នឹងពេលបច្ចុប្បន្ន។

## ៣. សេចក្តីត្រូវការរបស់មនុស្ស

បន្តពីទស្សនទាននៃការកកើតរដ្ឋ យើងត្រូវដឹងពីមូលហេតុគោល និងសេចក្តីត្រូវការរបស់មនុស្សនៅក្នុងធម្មជាតិ ដែលធ្វើឱ្យមានសមិទ្ធផលនានាមកដល់ពេលបច្ចុប្បន្ន។

បើយើងនិយាយដល់សេចក្តីត្រូវការរបស់មនុស្ស យើងតែងតែនឹកឃើញដល់តម្រូវការចម្បងរបស់មនុស្ស នោះគឺ៖ ចំណីអាហារ សម្លៀកបំពាក់ និងទីជម្រក។ មនុស្សត្រូវការចំណីអាហារដើម្បីអាចរស់រានបាន បើគ្មានចំណីអាហារទេមនុស្សមិនអាចរស់បានឡើយ។ បន្ទាប់ពីអាចរស់បានហើយ មនុស្សត្រូវការយុត្តិធម៌ សន្តិសុខខាងរូបរាងកាយ និងសេរីភាពផ្ទាល់ខ្លួនដែលជាតម្រូវការបន្ទាប់។ ដូចនេះ ចំណីអាហារ សម្លៀកបំពាក់ ទីជម្រក សេរីភាព និងយុត្តិធម៌សង្គម គឺជារឿងដែលមនុស្សគ្រប់ជាតិសាសន៍ត្រូវការដោយខានមិនបាននៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។



តាមទ្រឹស្តីលោក Maslow (Abraham Harold Maslow) អ្នកប្រាជ្ញចិត្តវិទ្យា ជនជាតិអាមេរិក ជាដំបូងមនុស្សត្រូវការអាហារ ទឹក ខ្យល់ និងទីជម្រក សម្រាប់ទ្រទ្រង់ជីវិត (ហៅថា តម្រូវការផ្នែកសរីរៈ)។ បន្ទាប់មកទើបមនុស្សត្រូវការសុវត្ថិភាពរួចផុតពីការគំរាមកំហែងពីមជ្ឈដ្ឋានខាងក្រៅ គឺសុវត្ថិភាពផ្ទាល់ខ្លួន សុខភាព ឬសុវត្ថិភាពផ្នែកហិរញ្ញវត្ថុ (ហៅថា តម្រូវការសុវត្ថិភាព)។

ដំណាក់កាលបន្ទាប់មនុស្សត្រូវការមានមិត្តភក្តិ ស្នេហា និងគ្រួសារជាសង្គមមនុស្ស (ហៅថា តម្រូវការសង្គម)។

ប្រសិនបើតម្រូវការកម្រិតទី៣ នេះត្រូវបានបំពេញរួចហើយមនុស្សចាប់ផ្តើមត្រូវការជាបន្តទៀត ឱ្យគេគោរពកោតសរសើរ (ហៅថា តម្រូវការសេចក្តីគោរព)។

ជាចុងក្រោយ តម្រូវការកម្រិតខ្ពស់បំផុតរបស់មនុស្ស គឺតម្រូវការសេចក្តីពិតចំពោះខ្លួនឯង មនុស្សចង់ធ្វើអ្វីដែលខ្លួនចង់បានពិតប្រាកដក្នុងឆាកជីវិត ចង់ក្លាយជាបុគ្គលដែលខ្លួនប្រាថ្នាចង់បាន ដោយប្រើប្រាស់ឱ្យអស់នូវសក្តានុពលនិងសមត្ថភាព។

ជារួម តម្រូវការរបស់មនុស្សមាន ៥ សំខាន់ៗ៖

- **តម្រូវការទី១** ៖ ហូបចុក ស្លៀកពាក់ ជម្រកនិងថ្នាំសង្កូវ
- **តម្រូវការទី២** ៖ សន្តិសុខ ពោលគឺការថែរក្សា ការពារ សន្តិសុខ សុវត្ថិភាព
- **តម្រូវការទី៣** ៖ សង្គម ពោលគឺ ទំនាក់ទំនង គ្រួសារ សេចក្តីស្រឡាញ់ របស់ជាកម្មសិទ្ធិ

• **តម្រូវការទី៤** ៖ កិត្តិនាម ពោលគឺ តំណែង កេរ្តិ៍ឈ្មោះ កិត្តិយស ការសម្រេចជោគជ័យ

• **តម្រូវការទី៥** ៖ ការអភិវឌ្ឍនិងការពេញចិត្ត ពោលគឺមនុស្សត្រូវការអភិវឌ្ឍខ្លួននិងពេញចិត្តនូវជីវិតដែលខ្លួនមាន។

នៅតាមវិទ្យាស្ថានស្រាវជ្រាវនិងស្ថាប័ននានា មានការសិក្សាអំពីតម្រូវការរបស់មនុស្សជាបន្តនិងមានរបកគំហើញនានាជាច្រើន ដែលបានបោះពុម្ពផ្សាយជាសាកល។

ដោយឡែកពាក់ព័ន្ធនឹងការបង្កើតរដ្ឋ មានការជជែកវែកញែកនិងការសិក្សាអំពីទ្រឹស្តីផ្សេងៗ រដ្ឋមានលក្ខណៈសំខាន់នៅសម្រាប់វិស័យដូចជានរវិទ្យា សង្គមវិទ្យា សេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយ។ ក្របខណ្ឌលេចធ្លោនៃការបង្កើតរដ្ឋ សំដៅឧត្តមភាពរបស់រដ្ឋជាអង្គការសម្រាប់ធ្វើសង្គ្រាមនិងទាញយកធនធាន(ភោគទ្រព្យ)។ ទ្រឹស្តីលេចធ្លោក្នុងការបង្កើតរដ្ឋ កាលពីមជ្ឈិមសម័យ សម័យបន្ទាប់ និងសម័យទំនើប សង្កត់ធ្ងន់លើតួនាទីនៃការធ្វើសង្គ្រាម ធ្វើពាណិជ្ជកម្ម ឬធ្វើកិច្ចសន្យាសំខាន់ៗ និងការផ្សព្វផ្សាយវប្បធម៌ ដើម្បីរៀបចំរដ្ឋឱ្យទៅជាទម្រង់ស្ថាប័នគ្រប់គ្រងរឹងមាំមួយ។

# ជំពូកទី៥
# អាណាចក្រធំនិងជម្លោះដណ្តើមអំណាច

## ១. ប្រវត្តិនៃអាណាចក្រធំៗ

### ១.១. អាណាចក្ររ៉ូម (២៧ឆ្នាំមុនគ.ស.ដល់ ឆ្នាំ៣៩៥)



ឆ្នាំ២៧ មុនគ.ស. (២០៤០ឆ្នាំមុនសម័យកាលបច្ចុប្បន្ន) រ៉ូមបានបោះបង់របបដឹកនាំបែបសាធារណរដ្ឋ ដែលមានតុល្យភាពអំណាច រវាងព្រឹទ្ធសភានិងកុងស៊ុល ដោយងាកមកចាប់យករបៀបដឹកនាំបែបចក្រភព ដែលអំណាចទាំងអស់ត្រូវប្រមូលផ្តុំនៅលើមនុស្សតែម្នាក់ គឺ អធិរាជ។ អធិរាជដំបូងបង្អស់នៃចក្រភពរ៉ូម មានឈ្មោះថា អូហ្គូស (Auguste) ឬតាមថាឡាតាំង Augustus។ នៅក្នុងរយៈពេល ៥៦ឆ្នាំដែលលោកកាន់អំណាចអធិរាជនេះបានស្តារប្រទេសជាតិឡើងវិញឱ្យចេញពីភាពប្រេះឆានៃវិវាទផ្ទៃក្នុង ដែលបានអូសបន្លាយពេលអស់រយៈពេលប្រមាណជា ១សតវត្សរ៍កន្លងទៅ ហើយដឹកនាំចក្រភពរ៉ូម ឆ្ពោះទៅរកសុខសន្តិភាព និងវិបុលភាព។

អធិរាជ អូហ្គូស ក៏បានបង្កើតស្នាដៃជាប្រវត្តិសាស្ត្រ ដោយបានកែទម្រង់កែទម្រង់រចនាសម្ព័ន្ធកងទ័ព ដោយរៀបចំឱ្យមានទាហានក្រោមការដឹកនាំរបស់អធិរាជអូហ្គូស និងអធិរាជក្រោយៗមកទៀត និងបានទទួលជ័យជម្នះនៅស្ទើរតែគ្រប់សមរភូមិ ហើយច្បាំងវាតទីពង្រីកទឹកដីរបស់ខ្លួន

ចាប់តាំងពីអង់គ្លេសនិងតំបន់អឺរ៉ុប មកដល់តំបន់ជុំវិញសមុទ្រមេឌីទែរ៉ាណេ ហើយចាក់ចុះទៅទិសខាងកើត រហូតទៅដល់អ៊ីរ៉ាក់បច្ចុប្បន្ន។

ប៉ុន្តែនៅដើមសតវត្សរ៍ទី៥ អាណាចក្ររ៉ូមក៏ចាប់ផ្តើមបាត់បង់ទឹកដីបន្តិចម្តងៗទៅក្នុងដៃពួកកុលសម្ព័ន្ធ ដោយចាប់ផ្តើមពីទឹកដីអង់គ្លេស នៅអំឡុងឆ្នាំ៤១០នៃគ.ស. អេស្ប៉ាញ និងអាហ្វ្រិកខាងជើង នៅឆ្នាំ៤៣០ ហ្គោល (បារាំង) នៅឆ្នាំ៤៥០ ហើយនៅឆ្នាំ៤៧៦ ក្រុមកុលសម្ព័ន្ធមកពីអាល្លឺម៉ង់បានវាយលុកចូលកាន់កាប់អ៊ីតាលី រួចហើយទម្លាក់អធិរាជនៃចក្រភពរ៉ូមខាងលិចពីអំណាច។




ប្រទេសរ៉ូមបូរាណ (ឆ្នាំ៧៥៣- ឆ្នាំ៥០៩មុនគ្រិស្តសករាជ)
និងអាណាចក្ររ៉ូម (ឆ្នាំ២៧ មុនគ្រិស្តសករាជ ដល់ឆ្នាំ៤៧៦ )



អារ្យធម៌រ៉ូម ចាប់តាំងពី ស.វ. ទី៨ មុនគ្រិស្តសករាជ

ក្រោយមកអាណាចក្របីហ្សង់តាំង ដែលមានរាជធានីនៅកុងស្តង់ទីណូប (Constantinoble) គឺនៅត្រង់ទីក្រុងអ៊ីស្តង់ប៊ុល ប្រទេសតួកគីបច្ចុប្បន្ន បានបន្តអំណាចរ៉ូម រហូតដល់សតវត្សរ៍ទី១៥នៃគ.ស.។ នៅឆ្នាំ១៤៥៣ តួកគីបានវាយលុកកាន់កាប់ទីក្រុងកុងស្តង់ទីណូប ផ្តួលរលំចក្រភពបីហ្សង់តាំង ហើយបង្កើតជាចក្រភពភពថ្មីមួយទៀត គឺចក្រភពអូតូម៉ង់ (ឬចក្រភពតួកគី)។

## ១.២. អាណាចក្រអេហ្ស៊ីប

អេហ្ស៊ីបបុរាណ គឺជាអាណាចក្រដែលមានវ័យចំណាស់បំផុតមួយក្នុងប្រវត្តិសាស្ត្រ និងជាទីកន្លែងនៃការចាប់កំណើតរបស់មនុស្ស រួមទាំងវប្បធម៌អរិយធម៌ និងប្រវត្តិនៃការបង្កើតរដ្ឋដំបូងផងដែរ។

មនុស្សចាប់ផ្តើមរស់នៅជាក្រុមនៅទីនោះ តាំងពី ១០០,០០០ឆ្នាំមុនគ្រិស្តសករាជ បន្ទាប់តៗមកក៏បានបង្កើតជាអារ្យធម៌ នៅ ៣១៥០ ឆ្នាំ មុនគ្រិស្តសករាជ (Ancient Egyptian civilization was around 3150 BC) ។

ប្រទេសអេហ្ស៊ីប គឺជាប្រទេសមួយដែលស្ថិតនៅកាត់ទ្វីប ហើយត្រូវបានគេចាត់ទុកថាជា ប្រទេសមួយដែលមានឥទ្ធិពលយ៉ាងខ្លាំង នៅអាហ្វ្រិកខាងជើង នៅសមុទ្រមេឌីទែរ៉ាណេ នៅតំបន់ឧបទ្វីបអាហ្វ្រិក ទន្លេនីល ពិភពអ្នកកាន់សាសនា និងតំបន់សមុទ្រ។



ការបង្កើតអក្សរជាសំណេរដំបូងគឺនៅអេហ្ស៊ីប កាលពីប្រមាណ ៣០០០ ទៅ ៤០០០ឆ្នាំមុនគ.ស.។ រដ្ឋនៅអេហ្ស៊ីបត្រូវបានបង្កើតឡើងដោយសារស្ថានភាពភូមិសាស្ត្រមិនអំណោយផល ពោលគឺអេហ្ស៊ីបជាប្រទេសសម្បូរទៅដោយវាលខ្សាច់ហួតហែងកម្រមានភ្លៀងធ្លាក់ ជាហេតុនាំឱ្យប្រជាជនមានគំនិតបង្កើតរដ្ឋ ដើម្បីជួយចាត់ចែងទឹកប្រើប្រាស់សម្រាប់ពួកគេ។

អេហ្ស៊ីបសម័យបុរាណ មានប្រជាជនសរុបប្រមាណពី ៧ ទៅ ៨លាននាក់ ដែលពោរពេញដោយអរិយធម៌ដ៏រុងរឿងនិងឯករាជ្យអស់រយៈពេលប្រមាណ ២៥ សតវត្សរ៍។ ប៉ុន្តែ ក្រោយមកអាណាចក្រដ៏រុងរឿងនេះក៏ត្រូវធ្លាក់ចុះខ្សោយបន្តិចម្តងៗ ដោយសារមានការចូលឈ្លានពានពីសំណាក់អាណាចក្រពែកស៍ នៅចន្លោះឆ្នាំ ៥២៥មុនគ.ស. ដែលបាននាំឱ្យអេហ្ស៊ីបត្រូវធ្លាក់ចុះដុនដាបលែងស្គាល់ឯករាជ្យ។ នៅឆ្នាំ៣៣២ មុនគ្រឹស្តសករាជ ស្តេចម៉ាសេដូនី (Macedonian Ruler) ឈ្មោះ មហាអាឡិចសាន់ (Alexander the Great) បានវាយយកនិងត្រួតត្រា លើប្រទេសអេហ្ស៊ីប។ រហូតទាល់តែដល់ឆ្នាំ១៩៥០ នៃគ.ស.ទើបអេហ្ស៊ីបបានស្គាល់នូវការរីកចម្រើននិងឯករាជ្យឡើងវិញ។

ប៉ុន្តែ ចក្រភពអង់គ្លេសបានរក្សាការគ្រប់គ្រងលើកិច្ចការបរទេស ការពារជាតិនិងបញ្ហាផ្សេងៗទៀតរបស់ប្រទេសអេហ្ស៊ីប។ ការកាន់កាប់របស់អង់គ្លេសមានរយៈពេលរហូតដល់ឆ្នាំ១៩៥៤។ សាធារណរដ្ឋអេហ្ស៊ីបទំនើបត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៥៣ ហើយជាមួយនឹងការដកទ័ពអង់គ្លេសទាំងស្រុងចេញពីព្រែកជីកស៊ុយអេក្នុងឆ្នាំ១៩៥៦។



(ប្រទេសអេហ្សីប ឆ្នាំ៣១៥០ មុនគ្រិស្តសករាជ)

ភស្តុតាងដែលបង្ហាញឱ្យឃើញពីភាពរុងរឿងក្នុងសម័យអាណាចក្រអេហ្ស៊ីប គឺការសាងសង់ពីរ៉ាមីដ(សាងសង់អំពីថ្មដែលមានភាពរឹងមាំ) ប្រវត្តិនៃការកកើតរដ្ឋ សំណេរប្រវត្តិសាស្ត្រផ្សេងទៀតដែលពិភពលោកបានស្គាល់រហូតមកដល់ពេលបច្ចុប្បន្ន។

## ១.៣. អាណាចក្រក្រិក

ប្រទេសក្រិក គឺជាឈ្មោះសម័យបុរាណដែលមានឥទ្ធិពលនិងការអភិវឌ្ឍខ្លាំងនៅទ្វីបអឺរ៉ុប ហើយក៏ជាប្រជាធិបតេយ្យដំបូងដែលត្រូវបានគេស្គាល់យ៉ាងទូលំទូលាយ និងជាប្រទេសនៃវប្បធម៌ ទ្រឹស្តី ទស្សនវិជ្ជា និងការបង្កើតស្នាដៃផ្សេងៗ។ ទីក្រុងរ៉ូមបុរាណត្រូវបានបង្កើតឡើងនៅឆ្នាំ 753 មុនគ្រិស្តសករាជ ខណៈពេលដែលជនជាតិក្រិចត្រូវបានគេស្គាល់ថាមានតាំងពីសម័យ Mycenaean ដែលមានអាយុកាលតាំងពីឆ្នាំ 1700 មុន គ.ស.។




ចាប់ពីសតវត្សទី៨ ដល់សតវត្សទី៤ មុនគ្រិស្តសករាជ ប្រទេសក្រិក មានអរិយធម៌មួយលូតលាស់ខ្លាំងនៅក្នុងសម័យបុរាណ និងបានឈាន ដល់កម្រិតកំពូលនៅសតវត្សទី៥មុនគ្រិស្តសករាជ។ ក្រុងអាថែនត្រូវបាន គេចាត់ទុកជាទីក្រុងមួយ ក្នុងចំណោមក្រុងដ៏រុងរឿងទាំងឡាយនៃពិភព ក្រិក ដែលជនជាតិក្រិកត្រូវបានប្រមូលផ្តុំក្រោមការគ្រប់គ្រងនៃបុរីនានា ដែលមានភាសារបៀបរស់នៅ សាសនា និងសិល្បៈដូចគ្នា។[23]

ប្រទេសក្រិចត្រូវបានចាត់ទុកថាជាទីចាប់ផ្តើមនៃអរិយធម៌លោក ខាងលិច ដែលជាកន្លែងកំណើតនៃលទ្ធិប្រជាធិបតេយ្យ ទស្សនវិជ្ជា លោកខាងលិច អក្សរសិល្ប៍លោកខាងលិច ប្រវត្តិសាស្រ្ត វិទ្យាសាស្រ្ត

23 សៀវភៅភូមិវិទ្យានិងប្រវត្តិវិទ្យាទ្វីបអឺរ៉ុប,ទំព័រ១២៧ ដោយ **អ៊ុន យ៉េត-ឃឹម វិច្ឆិកា**

នយោបាយ គោលការណ៍វិទ្យាសាស្ត្រ និងគណិតវិទ្យាសំខាន់ៗ មហោស្រព និងកីឡាអូឡាំពិក។



ប្រទេសក្រិកបូរាណ ស.វ. ទី១២ - ស.វ. ទី៩ មុនគ្រិស្តសករាជ

អាណាចក្រក្រិកបុរាណ ប្រមូលផ្ដុំដោយជនជាតិមីណូ មីសែលដូរ្យាង *(អ្នកលុកលុយពីខាងក្រៅ)* ដោយបានរៀបចំឱ្យមានរបបគ្រប់គ្រងនៅក្នុងសហាគមន៍របស់ពួកគេ ដោយមានការចូលរួមបង់ពន្ធ អាករលើផ្ទះ សំបែង ដីធ្លី និងមានមុខរបបចិញ្ចឹមជីវិតរៀងៗខ្លួន។ ក្រោយមកនៅអំឡុងសតវត្សរ៍ទី៥ មុនគ.ស.ប្រជាជនអាថែន និងស្ប៉ាត បានប្រឈមនឹងការចូលឈ្លានពានរបស់ពួកពែក្ស ប៉ុន្តែពួកពែក្សត្រូវបានទទួលបរាជ័យ ដែលការបរាជ័យរបស់ពួកពែក្សនេះហើយដែលនាំឱ្យអាណាចក្រក្រិក មានភាពរុងរឿងខ្លាំងបំផុត នាឆ្នាំ៤៨០ មុន គ.ស.។ ក្រោយពីបានទទួលជ័យជម្នះលើកង

ទ័ពនៃអាណាចក្រពែរស៍ អាថែនដែលជាបុរីរដ្ឋដ៏សំខាន់មួយរបស់ក្រិក បានស្គាល់នូវភាពរុងរឿង មានឈ្មោះល្បីល្បាញ ហើយបានពង្រីកឥទ្ធិពលនៃវប្បធម៌របស់ខ្លួនទៅកាន់បុរីរដ្ឋផ្សេងទៀតរបស់ក្រិក ក៏ដូចជាទៅកាន់រដ្ឋផ្សេងទៀតនៅក្បែរៗនោះផងដែរ។ អាថែន គឺជាអ្នកបង្កើតរបបដឹកនាំបែបប្រជាធិបតេយ្យជាលើកដំបូងគេបង្អស់ក្នុងប្រវត្តិមនុស្សជាតិ។ ពលរដ្ឋអាថែន ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅមានសិទ្ធិចូលរួមប្រជុំ ដើម្បីជ្រើសរើសសមាជិកសភា ហើយសមាជិកសភាជាអ្នកជ្រើសរើសសមាសភាពរដ្ឋាភិបាល និងជាដំណើរការប្រជាធិបតេយ្យ ដែលបានបន្សល់ទុករហូតមកទល់នឹងពេលបច្ចុប្បន្ន។ នៅក្រិកសម័យបុរាណ យុវជនទទួលបាននូវការអប់រំយ៉ាងទូលំទូលាយ ដោយភាគច្រើនចេះអាន និងចេះសរសេរ។



សូក្រាតសុខចិត្តផឹកថ្នាំពុលសម្លាប់ខ្លួន (ឆ្នាំ៣៩៩ មុនគ្រិស្តសករាជ)

ក្រៅពីប្រជាធិបតេយ្យ និងទស្សនវិជ្ជា ក្រិកក៏បានបង្កើតគំនិតថ្មីៗជាច្រើនទៀត ដែលបន្សល់ទុកជាកេរមរតកសម្រាប់មនុស្សជាតិ រហូត

ដល់ពេលបច្ចុប្បន្ននេះ។ ទ្រឹស្តីបទគណិតវិទ្យាជាច្រើនមានប្រភពចេញពីក្រិក ហើយដែលគេនៅតែបន្តយកមកបង្រៀននៅតាមសាលារៀននៅទូទាំងពិភពលោកសព្វថ្ងៃនេះ (Pythagore, Thalès, Archimède សុទ្ធសឹងជាជនជាតិក្រិក)។ នៅក្នុងភាសានៃបណ្តាប្រទេសក្នុងទ្វីបអឺរ៉ុបបច្ចុប្បន្ន គេសង្កេតឃើញថា ពាក្យបច្ចេកទេសដែលអ្នកចេះដឹងច្រើន យកមកប្រើភាគច្រើនជាពាក្យដែលមានឫសគល់ចេញពីភាសាក្រិក។

## ១.៤. អាណាចក្រពែរស៍

ក្រោមការដឹកនាំរបស់អធិរាជស៊ីរូស Cyrus អាណាចក្រពែរស៍បានវាតទីពង្រីកដែនដីរបស់ខ្លួន ដោយវាយកាន់កាប់រដ្ឋដែលនៅជិតខាងដែលក្នុងនោះក៏រួមមានទាំងអាណាចក្របាប៊ីឡូន នៅមេសូប៉ូតាមីផងដែរ។ គិតត្រឹមឆ្នាំ ៥០០មុនគ.ស. មេសូប៉ូតាមី អេហ្ស៊ីប ឥណ្ឌា ព្រមទាំងតំបន់អាស៊ីកណ្តាល និងមួយផ្នែកនៃតំបន់មេឌីទែរ៉ាណេ ត្រូវធ្លាក់ក្រោមការកាន់កាប់របស់អាណាចក្រពែរស៍។

នៅឆ្នាំ៤៩៩ មុនគ.ស. ក្រោមការដឹកនាំរបស់អធិរាជដារីយូស (Darius) អាណាចក្រពែរស៍ ដែលដណ្តើមកាន់កាប់ទ័ពជើងទឹករបស់លីបង់ (ហ្វេនីស៊ី) ក៏បានបញ្ជូនទូកចម្បាំងនិងទាហានរបស់ខ្លួនទៅវាយលុកចូលក្នុងប្រទេសក្រិក។ ក៏ប៉ុន្តែ កងទ័ពពែរស៍ត្រូវកងទ័ពក្រិកវាយបំបាក់ នៅប្រមាណ ៤០គីឡូម៉ែត្រពីបុរីអាថែនត្រង់កន្លែងមួយឈ្មោះថា"ម៉ារ៉ាតុង"។

ក្រោយពីទទួលបរាជ័យនៅម៉ារ៉ាតុង អាណាចក្រពែរស៍មិនអស់ចិត្តក៏បានលើកទ័ពមកវាយលុកលើក្រិកសាជាថ្មីទៀត។ សង្គ្រាមរវាងពែរស៍និងក្រិកបានអូសបន្លាយពេលរហូតដល់ទៅប្រមាណជាកន្លះសតវត្សរ៍។ ក៏ប៉ុន្តែ នៅចុងបំផុតទៅកងទ័ពអាណាចក្រពែរស៍ ដែលមានចំនួនយ៉ាង

ច្រើនសន្ទឹកសន្ទាប់នៅតែត្រូវទទួលបរាជ័យ ដោយមិនអាចវាយកាន់កាប់ក្រិកបាន ដោយសារតែកងទ័ពរបស់ក្រិច គឺជាកងទ័ពដែលមានស្មារតីស្នេហាជាតិ និងប្តូរផ្តាច់ ដើម្បីការពារសេរីភាព និងឯករាជ្យរបស់ខ្លួន ពីការត្រួតត្រារបស់បរទេស។

នៅក្នុងអំឡុងពេលនោះ ពែរស៍ គ្រាន់តែជារដ្ឋតូចមួយប៉ុណ្ណោះ លែងជាអាណាចក្រដ៏សម្បើមដូចពីមុនទៀតហើយ។ ឥណ្ឌាវិញ បន្តមានបញ្ហាបាក់បែកផ្ទៃក្នុងច្រើន ក៏ប៉ុន្តែ នៅតែអាចចាប់ផ្តើមពង្រីកឥទ្ធិពលនៃអរិយធម៌របស់ខ្លួន ទៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (នគរជ្វា ខ្មែរ ម៉ាឡេ និងចាម្ប៉ា ជាដើម)។ ចំណែកចិន ដែលបានបង្រួបបង្រួមគ្នា ក្រោមការដឹកនាំរបស់រាជវង្សហាន គឺជាអាណាចក្រដ៏សំខាន់មួយដែរ គ្រាន់តែមិនមែនជាមហាអំណាចកម្រិតពិភពលោក ដូចជាចក្រភពរ៉ូម។ អាណាចក្រទាំងពីរ ចិន និងរ៉ូម មានទំនាក់ទំនងជាមួយគ្នាច្រើន ទាំងទំនាក់ទំនងផ្នែកការទូត និងខាងផ្នែកជំនួញ ជាពិសេស ការជួញដូរសូត្រពីចិន។

## ១.៥. អាណាចក្រឥណ្ឌា

- **ការកកើតរដ្ឋនៅឥណ្ឌា**

មនុស្សបានមករស់នៅ លើទឹកដីអាស៊ីខាងត្បូង (ប្រទេសឥណ្ឌា) តាំងពី ៧៣០០០ ទៅ៥៥០០០ឆ្នាំ មកហើយ។ មនុស្សចេះ ប្តូរពីការស្វែងរកចំណីអាហារក្នុងព្រៃ មកធ្វើកសិកម្ម ចិញ្ចឹមសត្វ នៅប្រហែល ៧០០០ ឆ្នាំ មុនគ្រិស្តសករាជ ។ អរិយធម៌ ចាប់រីកចម្រើនខ្លាំង នៅ ២៥០០ឆ្នាំ ទៅ ១៩០០ឆ្នាំ មុនគ្រិស្តសករាជ ។

ឥណ្ឌា គឺជាដែនដីមួយក្នុងចំណោមដែនដី ដែលមានអារិយធម៌ដ៏ចំណាស់បំផុតក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិក្រៅពី អេហ្ស៊ីប មេសូប៉ូ

តាមី និងចិន។ ការកកើតរដ្ឋដំបូង និងអារិយធម៌ដំបូងរបស់មនុស្សជាតិ គឺបានចាប់កំណើតឡើងមុនគេ នៅតាមតំបន់ដែលមនុស្សចាប់ផ្តើមបង្កើតជារបរកសិកម្ម គឺមាននៅតាមតំបន់ទាំង ៤ ដែលជាប់នឹងទន្លេសំខាន់ៗ រួមមាន៖

- អេហ្ស៊ីប-ជាប់នឹងទន្លេនីល
- មេសូប៉ូតាមី-ជាប់នឹងដងទន្លេអឺប្រ៉ាត និងទន្លេទីហ្គ្រីស
- ឥណ្ឌា-ជាប់នឹងដងទន្លេឥណ្ឌុស និង
- ចិន-ជាប់នឹងដងទន្លេលឿង។

នៅប្រមាណ ១៥០០ឆ្នាំ ក្រោយមកទើប «រដ្ឋ» បានចាប់កំណើតឡើងនៅ ឥណ្ឌា។ ដោយសារតែតំបន់នេះមានការប្រែប្រួលអាកាសធាតុបណ្តាលឱ្យបាត់បង់ព្រៃឈើ បង្ករជាវាលខ្សាច់ មិនសូវមានភ្លៀងធ្លាក់ច្រើន ទើបដំណើរវិវឌ្ឍឆ្ពោះទៅរកការបង្កើតរដ្ឋនៅឥណ្ឌា ក៏ដូចជាចិនបានធ្វើឡើងដោយសន្សឹមៗ និងដោយសារតែមនុស្សនៅក្នុងតំបន់នេះមិនសូវជាមានតម្រូវការចាំបាច់ និងបន្ទាន់ខ្លាំងក្នុងការបង្កើតជារចនាសម្ព័ន្ធរដ្ឋ ដើម្បីគ្រប់គ្រងបែងចែកធនធានទឹក ដូចនៅអេហ្ស៊ីប និងមេសូប៉ូតាមីដែលតែងតែវាយកាប់ចាក់គ្នាដណ្តើមធនធានទឹក។

- វប្បធម៌ អរិយធម៌ និងនយោបាយ

ឥណ្ឌាថ្វីត្បិតតែមានប្រវត្តិហាក់ដូចជាក្រោយ អេហ្ស៊ីប និងមេសូប៉ូតាមីពិតមែន ក៏ប៉ុន្តែប្រជាជននៅតំបន់ឥណ្ឌានេះ មានច្រើនប្រហាក់ប្រហែលគ្នាដែរជាមួយប្រជាជននៅតំបន់អេស៊្សីប និងមេសូប៉ូតាមី គឺប្រមាណជាង១០លាននាក់ ហើយមនុស្សជាតិយើងសម័យកាលនោះចាប់ផ្តើមចេះប្រកបរបរកសិកម្ម ការដាំដុះ និងចិញ្ចឹមសត្វ ជំនួសឱ្យការបរ

បាញ់សម្រាប់ការចិញ្ចឹមជីវិតប្រចាំថ្ងៃនិងការបង់ពន្ធជូនរដ្ឋផងដែរ។ ក្រៅពីរបរកសិកម្ម និងការចិញ្ចឹមសត្វ មនុស្សបានចាប់ផ្តើមចេះធ្វើជំនួញរវាងគ្នានឹងគ្នា រវាងរដ្ឋនឹងរដ្ឋ ដើម្បីដោះដូរទំនិញ ឬផលរបរដែលពួកគេរកបានដោយខ្លួនឯង។

ឧទាហរណ៍៖ «សូត្រ» ដែលពេលនោះមានផលិតតែនៅ ចិន ប៉ុន្តែត្រូវបានគេនាំយកទៅលក់រហូតទៅដល់ អេហ្ស៊ីប ដោយឆ្លងកាត់តាមផ្លូវគោកដ៏វែងឆ្ងាយដែលគេឱ្យឈ្មោះថា "ផ្លូវសូត្រ" ចេញពីឆាងអាន កាត់តាមឥណ្ឌា និងមេសូប៉ូតាមី រហូតទៅដល់អេហ្ស៊ីប។

ជាមួយគ្នានឹងសកម្មភាពកសិកម្មដែលជាសម័យយុគថ្មរំលីងនេះ គេក៏សង្កេតឃើញថា មនុស្សបានចាប់ផ្តើមមានគំនិតចេះច្នៃប្រឌិតរបស់របរប្រើប្រាស់សម្រាប់បម្រើឱ្យការងារកសិកម្ម និងការចិញ្ចឹមសត្វ ព្រមទាំងការកសាងជាហេដ្ឋារចនាសម្ព័ន្ធ ប្រាង្គប្រាសាទ និងទីសក្ការៈផ្សេងៗដែលជាជំនឿទៅតាមប្រភេទដូចជាសាសនានាសម័យបច្ចុប្បន្នដែរ។

អំពីសង្គ្រាមវិញ ឥណ្ឌា ក្នុងសម័យបុរាណមិនសូវជាធ្វើសង្គ្រាមជាមួយចិន និងរដ្ឋផ្សេងទៀតដោយផ្ទាល់ដូចជានៅ អេហ្ស៊ីប និងមេសូប៉ូតាមីនោះទេ ក៏ប៉ុន្តែ បែរជារដ្ឋនិងបុរីផ្ទៃក្នុងទៅវិញទេ ដែលតែងតែមានការប្រកាប់ប្រចាក់គ្នា ដើម្បីដណ្តើមឥទ្ធិពលនិងផលប្រយោជន៍សម្រាប់ខ្លួនឯង។ ដូចជានៅចិនដែរ រដ្ឋ និងបុរី នៅផ្ទៃក្នុងអាណាចក្រចិនមានការធ្វើសង្គ្រាមស៊ីសាច់ហុតឈាមរវាងគ្នានិងគ្នាដោយឥតត្រាប្រណី រហូតដល់ជាប់ឈ្មោះថា ជា "អាណាចក្រសង្គ្រាម" ដែលរហូតដល់ឆ្នាំ២២០ មុនគ.ស. ទើបអាណាចក្រចិនបានស្គាល់ការរួបរួមគ្នា ក្រោមការដឹកនាំរបស់អធិរាជ "ឈីន" (Qin) មុននឹងបន្តការបែកបាក់បង្កើតជាសង្គ្រាមបន្តទៀត។

ដូចនេះ ក្រៅពី អេហ្ស៊ីប មេសូប៉ូតាមី និងចិន ឥណ្ឌា គឺជាដែនដីមួយនៃប្រភពវប្បធម៌ និងអរិយធម៌ដំបូងបង្អស់របស់មនុស្សជាតិ គឺជាទីកន្លែងចាប់កំណើតនៃរបរកសិកម្មតាំងពីរាប់ពាន់ឆ្នាំមុន និងរបៀបរស់នៅដែលយើងនៅតែបន្តឃើញមានមកទល់នឹងពេលបច្ចុប្បន្ននេះ។ គំនិតច្នៃប្រឌិត និងរបកគំហើញមួយចំនួន ដូចជា ត្រីវិស័យ រំសេវផ្ទុះ ក្រមច្បាប់ ជាដើម គឺសុទ្ធសឹងជាមរតកដែលបន្សល់ទុកដោយអរិយធម៌ដ៏ចំណាស់នេះឱ្យមនុស្សជាតិយើងបន្តប្រើប្រាស់រហូតមកទល់នឹងពេលបច្ចុប្បន្ន។

## ១.៧. អាណាចក្រអូតូម៉ង់ (ឆ្នាំ ១៣៣៣-១៩២២)

មេដឹកនាំកុលសម្ព័ន្ធទួគី Osman គឺជាអ្នកដែលបានបង្កើតចក្រភពអូតូម៉ង់មួយនេះឡើងដំបូងគេ និងបានចាប់ផ្តើមពង្រីកទឹកដី និងមានអំណាចយ៉ាងខ្លាំងក្លានាចន្លោះសតវត្សរ៍ទី១៥ ទី១៦ ដោយបានច្បាំងយកប្រទេស ពែរស៍ អេហ្ស៊ីប ប៉ែលហ្គ្រាដ ផ្នែកមួយចំនួននៃប្រទេសហុងគ្រី ថែមទាំងបានគ្រប់គ្រងលើតំបន់ Mesopotamia ឈូងសមុទ្រពែរស៍ ប្រទេសសូម៉ាលី និងតំបន់ Horn of Africa ផងដែរ។

ចក្រភពអូតូម៉ង ក៏ជាផ្នែកមួយសំខាន់ក្នុងនយោបាយប៉ែកអឺរ៉ុប ក្នុងសង្គ្រាមពង្រីកទឹកដីក្នុងសម័យឆ្នាំ១៤៥៣-១៥៦៦។ ប៉ុន្តែចក្រភពមួយនេះត្រូវបានចុះអន់ថយបន្តិចម្តងៗនៅក្នុងឆ្នាំ១៩០៨ និងត្រូវបានដួលរលំទាំងស្រុងនៅក្នុងឆ្នាំ១៩២២ បន្ទាប់ពីបានឈរជើងលើទ្វីបទាំង៣អស់រយៈពេលជាង ៦០០ឆ្នាំ។

## ១.៨. អាណាចក្រកាលីហ្វាត (ឆ្នាំ៦៣០ ដល់ ឆ្នាំ៩០០)

ចក្រភពនេះ ត្រូវបានបង្កើតឡើងដោយមេដឹកនាំសាសនាមូស្លីម Muhammad និងមានឈ្មោះម្យ៉ាងទៀតហៅថា «ចក្រភពអារ៉ាប់» ដែល

បានចាប់ផ្តើមបង្កើត និងសាបព្រោះផ្សព្វផ្សាយសាសនាអ៊ិស្លាមដំបូងគេផងដែរហើយថែមទាំងមានកម្លាំងទ័ពខ្លាំងក្លាបានច្បាំងដណ្តើមយកតំបន់អាស៊ីអាគ្នេយ៍ អាហ្វ្រិកខាងជើង និងប្រទេសអេស្ប៉ាញ ទៀតផង។

ស្តេច ឬមេដឹកនាំសាសនាដែលបានគ្រប់គ្រងចក្រភពកាលីហ្វាតដំបូងមាន ៤ នាក់ គឺ Viz Abu Bakr, Umar I, Uthman និង Ali ហើយអ្នកទាំងនោះហើយដែលជាអ្នកដែលបានដឹកនាំចក្រភពកាលីហ្វាតឱ្យក្លាយជាយុគមាសនៃអ៊ិស្លាមសាសនាផងដែរ។

## ១.៩. ចក្រភពអង់គ្លេស

ទឹកដីនៃប្រទេសអង់គ្លេស មានមនុស្សរស់នៅតាំងតែពី ៨០០,០០០ ឆ្នាំមកម្ល៉េះ តាមដែលគេរកឃើញភស្តុតាង (discovery of stone tools and footprints at Happisburgh in Nortfolk) ។ រីឯមនុស្សទំនើប មាននៅ ៤១,០០០ - ៤៤,០០០ឆ្នាំមុនមក គេរកឃើញស្លាកស្នាមនៅតំបន់ ឌីវ៉ុន (in Devon at Kents Cavern)។

អំឡុងឆ្នាំ១៥៨៣ ដល់ឆ្នាំ១៩៤៥ ចក្រភពអង់គ្លេសមានទឹកដីធំធេងជាងគេនៅក្នុងប្រវត្តិសាស្ត្រសម័យនោះ ដោយមានផ្ទៃដី លាតសន្ធឹងទំហំដល់ទៅ ៣៥.៥០ លានគីឡូម៉ែត្រការ៉េ។ ប្រទេសមហាអំណាចមួយនេះអាចមានសមត្ថភាពអាចទប់ទល់នឹងសង្គ្រាមធំៗជាច្រើននៅក្នុងពេលតែមួយផងដែរ ថែមទាំងបានដឹកនាំ និងប្រជាជនជាង ៤១២លាននាក់ ដែលស្មើនឹង ២៣% នៃប្រជាជនទូទាំងពិភពលោក ជាពិសេសត្រូវបានគេដាក់ឈ្មោះឱ្យ ថា «ព្រះអាទិត្យមិនដែលអស្តង្គត» ដែលមានន័យសម្រាប់សំដៅលើចក្រភពដ៏ខ្លាំងពូកែមួយនេះមានអំណាចកើនឡើងជាលំដាប់មិនចេះ

អន់ថយ។ ចក្រភពមួយនេះផងដែរ បានគ្រប់គ្រងសេដ្ឋកិច្ចលើតំបន់ជាច្រើន ដូចជា អាស៊ី អាម៉េរិកឡាទីន និងផ្នែកមួយចំនួននៃទ្វីបអាហ្វ្រិក។

ចក្រភពអង់គ្លេសដែលឈរជើងក្នុងអំឡុងឆ្នាំ១៥៨៣ ដល់ឆ្នាំ ១៩៤៥ បានធ្វើឱ្យភាសាអង់គ្លេសបានហូរចូលទៅកាន់បណ្តាប្រទេសផ្សេងៗ លើពិភពលោក រហូតដល់ក្លាយទៅជាភាសាផ្លូវការទី២បន្ទាប់ពីភាសាកំណើតរបស់ប្រទេសដទៃជាច្រើនទៀតផងដែរ រហូតមកដល់សព្វថ្ងៃនេះ។

ក្រោយពីក្លាយជាប្រទេសដែលមានវិសាលភាពទឹកដីធំធេង មានចំនួនប្រជាជនដ៏ច្រើនលើសលប់ និងមានកម្លាំងយោធាដ៏ខ្លាំងក្លាហើយនោះ គួរឱ្យសោកស្តាយដោយសារតែសង្គ្រាមលោកលើកទី២ បានធ្វើឱ្យចក្រភពអង់គ្លេសចាប់ផ្តើមអន់ថយបន្តិចម្តងៗជាលំដាប់ទៅវិញ។

## ១.១០. ប្រទេសចិន

ប្រវត្តិសាស្ត្រចិន ចាប់ផ្តើមពីឆ្នាំ ១២៥០ មុនគ.ស.ចាប់ពីរាជវង្សសាង (Shang Dynasty c. 1600-1045 BC) ។ ប៉ុន្តែមានការរកឃើញតាមឯកសារច្រើនទៀតថា ប្រទេសចិនមានអរិយធម៌ តាំងពីឆ្នាំ ២០៧០ -១៦០០ មុន គ.ស.ក្នុងរាជវង្ស សៀ (Xia Dynasty) ។ រាជវង្ស សាង គ្រប់គ្រងតំបន់នៅតាមដងទន្លេលឿង ។ ទោះជាយ៉ាងណា ក៏អារ្យធម៌សម័យថ្មរំលីង[24] បានចាប់ផ្តើមឡើងនូវមណ្ឌលវប្បធម៌នានាជាច្រើនកន្លែង ជាពិសេស នៅតាមតំបន់តាមបណ្តោយ ដងទន្លេលឿង និងទន្លេយ៉ង់សេ (Yellow River and Yangtze River) ។ អារ្យធម៌ទាំងនេះ បានកើតច្រើនពាន់ឆ្នាំ មុនជំនាន់

---

[24] សម័យថ្មរំលីង Neolithic c. 8500- c. 2070

រាជវង្ស សាង ទៅទៀត។ ជាមួយនឹងប្រវត្តិសាស្ត្របន្តបន្ទាប់ច្រើនពាន់ឆ្នាំ ប្រទេសចិន ជាប្រទេសមួយ ដែលមានអារ្យធម៌ដ៏ចំណាស់មួយ នៅក្នុងពិភពលោក។ រាជវង្ស ចូវ (Zhou Dynasty 1046-256 BC) បានបន្តពីរាជវង្ស សាង ចាប់ពីឆ្នាំ ១០៤៦ មុន គ.ស.។

ជាបន្តបន្ទាប់មក រាជវង្ស ហាន បានចាប់ផ្តើម ពីឆ្នាំ ២០២ មុន គ.ស. (Han Dynasty 202 BC - 220 AD។

អស់រយៈពេល ២១ សតវត្ស ចាប់ពីឆ្នាំ២០២ មុន គ.ស. ដល់ឆ្នាំ ១៩២១ នៃគ្រិស្តសករាជ កិច្ចការរដ្ឋបាលត្រូវបានដឹកនាំដោយមន្ត្រីរាជការ ដែលជា អ្នកប្រាជ្ញ អ្នកមានចំណេះដឹងខ្ពស់ ដែលជំនាញ ប្រវត្តិសាស្ត្រ ទស្សនវិជ្ជា អក្សរសាស្ត្រ...។ល។ ចុងក្រោយបំផុតនៃរាជានិយមនៅប្រទេសចិន គឺរាជវង្ស ឈីង (Qing Dynasty 1644-1912) ដែលបានត្រូវផ្តួលរំលំ រួចជំនួសដោយសាធារណរដ្ឋចិន នៅឆ្នាំ១៩១២ ហើយបន្ទាប់មកដោយសាធារណរដ្ឋប្រជាមានិតចិន នៅ១៩៤៩ និង សាធារណរដ្ឋចិន ដែលបានដកថយទៅតាំងទីនៅ កោះតៃវ៉ាន់។

## ១.១១. អាណាចក្រអង្គរ (៨០២-១៤៣១)

នៅក្នុងអំឡុងសតវត្សរ៍ទី៩ នៅក្នុងពេលដែលអឺរ៉ុបកំពុងឆ្លងកាត់នូវយុគខ្មៅងងឹត ក្រោយការដួលរលំនៃចក្រភពរ៉ូម ហើយចក្រភពអារ៉ាប់កំពុងស្គាល់ភាពរុងរឿង បានវាតទីកាន់កាប់ទឹកដីនៅប៉ែកខាងត្បូង និងខាងកើតនៃតំបន់មេឌីទែរ៉ាណេ រីឯនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ឯណោះវិញ អាណាចក្រមួយក៏កំពុងតែងើបឡើង និងស្គាល់ភាពរុងរឿងខ្លាំងដែរ នោះគឺ អាណាចក្រខ្មែរ។




ផែនទីនៃអាស៊ីអគ្នេយ៍ សវ ទី៩

នៅក្នុងអាណាចក្រហ្វូណន គេឃើញមាននគរពីរ ដែលមានការប្រកួតប្រជែងគ្នាខ្លាំងជាងគេ គឺមួយមានរាជធានីនៅវ្យាធបុរៈ (នៅត្រង់ព្រៃកប្បាសបច្ចុប្បន្ន) និងមួយទៀត មានរាជធានីនៅសម្ភុបុរៈ (ត្រង់ស្រុកសម្បូរ ខេត្តក្រចេះបច្ចុប្បន្ន)។ នៅសតវត្សរ៍ទី៥ នគរវយធបុរៈបានវាយដណ្ដើមកាន់កាប់សម្ភុបុរៈ ហើយបញ្ចូលគ្នាបង្កើតទៅជានគរធំមួយ ដែលមានអំណាចយ៉ាងខ្លាំង រហូតក្រោយមកទៀត ឈានទៅដណ្ដើមកាន់កាប់ដែនដីនៃនគរហ្វូណនទាំងមូល។ នគរហ្វូណនត្រូវដួលរលំ ហើយជំនួស

មកវិញ ដោយនគរថ្មីមួយទៀត ដែលនៅក្នុងឯកសារចិនដាក់ឈ្មោះឱ្យថា "ចេនឡា" ហើយដែលក្រោយមកបានក្លាយទៅជាអាណាចក្រខ្មែរ។

នៅសតវត្សរ៍ទី៧ ក្រោយការចូលទីវង្គតរបស់ព្រះបាទជ័យវរ្ម័នទី១ រាជាណាចក្រកម្ពុជា ដែលចិនហៅថា ចេនឡា ត្រូវបានបំបែកជានគរពីរ ដូចកាលពីសម័យហ្វូណនវិញ គឺនគរព្រាធបុរៈ ដែលចិនហៅថា "ចេនឡាទឹក" និងនគរសម្ភុបុរៈ ដែលចិនហៅថា "ចេនឡាគោក"។ ចេនឡាទឹកមានទឹកដីនៅត្រង់ម្តុំកម្ពុជាក្រោមសព្វថ្ងៃ ចំណែកឯចេនឡាគោក មានទឹកដីនៅត្រង់ម្តុំប្រទេសកម្ពុជាសព្វថ្ងៃ ហើយលាតសន្ធឹងដល់ជួរភ្នំដងរែក។ ក៏ប៉ុន្តែ ការបែងចែកនគរចេនឡាជាពីរនៅពេលនោះ ប្រហែលជាធ្វើឡើងគ្រាន់តែដើម្បីចែកគ្នាគ្រប់គ្រងតែប៉ុណ្ណោះ។ ចេនឡាទាំងពីរ មិនមែនជាសត្រូវនឹងគ្នា ដូចជាកាលពីនគរព្រាធបុរៈ និងសម្ភុបុរៈ កាលពីនៅក្នុងសម័យកាលនគរហ្វូណននោះទេ។

ផែនទីនៃអាស៊ីអាគ្នេយ៍ ក្នុងអំឡុងសតវត្សរ៍ទី១០ រហូតដល់ដើមសតវត្សរ៍ទី៩ ចេនឡាទាំងពីរក៏បានបង្រួបបង្រួមគ្នាជានគរតែមួយឡើងវិញ ក្រោមការដឹកនាំរបស់ព្រះបាទជ័យវរ្ម័នទី២ ដែលបានឡើងគ្រងរាជ្យនៅឆ្នាំ៨០២។ ថ្វីត្បិតតែនៅក្នុងប្រវត្តិសាស្រ្ត ព្រះបាទជ័យវរ្ម័នទី២មិនសូវមានកិត្តិនាមល្បី ដូចជា ព្រះបាទជ័យវរ្ម័នទី៧ ក៏ប៉ុន្តែ ព្រះអង្គត្រូវបានអ្នកប្រវត្តិសាស្រ្តចាត់ទុកថាជាក្សត្រដំបូងបង្អស់ ដែលបានស្ថាបនាអាណាចក្រខ្មែររួបរួមគ្នាមួយ ដែលក្រោយមកទៀត បានស្គាល់នូវភាពរុងរឿងបំផុតក្នុងប្រវត្តិសាស្រ្តខ្មែរ។ ឆ្នាំ៨០២ ដែលព្រះបាទជ័យវរ្ម័នទី២ ឡើងគ្រងរាជ្យ ត្រូវបានអ្នកប្រវត្តិសាស្រ្តទូទៅកំណត់ថាជាចំណុចចាប់ផ្តើមនៃសម័យអង្គរ ដែលជាសម័យកាលដ៏រុងរឿងបំផុតនៃអាណាចក្រខ្មែរ។



ប្រាសាទអង្គរវត្ត

ក្នុងរយៈពេលប្រមាណជាជាង ៦០០ឆ្នាំ ចាប់តាំងពីដើមសតវត្សរ៍ទី ៩ រហូតដល់ពាក់កណ្តាលសតវត្សរ៍ទី១៥ អាណាចក្រខ្មែរបានស្គាល់នូវភាពរុងរឿង ក្នុងឋានៈជាមហាអំណាច នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ នៅក្នុងអំឡុងពេលនោះ អាណាចក្រខ្មែរបានគ្រប់គ្រងទឹកដីដ៏ធំ ដែលមានការគ្របដណ្តប់លើទឹកដីកម្ពុជា ថៃ ឡាវ និងប៉ែកខាងត្បូងប្រទេសវៀតណាមបច្ចុប្បន្ន។ ព្រំដែននៃអាណាចក្រខ្មែរលាតសន្ធឹងរហូតទៅដល់ប្រទេសចិន នៅប៉ែកខាងជើង ភូមា នៅប៉ែកខាងលិច ម៉ាឡេស៊ី នៅប៉ែកខាងត្បូង និងនគរចម្ប៉ា នៅខាងកើត។

នៅក្នុងកំណត់ត្រារបស់ពួកអារ៉ាប់ នៅចន្លោះពីសតវត្សរ៍ទី៩ និងសតវត្សរ៍ទី១០ គេឃើញថា កាលណានិយាយពីតំបន់អឺរ៉ុប ពួកអារ៉ាប់តែងតែលើកឡើងពីការធ្លាក់ដុនដាប ក្នុងយុគខ្មៅងងឹត ក៏ប៉ុន្តែ ពួកអារ៉ាប់បាន

ចាត់ទុកតំបន់អាស៊ីអាគ្នេយ៍ថាស្ថិតក្នុងតំបន់ដែលមានភាពរុងរឿងបំផុត នៅលើពិភពលោក នៅក្នុងអំឡុងពេលនោះ។

ក៏ប៉ុន្តែ ជម្លោះផ្ទៃក្នុង ជាពិសេស ជម្លោះដណ្តើមរាជ្យបល្ល័ង្គ បូករួម ជាមួយនឹងការឈ្លានពានពីប្រទេសជិតខាង បានធ្វើឱ្យអាណាចក្រខ្មែរត្រូវ ធ្លាក់ចុះខ្សោយជាបន្តបន្ទាប់ ហើយទឹកដីកាន់តែរួញតូច។ ជាទូទៅ អ្នក ប្រវត្តិសាស្ត្របានកំណត់ថា សម័យកាលរុងរឿងនៃអាណាចក្រខ្មែរបាន ចាប់ផ្តើមពីឆ្នាំ៨០២ ជាមួយនឹងការឡើងគ្រងរាជ្យនៃព្រះបាទជ័យវរ្ម័នទី២ និងបញ្ចប់នៅត្រឹមឆ្នាំ១៤៣១ នៅពេលដែលព្រះបាទស្រីសុរិយោពណ៌ (ឬ ចៅពញាយ៉ាត) សម្រេចចិត្តបោះបង់រាជធានីអង្គរចោល ហើយទៅតាំង រាជធានីនៅស្រីសន្ធរ និងបន្ទាប់មកនៅភ្នំពេញវិញ ដើម្បីគេចចេញពីការ ឈ្លានពានរបស់កងទ័ពសៀម។

# ជំពូកទី៦
# ការវិវត្តបម្លាស់ទីរបស់មនុស្ស និងពិភពលោកពហុប៉ូល

ទីតាំងភូមិសាស្ត្រពិតជាកត្តាដ៏សំខាន់មួយសម្រាប់កំណត់ហេតុការណ៍ដែលកើតឡើងនៅក្នុងប្រវត្តិរបស់ពិភពលោក។ មនុស្សចាប់ផ្តើមធ្វើដំណើរត្រាច់ចរចេញពីទ្វីបអាហ្វ្រិក កាលពីប្រមាណ១សែនឆ្នាំមុនទៅគ្រប់ទិសទីនៃទ្វីបអាហ្វ្រិក និងធ្វើដំណើរទៅទិសខាងជើង សំដៅទៅទ្វីបអឺរ៉ុប និងទៅទ្វីបអាស៊ី។ បន្ទាប់មក មនុស្សដែលនៅអឺរ៉ុប ក៏ចល័តពីទ្វីបអឺរ៉ុប ទៅកាន់ទ្វីបអាស៊ី ហើយមនុស្សនៅទ្វីបអាស៊ី បន្តទៅកាន់ទ្វីបអាម៉េរិក។ មនុស្សក៏ដូចជាភាវៈរស់ដទៃទៀតដែរ ការកំណត់ទីកន្លែងរស់នៅត្រូវបានកំណត់ដោយភាពអំណោយផលនៃធម្មជាតិ មានដូចជា ទឹកសាប ដីមានជីជាតិ និងកត្តាអាកាសធាតុ។



យើងសង្កេតឃើញថា មនុស្សចាប់ផ្តើមប្រមូលផ្តុំគ្នា រស់នៅជាក្រុម រួចក្លាយជាកុលសម្ព័ន្ធ ហើយក្លាយជានគរតាំងពីប្រមាណ៥០០០ឆ្នាំមុនមកម្ល៉េះ។ តើកន្លែងណាដែលមនុស្សចូលចិត្តប្រមូលផ្តុំគ្នារស់នៅច្រើនជាងគេ? បើមើលតាមទីតាំងភូមិសាស្ត្រ មនុស្សភាគច្រើន គឺរស់នៅតាមដងទន្លេ ដែលជាប្រភពទឹកដ៏ចិតថេរមួយសម្រាប់ការប្រើប្រាស់ បរិភោគ ដំណាំដាំដុះ និងចិញ្ចឹមសត្វ។

តាមការពណ៌នារបស់ផែនទី និងផ្អែកលើភូគព្ភសាស្ត្រ តំបន់ខ្ពង់រាបទីបេ គឺជាប្រភពផ្គត់ផ្គង់ទឹកដ៏ធំនៃដងទន្លេជាច្រើន នៅក្នុងប្រទេសចិន ឥណ្ឌា ភូមា និង ទន្លេមេគង្គនៅអាស៊ីអាគ្នេយ៍។ ទន្លេទាំងនោះ ក៏ជាប្រភពនាំដីល្បាប់ដ៏សំខាន់មួយ សម្រាប់វិស័យកសិកម្មនៅតាមបណ្តាប្រទេសជុំវិញវាផងដែរ។ បើគ្មានទន្លេ ស្ទឹងទេ ប្រភពទឹកក៏អត់ដីល្បាប់ដែលមានជីជាតិក៏ខ្សត់ មនុស្សក៏មិនសូវមាន ហើយក្រុមមនុស្សអាចទៅចាប់រកទីកន្លែងផ្សេង ដើម្បីអាចបន្តជីវិតរស់រានបាន ដូចជាតំបន់ជុំវិញបឹង ឬនៅតាមភ្នំដែលមានប្រភពទឹក។

ចំណុចមួយសំខាន់ដែលជាលទ្ធផលពីជីវភូមិសាស្ត្រនេះ គឺចំនួនប្រជាជន។ ប្រមាណជាង ៣ពាន់ឆ្នាំ នៅតំបន់អាស៊ីខាងកើត មនុស្សរស់នៅដោយពឹងផ្អែកប្រភពទឹកពីតំបន់ភ្នំហិមាល័យ តំបន់ខ្ពង់រាបទីបេ គឺមានប្រមាណជាង ៥០% នៃចំនួនប្រជាជនពិភពលោកសរុបក្នុងសម័យកាលនោះ។




នេះមិនមែនជារឿងចៃដន្យឡើយ ព្រោះមនុស្សយើងគ្មានជម្រើសច្រើនប៉ុន្មានទេ ក្នុងការជ្រើសរើសទីតាំងសមរម្យសម្រាប់រស់នៅទូទាំងពិភពលោក។ ម្យ៉ាងវិញទៀត ជាង២ពាន់ឆ្នាំកន្លងទៅ គេមិនដឹងថាមានព្រឹត្តិការណ៍អ្វីកើតឡើងយ៉ាងណានោះទេ តែបណ្ដុំប្រជាជននៅតែមិនមានការផ្លាស់ប្ដូរ ដូចដែលបានបង្ហាញក្នុងរូបភាព។

ចំណុចមួយទៀតពិតជាគួរឱ្យចាប់អារម្មណ៍ គឺទំហំសេដ្ឋកិច្ចតាមតំបន់ទូទាំងពិភពលោកមុនឆ្នាំ១៨២០។ មុនអំឡុងឆ្នាំនោះ សេដ្ឋកិច្ចពិភពលោកគឺពឹងផ្អែកសំខាន់លើវិស័យកសិកម្ម ដែលជាវិស័យស្នូលរបស់ប្រទេសនីមួយៗ។ រូបភាពឧស្សាហកម្មមិនទាន់មានចេញជារូបរៀងនៅឡើយទេ លុះដល់មានរបកគំហើញម៉ាស៊ីនដើរដោយចំហាយទឹកចេញពីចក្រភពអង់គ្លេស ទើបធ្វើឱ្យមានបដិវត្តន៍ឧស្សាហកម្មកើតមានឡើង។ ដូចនេះមានន័យថាមុនបដិវត្តន៍ឧស្សាហកម្ម ប្រទេសដែល

មានដែនដីអំណោយផលលាតសន្ធឹងធំជាង ដែនដីនោះគឺនឹងអាចបង្កើតមនុស្សបានច្រើនជាង។ យើងមិនគួរគិតអំពីកត្តាសម្រស់ទេសភាពចូលនោះទេ សំខាន់ឱ្យតែមានអំណោយផលអាចឱ្យមនុស្សរស់នៅបាន។ម្យ៉ាងទៀតផែនទីភូមិសាស្ត្រពិភពលោក មិនមែនមានតែតំបន់ជុំវិញខ្ពង់រាបទីបេ ភ្នំហេមពាន្តនោះទេ ដែលជាទីតាំងអំណោយផលជាងគេសម្រាប់មនុស្សរស់នៅបាន ដែលអាចពន្លឿនកំណើនប្រជាជនច្រើនជាងតំបន់អឺរ៉ុប និងអាហ្វ្រិក។ សម្រាប់ទ្វីបអាម៉េរិក គឺត្រូវបានខណ្ឌពីទ្វីបអឺរ៉ុបអាស៊ី ដោយមហាសមុទ្រអាត្លង់ទិកនៅផ្នែកខាងលិច និងដោយមហាសមុទ្រប៉ាស៊ីហ្វិកនៅប៉ែកខាងកើត។ ដូចនេះ មានការប្រាស្រ័យទាក់ទងរវាងមនុស្សនឹងមនុស្ស និងការធ្វើចំណាកស្រុករបស់មនុស្សទៅទីដីថ្មីនេះគឺមានតិចតួចមែនទែន លុះដល់សតវត្សទី១៥ ទើបយើងចាប់ផ្តើមរកឃើញទ្វីបនេះដោយការធ្វើនាវាចររបស់លោកខាងលិច ហើយក៏មានមនុស្សចាប់ផ្តើមរស់នៅជាបន្តបន្ទាប់។

យើងអាចនិយាយឱ្យងាយស្រួលយល់ថា មុនឆ្នាំ ១៨២០ ក្នុងមនុស្ស ៥នាក់ មាន៣នាក់ហើយ ដែលមកពីតំបន់ជុំវិញទីបេ សេសសល់ប៉ុន្មានគឺមកពីគ្រប់ទិសទីនៃពិភពលោក។

ពិភពលោកក៏ចាប់ផ្តើមមានការផ្លាស់ប្តូរដ៏ធំមួយក្នុងប្រវត្តិសាស្ត្រមនុស្សលោកក្នុងពេល២ពាន់ឆ្នាំចុងក្រោយនេះ គឺបដិវត្តន៍ឧស្សាហកម្ម និងការធ្វើអាណានិគមរបស់លោកខាងលិចទៅលើសកលលោក។ នេះជាពេលមួយដ៏អាម៉ាស់មុខ សម្រាប់បណ្តាប្រទេសនៅតំបន់ជុំវិញទីបេដែលដាំក្បាលសេដ្ឋកិច្ចដល់ថ្នាក់ងើបមុខមិនចង់រួច ដោយខ្លួនធ្លាប់ជា

មហាប្រទេសក្នុងសាកលលោក និងមានវប្បធម៌ចាស់ទុំយូរអង្វែងជាងប ណ្តាប្រទេសនៅលោកខាងលិច។

កត្តាដែលធ្វើឱ្យប្រទេសភាគច្រើននៅអាស៊ីចុះទន់ខ្សោយ រួម មានដូចខាងក្រោម៖

- ប្រជាជនអាស៊ីមួយចំនួនធំនៅក្រោមការគ្រប់គ្រងរបស់អឺរ៉ុប ដែលជាការពន្យឺតល្បឿនអភិវឌ្ឍន៍សេដ្ឋកិច្ច
- ចំណេះដឹងរបស់ប្រជាជនអាស៊ីនៅមានកម្រិតទាប ខាងផ្នែក វិទ្យាសាស្ត្រ និងផ្នែកឧស្សាហកម្ម
- ការពង្វក់ផ្នែកមនោគមន៍វិជ្ជាពីសំណាក់លោកខាងលិច
- សង្គ្រាមអាភៀនរវាងអង់គ្លេសនិងចិនលើដែនដីចិន

បើមើលរូបភាពបង្ហាញនូវទំហំសេដ្ឋកិច្ចតាមតំបន់នីមួយៗ គេ អាចប្រៀបធៀបពីឆ្នាំ១ ដល់ឆ្នាំ ១៨២០ ទំហំសេដ្ឋកិច្ច គឺអាស្រ័យទៅលើ ទំហំប្រជាជន និងបូករួមវិស័យស្នូលក្នុងសម័យកាលនោះជាវិស័យកសិ កម្ម។ ក្រោយឆ្នាំ ១៩២០ វិស័យស្នូលរបស់សាកលលោកមិនមែនជា កសិកម្មទៀតនោះទេ ប៉ុន្តែគឺឧស្សាហកម្ម។ គេអាចមើលឃើញយ៉ាង ជាក់ស្តែងអំពីសមិទ្ធិផល នៅក្រោយពេលដែលប្រទេសអាស៊ីសម្រេច បដិវត្តន៍ឧស្សាហកម្មក្នុងតំបន់ បានដោយជោគជ័យ។

បើគេអាចសង្កេតមើលឃើញ សេដ្ឋកិច្ចនៅតំបន់អាស៊ីមានសន្ទុះ លឿនរហ័សក្លៀវក្លាណាស់ បន្ទាប់ពីទទួលបានអធិបតេយ្យភាពពីលោក ខាងលិចវិញ។ ដំបូងមានការកែសម្រួលការដឹកនាំនិងគ្រប់គ្រងនៅក្នុង ប្រទេស បន្ទាប់មកអភិវឌ្ឍធនធានមនុស្សចុងក្រោយគឺការបញ្ចូលខ្លួន ទៅនឹងពិភពលោកថ្មីមួយ គឺពិភពលោកក្នុងយុគសម័យឧស្សាហកម្ម។

ជោគជ័យរបស់ប្រទេសអាស៊ីខាងកើតមួយ នៅសម័យមីហ៊ិជិ បន្ទាប់ពីប្រទេសជប៉ុនបានបាត់បង់តម្លៃមតិខ្លួនលើឆាកអន្តរជាតិ ក្រោមការសម្លុតបើកច្រកពាណិជ្ជកម្មឱ្យលោកខាងលិចធ្វើជំនួញ អធិរាជរបស់ជប៉ុនក៏បានប្រកាសសម័យកាលថ្មីមួយឡើងគឺ គំនិតជប៉ុន បច្ចេកវិទ្យាលោកខាងលិច (Japanese Spirit, Western Technology)។ ជាទូទៅមានការយល់ឃើញថា ដើម្បីឱ្យប្រទេសមួយមានភាពបិតថេរបាន លុះត្រាតែចាប់ផ្តើមអភិវឌ្ឍវិស័យឧស្សាហកម្ម ពីព្រោះពិភពលោកមិនដូចមុនទេ តួអង្គថ្មីមានច្រើន និងវិស័យគោលក៏មានការផ្លាស់ប្តូរ។ មួយវិញទៀត អត្ថប្រយោជន៍នៃការអភិវឌ្ឍប្រជាជាតិខ្លួនជាង ២៥០០ឆ្នាំ គឺបានពង្រឹងផ្នែកស្មារតី មេរៀនសម្រាប់ជីវិតរស់នៅក្នុងបណ្តុំមនុស្សច្រើន និងភាពយកចិត្តទុកដាក់នឹងការងារ។ នេះមិនមានន័យថាលោកខាងលិចមិនយកចិត្តទុកដាក់ចំពោះប្រទេសអាស៊ីទាំងអស់ ដូចនឹងជប៉ុនទាំងអស់នោះទេ។ បើយើងមើលពេលបច្ចុប្បន្ន ដូចជាការផលិតរថយន្តនៅជប៉ុនគឺធ្វើបានគុណភាពល្អនិងបរិមាណច្រើន ថ្លៃ(price)ទាបជាង តែគុណភាពអាចប្រហាក់ប្រហែលឬស្មើទៅនឹងផលិតផលមកពី ប្រទេសអាល្លឺម៉ង់ បារាំងឬអង់គ្លេសដែរ។ លទ្ធផលនេះ មិនមែនសុទ្ធតែចេញពីលោកប្រធានក្រុមហ៊ុនទាំងអស់នោះទេ តែជាលទ្ធផលចេញពីភាពយកចិត្តទុកដាក់ និងភាពអត់ធ្មត់របស់បុគ្គលិកនៅគ្រប់ផ្នែក ក្រោមវប្បធម៌គ្រប់គ្រងតាមបែបផែនរបស់ជនជាតិអាស៊ី។ ក្រុមហ៊ុន GM ក៏ធ្លាប់ទទួលស្គាល់ថា បច្ចេកវិទ្យាមិនលើសខ្វះគ្នាប៉ុន្មានទេ តែកម្លាំងពលកម្មនៅអាស៊ីមានភាពតស៊ូជាង។ ការលើកឡើងនេះ មិនមែននិយាយកាន់ជើងអាស៊ីនោះទេ តែវាជាការពិតមួយដែលប្រកែកមិនបាន។ ជនជាតិអាស៊ី

មិនមែនជាជនជាតិអន់ខ្សោយជាងជនជាតិអឺរ៉ុបទេ ពីព្រោះមនុស្សទាំងអស់មានដើមកំណើតចេញពីអាហ្វ្រិកដូចតែគ្នាទេ ទន្ទឹមនឹងនេះក៏មានប្រទេសជាច្រើនទៀតនៅតំបន់អាស៊ី កំពុងនិងសម្រេចបាននូវបដិវត្តន៍ឧស្សាហកម្ម ដូចជាប្រទេសចិន កូរ៉េ ជាដើម។

**២. បម្រែបម្រួលពិភពលោកក្រោយឆ្នាំ ១៨២០**

បន្ទាប់ពីសម័យអាណានិគមត្រូវបានបញ្ចប់ ដំណើរការសកលភាវូនីយកម្មក៏ចាប់ដំណើរការឡើងជាបន្តបន្ទាប់រហូតដល់ឆ្នាំ ២០០១ ក្រោយប្រទេសចិនដីគោកបានចូលជាសមាជិក WTO។ ក្នុងសម័យនេះមិនមែនដូចពីសម័យមុន គេដើរធ្វើសង្គ្រាមឈ្លានពានគ្នាដណ្ដើមទឹកដីទៀតនោះទេ។ ក្រោយសង្គ្រាមលោកលើកទី២ ព្រំដែនដីគោកត្រូវបានកំណត់ ភាពហត់នឿយដោយសារសង្គ្រាមក៏ហាក់ដូចជាបានធូរស្រាល ពិភពលោកក៏ចាប់ផ្ដើមប្រែមុខមាត់ថ្មីក្រោមការប្រកួតប្រជែងថ្មី នៅក្នុងវិស័យវិទ្យាសាស្ត្រនិងឧស្សាហកម្ម។ លោកខាងលិចធ្លាប់បានគិតថាប្រវត្តិសាស្ត្រពិភពលោកត្រូវបានដើរដល់ទីបញ្ចប់ ក្រោយពេលការដួលរលំរបបដឹកនាំរបស់សហភាពសូវៀត។ នេះជាការមួយដែលមើលរំលង និងមើលស្រាលនៃកម្លាំងរបស់អាស៊ី ក្នុងការដឹកនាំពិភពលោកតាមបែបផែនផ្សេង។ លោកខាងលិចបានគិតថាខ្លួនបានសម្រេចនូវនគរូបនីយកម្មនិងគិតថា ប្រទេសដែលនៅតំបន់ផ្សេងទៀត នឹងដើរតាមផ្លូវមួយនេះដូចខ្លួន។ ធាតុពិតទៅ ការយល់ឃើញរបស់លោកខាងលិច គ្រាន់តែជាផលិតផលចេញពីបស្នឹមភាវូនីយកម្មក្រោមគោលការណ៍ប្រជាធិបតេយ្យតាមបែបផែនអឺរ៉ុប។ ថ្នាក់ដឹកនាំនៅក្នុងប្រទេសតំបន់អាស៊ីធ្លាប់បានលើកឡើងថា ប្រជាធិបតេយ្យនៅតំបន់អាស៊ីគឺខុសគ្នាពីប្រជាធិបតេយ្យ

នៅអឺរ៉ុប ដែលត្រូវច្របាច់ចូលនូវកត្តាវប្បធម៌ ស្ថានភាពជាក់ស្តែងនៅក្នុងសង្គម និងផ្ទត់គំនិតរបស់អាស៊ីចូលទៅក្នុងនោះផងដែរ។ ប្រជាធិបតេយ្យគឺជារូបមន្តមួយដ៏ល្អសម្រាប់ដឹកនាំប្រទេស ប៉ុន្តែក៏គេត្រូវកែសម្រួលខ្លះដើម្បីឱ្យវាមានប្រសិទ្ធភាព ស្ថេរភាព និងនិរន្តភាព ពេលយកមកប្រើប្រាស់លើប្រជាជាតិអាស៊ី។ នេះមិនមានន័យថាប្រជាធិបតេយ្យអាស៊ីល្អជាងអឺរ៉ុបនោះទេ ប្រជាធិបតេយ្យគ្រាន់តែជាស្ពានចម្លងសម្រាប់គំនិតល្អៗ ចូលរួមមកអភិវឌ្ឍប្រទេសជាតិប៉ុណ្ណោះ។ តើជាការត្រឹមត្រូវទេ ដែលគេថាចិនដីគោកមិនឱ្យតម្លៃដល់ការបញ្ចេញមតិ និងសិទ្ធិមនុស្ស ដូចដែលប្រទេសលោកខាងលិចមួយចំនួនបានចោទជាសំណួរឡើង។ នេះថា គ្រាន់តែជាការប៉ែងជើងគ្នាឱ្យដួលតែប៉ុណ្ណោះ បើការបញ្ចេញមតិមិនត្រូវបានឱ្យតម្លៃ សិទ្ធិមនុស្សមិនបានគោរព ចិនដីគោកមិនអាចលុបបំបាត់ភាពក្រីក្ររបស់ប្រជាជនជាង ៦០០លាននាក់បាននោះទេ ក្នុងត្រឹមរយៈពេលប្រមាណ៣០ឆ្នាំប៉ុណ្ណោះ។ ភាពអយុត្តិធម៌ជាច្រើន ក៏នៅមានដែរក្នុងប្រទេសចិននោះ តែបើគេកុំប្រើអារម្មណ៍យកមកវិភាគ សកម្មភាពទាំងនេះ គឺដើម្បីប្រយោជន៍ជារួមសម្រាប់ប្រទេសជាតិជាក់ស្តែងដូចជាការបំបាត់ភាពក្រីក្រនៅក្នុងប្រទេសចិនជាដើម។ គេតែងគិតថាអាស៊ីគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន និងឈ្នានីសគ្នា ជាពិសេស នៅប្រទេសចិន។ តែគេត្រូវដឹងប្រវត្តិសាស្ត្រមួយជាមុនសិន មុននឹងសន្និដ្ឋានបែបនេះ។ មុនបដិវត្តន៍ឧស្សាហកម្ម ប្រទេសអង់គ្លេសនិងបារាំងបានធ្វើសង្គ្រាមជាមួយគ្នាជាង១០០ដង នៅពេលតែមួយ ប្រទេសចិនមានសង្គ្រាមធំតែមួយដងគត់ គឺជាមួយវៀតណាម។ នេះគ្រាន់តែជា

ឧទាហរណ៍មួយប៉ុណ្ណោះ ពីព្រោះអាកប្បកិរិយារបស់មនុស្សជំនាន់ក្រោយ ត្រូវបានកំណត់ពីការអប់រំក្នុងគ្រួសារនិងសាលារៀន។

តាមការព្យាករណ៍ ចំណុចកណ្តាលនៃសេដ្ឋកិច្ចពិភពលោកគឺកំពុងរំកិលមកកាន់អាស៊ី។ ការបម្លាស់ទីនេះ អ្នកវិភាគជឿជាក់ថា គឺជាការបញ្ចូលខ្លួនរបស់ប្រជាជាតិអាស៊ី ទៅនឹងបដិវត្តន៍ឧស្សាហាកម្ម ដូចដែលលោកខាងលិចបានសម្រេចកាលពីសតវត្សមុនមកនេះ ហើយបានជួយលោកខាងលិចក្លាយជាមហាអំណាចពិភពលោកដូចពេលកន្លងមកនិងកំពុងបន្ត។ ប៉ុន្តែមិនមានន័យថា ស្ថានភាពនេះបានថិតថេរនោះទេ ពីព្រោះមនុស្សនៅក្រៅអឺរ៉ុប ជាពិសេសអាស៊ី ក៏មានសមត្ថភាពអនុវត្តលើវិស័យឧស្សាហាកម្មបានដូចគ្នា។ នេះជាចំណុចមួយដ៏សំខាន់ នៅពេលអាស៊ីសម្រេចបដិវត្តន៍នេះបាន។ ការកំណត់ទំហំសេដ្ឋកិច្ច ការកំណត់ចំណុចកណ្តាលនៃពិភពលោក ការកំណត់ឥទ្ធិពល គឺអាស្រ័យទៅនឹងបរិមាណមនុស្ស និងការកំណត់វិស័យស្នូលក្នុងតំបន់ ដូចដែលបានកើតឡើងក្នុងសម័យកសិកម្មដូច្នោះដែរ។

តាមរូបភាពខាងក្រោម យើងអាចសន្មតបានថា ពិភពលោកកំពុងរំកិលទៅរកភាពដើម តំបន់នៅជុំវិញតំបន់ទីបេនៅតែជាតួអង្គសំខាន់នៅក្នុងពិភពលោក។ មានការពិភាក្សាគ្នាច្រើនណាស់អំពីបញ្ហាទាំងនេះ ការត្រៀមខ្លួននៃលោកខាងលិចនិងអាម៉េរិក សម្រាប់ពិភពលោកថ្មីមួយលទ្ធភាពនៃការបញ្ចៀសសង្គ្រាម រវាងសហរដ្ឋអាម៉េរិកនិងចិន តើពិភពលោកថ្មីមានរូបភាពយ៉ាងដូចម្តេច នៅពេលប្រទេសទាំងអស់ក្លាយជាប្រទេសមានការអភិវឌ្ឍខ្ពស់?។




សំណួរទាំងអស់នេះ ត្រូវការនូវចម្លើយឆ្លើយច្បាស់និងត្រឹមត្រូវ ដែលត្រូវការការសិក្សាស៊ីជម្រៅ។ នេះជាប្រធានបទដ៏សំខាន់សម្រាប់ប្រទេសកម្ពុជាផងដែរ ដែលត្រូវដើររបៀបណាឱ្យមានលំនឹង និងត្រៀមខ្លួនអ្វីខ្លះសម្រាប់សាកលលោកដែលកំពុងប្រែប្រួលមុខមាត់ថ្មីនេះ។

# ជំពូកទី៧
# មានមនុស្សទើបមានសេដ្ឋកិច្ច

## I- ការកកើតសេដ្ឋកិច្ចលើភពផែនដី

ដំណើរការសេដ្ឋកិច្ចដ៏មមាញឹកពេលបច្ចុប្បន្ននេះ គេហាក់ដូចជាមិនបានចាប់អារម្មណ៍អំពីមូលហេតុនិងចំណុចចាប់ផ្តើមទេ។ មនុស្សម្នាក់ៗ ប្រទេសនីមួយៗ គិតតែពីខំរិះរកមធ្យោបាយទ្រទ្រង់កំណើនសេដ្ឋកិច្ច ខំទប់អតិផរណា ជំរុញឱ្យមានកំណើនការនាំចេញ ។ល។ ប៉ុន្តែគេមិនបានគិតថា តើប្រភពដើមនៃសេដ្ឋកិច្ច ចេញមកពីណា តើអ្នកណាជាអ្នកបង្កើតនូវសកម្មភាពសេដ្ឋកិច្ចទាំងអស់នេះ នៅលើភពផែនដី។

ជាការពិត សត្វមិនអាចបង្កើតសេដ្ឋកិច្ចបានទេ សត្វមិនអាចបង្កើតទំនិញ មិនអាចបង្កើតខ្សែច្រវាក់ផលិតកម្ម (Production Chain) មិនអាចបង្កើតសេវាកម្ម ។ល។ ដោយសារសត្វមិនចេះនិយាយទាក់ទងគ្នា ផ្លាស់ប្តូរបទពិសោធន៍ សត្វមិនអាចបង្កើតពលកម្ម សត្វមិនមានវិចារណញាណ មិនចេះគិតពិចារណាដូចមនុស្សទេ។

តាំងពី២៤៣លានឆ្នាំមុនមកម្ល៉េះ ជំនាន់មានសត្វ ដាយណូស័រ (Dinosaurs) និងមានសត្វមានជីវិតនានា រស់នៅពេញពិភពលោក សត្វទាំងនោះមិនអាចបង្កើតជា ប្រព័ន្ធនៃសេដ្ឋកិច្ចបានទេ។ ជំនាន់នោះ គ្មានការលក់ដូរ គ្មានការផលិតទំនិញទេ។ ៦៥លានឆ្នាំក្រោយ ពីជំនាន់សត្វដាយណូស័រ រហូតមកដល់២ម៉ឺនឆ្នាំមុននេះ ក៏មិនទាន់មានប្រព័ន្ធសេដ្ឋកិច្ច ឬដំណើរការសេដ្ឋកិច្ចនៅឡើយដែរ ។

ទាល់តែមានការចាប់ផ្តើមការបែងចែកពលកម្ម (division of labor) គឺមនុស្សមួយក្រុមទៅបរបាញ់សត្វ មនុស្សមួយក្រុមទៅរកបន្លែ ផ្លែឈើ

ដំឡូង ឬក៏ជួយមើលកូននៅក្នុងរូងភ្នំឬលំនៅឋាន។ នេះជាការវិវត្តនៃសង្គមបុរេបុព្វកាល បន្ទាប់មកសង្គមទាសករ មានមនុស្សរស់នៅជាក្រុមជាមួយនឹងការកកើតភាសាផ្លាស់ប្តូរយោបល់គ្នា មានការផ្លាស់ប្តូររបស់របរ ត្រីសាច់ ។ល។ នេះទើបមានសេដ្ឋកិច្ចទម្រង់ដំបូងចាប់ផ្តើមកកើតឡើង។

តាមការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ គេរកឃើញផ្សេង ខុសពីគម្ពីរសាសនានានាដែលបានសរសេរកន្លងមក គឺថាតាមការសិក្សាសត្វស្វា (chimpanzee) ដែលចាប់ផ្តើមក្លាយជាមនុស្សកើតមានតាំងពី២លានឆ្នាំមក។ មនុស្សបានរកឃើញភ្លើងប្រហែលជា ៤-៥សែនឆ្នាំ។ ទើបតែប្រមាណជា ៧-៩ពាន់ឆ្នាំទេ ទើបបានមនុស្សចាកចេញពីសង្គមបុព្វកាលមកជាសង្គមទាសករ ទៅតាមតំបន់។ ពេលនោះទើបមានការបែងចែកពលកម្មកាន់តែច្រើន ការចិញ្ចឹមសត្វ និងការធ្វើស្រែចម្ការ ការបង្កើតជាទំនិញ ការប្តូរផ្តោះទំនិញ និងការកើតមានសេវានានា ជាបន្តបន្ទាប់។ អារ្យធម៌ចំណាស់ៗ គេរកឃើញមាននៅ អេហ្ស៊ីប ចិន ឥណ្ឌា ។ល។

មនុស្សចេះបង្កើតជា ឧបករណ៍ ដូចជា ដុំថ្ម ឈើស្រួចៗ... ដែលជាលក្ខណៈពិសេស ធ្វើឱ្យមនុស្សបែកចេញពីសត្វ (making tool) 25។ គេបានរកឃើញមានសំណល់ពីមនុស្សជំនាន់ អូម៉ូ អាប៊ីលីស (Homo habilis – Handy man) កាលពី ២,៥លាន ឆ្នាំមុន នៅភាគខាងកើតនៃទ្វីបអាហ្វ្រិក ។

25 Kenneth Oakley article, anthropologist, 1994



## ទស្សនៈពាក់ព័ន្ធមូលដ្ឋានសេដ្ឋកិច្ច «មានមនុស្សទើបមានទំនិញ»

សព្វថ្ងៃនេះ ជាទូទៅមនុស្សរស់នៅមានភាពខុសពីសត្វ។ មនុស្ស ចេះគិត ចេះពិចារណា ចេះនិយាយប្រាប់គ្នាទៅវិញទៅមក។ ពិតមែនតែ មនុស្សបានចាកចេញពីសត្វរាប់ម៉ឺនឆ្នាំមកហើយ តែអត្តចរិត និងសភាវៈ គតិពីកំណើត នៅមិនទាន់ឃ្លាតចេញឆ្ងាយពីបុព្វការីជននៅឡើយទេ។

ដើម្បីជួយបង្កភាពងាយស្រួលក្នុងការរស់នៅ មនុស្សត្រូវការ និង បង្កើតជាឧបករណ៍សម្ភារៈ វត្ថុនានា ជាច្រើន។ មនុស្សត្រូវការទំនិញ ផលិតផល ដែលបានពីការប្តូរផ្តោះគ្នាជាមួយអ្នកផលិត មនុស្សត្រូវការ ស្បៀង ស្រូវ អង្ករ បន្លែ ម្ហូបអាហារ ... និងសេវានានាដទៃទៀត។

ទំនិញជាផ្នែកមួយសំខាន់នៃសេដ្ឋកិច្ច។ តើទំនិញជាអ្វី? តើសត្វ អាចបង្កើតទំនិញបានឬទេ?

**ទំនិញ** (merchandise/goods): ទំនិញ គឺជាផល(ឬផលិតផល) នៃ «ពលកម្ម» សម្រាប់ប្តូរផ្តោះ តាមរយៈការទិញ លក់។ ផលិតផលនៃ

ពលកម្មចាប់ផ្តើមមកកើតឡើងជាទំនិញ ជាមួយនឹងការលេចឡើងនៃ *ការបែងចែកពលកម្មសង្គម* ដោយពួកផលិតករឯកជន (កម្មសិទ្ធិករផ្សេងៗគ្នានៃមធ្យោបាយផលិតកម្ម នាជំណាក់កាលនៃការរលាយទៅនៃរបបសង្គមបុរេបុព្វកាល និងការកកើតនៃរបបទាសភាព) ។

**ពេលវេលាវិវត្តនៃសង្គមមនុស្ស**




**របបទាសភាព** (slavery) មានតាំងពី ១១,០០០ឆ្នាំមុនមកម្ល៉េះ តាំងពីចាប់ផ្តើម ការបង្កើតវិស័យកសិកម្ម (invention of agriculture) នាសម័យបដិវត្តន៍ នីអូលីធីក (Neolithic Revolution)។ ឈ្មោះ សម័យសាមើ (Sumer) មាននៅ ប្រទេស អេហ្ស៊ីប ចិន ឥណ្ឌា ក្រិក អ៊ីរ៉ង់ បាប៊ីឡូន រ៉ូមាំង អារ៉ាប់ ...។

សង្គមនីមួយៗ ប្រទេសនីមួយៗ តែងតែឆ្លងកាត់របបទាសភាព ដោយការចាប់មនុស្ស យកមកប្រើដើម្បីធ្វើសកម្មភាពលំបាកៗជំនួសខ្លួន។ កាលពីបុរាណ គេយល់ថា ការប្រើឬការទិញលក់ទាសករ ជាការធម្មតា។ ទើបតែសម័យបច្ចុប្បន្នទេ គេយល់ថា ជាការជិះជាន់មនុស្សលើមនុស្ស។ តែបើមនុស្សប្រើសត្វ ដូចជា គោ ក្របី ដំរី សេះ ជាដើម មិនអីទេ មិនទាន់មានច្បាប់ហាមឃាត់នៅឡើយទេ។



c. 1480 BC, fugive slave treaty between Idrimi of Alakakh (now Tell Atchana) and Pilla of Kizzuwatna (now Cilicia)



Slaves in chains under Roman rule, at Smyrna (present-day İzmir), 200 CE.

សិលាចារឹកនិងរូបចម្លាក់បង្ហាញពីរបបទាសភាព

តើពលកម្មជាអ្វី?

**ពលកម្ម** (travail/labor): តាមន័យសង្គម-សេដ្ឋកិច្ច ពលកម្ម គឺជាសកម្មភាពប្រកបដោយមនសិការនិងវិចារណញ្ញាណ (conscience) របស់មនុស្ស សំដៅកែប្រែកម្មវត្ថុនៅក្នុងធម្មជាតិ ឱ្យបំពេញទៅតាមសេចក្តីត្រូវការរបស់ខ្លួន។ នៅក្នុងដំណើរការ(process)នៃពលកម្ម មានការចាយថាមពលកាយនិងខួរក្បាលរបស់មនុស្ស។ លទ្ធផលនៃពលកម្មគឺ

វត្ថុ ឧបករណ៍ របស់របរ ផលនានា ចាំបាច់សម្រាប់បំពេញសេចក្តីត្រូវការរបស់មនុស្ស។

**ពលកម្ម** ជាលក្ខខណ្ឌទីមួយនិងជាសារវន្តសម្រាប់អត្ថិភាពរបស់មនុស្ស។ ដោយសារគុណនៃពលកម្មនេះ ទើបមនុស្សអាចឈានចេញពីពិភពសត្វបាន។ មនុស្សអាចបង្ក្រាបកម្លាំងធម្មជាតិ និងប្រើប្រាស់វាដើម្បីបម្រើប្រយោជន៍របស់ខ្លួន។

ក្នុងពេលបំពេញការងារ ដើម្បីធានាបាននូវមធ្យោបាយអត្ថិភាព (moyens d'existence) មនុស្សនិងមនុស្សបានបង្កើតនូវទំនាក់ទំនងផលិតកម្ម។ ចរិតលក្ខណៈនៃពលកម្ម និងទម្រង់នៃសម្ព័ន្ធរវាងកម្លាំងពលកម្ម និងមធ្យោបាយផលិតកម្ម គឺពឹងផ្អែកទៅតាមបែបផែនពលកម្ម។

**ភាពខុសគ្នារវាងថ្លៃនិងតម្លៃ**

នៅក្នុងភាសាខ្មែរយើង ពាក្យ២នេះស្រដៀងគ្នាណាស់ ដែលជាធម្មតាធ្វើឱ្យគេមានការភ័ន្តច្រឡំ តែសម្រាប់ភាសាបរទេសវិញ ដូចជាអង់គ្លេសឬបារាំង គឺខុសគ្នាស្រឡះ (price-value)។

**ថ្លៃ** (prix/price): គឺជាតម្លៃទំនិញគិតចេញជាប្រាក់/លុយ។ ឧទា. ថ្លៃនៃសៀវភៅនេះ គឺ២ម៉ឺនរៀល ។

**តម្លៃ** (valeur/value): បរិមាណពលកម្មសង្គមចាំបាច់ បានចាយក្នុងការផលិតទំនិញ (ឬសេវា)[26]។ ឧទា. ស្នាដៃនេះ មានតម្លៃខ្ពស់ណាស់

[26] និយមន័យតាមនិន្នាការរបស់ Adam Smith, Feuerbach, Saint-Simon, Hegel,..

មិនអាចកាត់ស្មើបានទេ។ វត្ថុមួយឬទំនិញមួយ ទាល់តែយកទៅដាក់លក់នៅលើទីផ្សារ ទើបដឹងថាមានថ្លៃប៉ុន្មាន។

**<u>គំនិតគួរពិចារណា៖</u>**

**១- ខ្យល់** ៖ ខ្យល់ធម្មជាតិ មិនមានតម្លៃ(ជាលុយ)ទេ (មានតែសារៈសំខាន់) ព្រោះគ្មានពលកម្ម(របស់មនុស្ស) នៅក្នុងនោះ។ មនុស្ស សត្វកើតមកដកដង្ហើមដោយសេរី មិនបានទិញឬសុំពីអ្នកណាទេ។ ទាល់តែមនុស្សចាយពលកម្ម ប្រើកម្លាំងទៅចាប់យកខ្យល់នោះមកកែឆ្នៃ យកមកសប់កង់ឡានឬម៉ូតូ... ទើបបានខ្យល់មានតម្លៃ ហើយបន្ទាប់មកទើបនិយាយតថ្លៃគ្នាបាន ។

**២- សម្បុកឃ្មុំ**៖ គេថាសត្វឃ្មុំឆ្លាត តែនៅក្នុងព្រៃ ទឹកឃ្មុំគ្មានតម្លៃទេ ពីព្រោះវាធ្វើសម្បុកទៅតាមសភាវគតិរបស់វា តាំងពីរាប់សែនលានឆ្នាំមកហើយ ទាល់តែពេលណាដែលមនុស្សចាយពលកម្ម ទៅបេះពីព្រៃ ហើយយកមកដាក់លក់នៅទីផ្សារ ទើបសម្បុកឃ្មុំមានតម្លៃ និងកើតចេញជាថ្លៃ។

**៣- ដី** ៖ មិនមានតម្លៃទេ ព្រោះមិនមែនជាផលិតផលនៃពលកម្ម (របស់មនុស្ស)។ សព្វថ្ងៃដីជាកម្មវត្ថុនៃការទិញលក់ គឺដោយសារមនុស្សទៅបោះបង្គោល កំណត់ថាជាកម្មសិទ្ធិរបស់ខ្លួន។ មនុស្សលក់សិទ្ធិនៃការទទួលអត្ថប្រយោជន៍ពីដី។ មនុស្សគិតថា បើគេយកលុយទៅដាក់នៅធនាគារ ឬយកលុយទៅទិញដី តើមួយណាបានការប្រាក់ច្រើនជាង ។ល។

- មនុស្សអង្គុយច្រៀងម្នាក់ឯង មិនទាន់បង្កើតបានជាថ្លៃ (price) ទេ គឺច្រៀងដើម្បីឱ្យបានសប្បាយចិត្តខ្លួនឯង។

- សត្វចាបឃុំនៅក្នុងព្រៃ ស្នូរទឹកធ្លាក់នៅក្នុងព្រៃ.. បើគ្មានមនុស្ស ទៅស្ដាប់ទេ គឺមិនពិរោះ គ្មានតម្លៃទេ។

- កាំបិត ពូថៅ ដែលបុរសម្នាក់ផលិតបាន ហើយប្រើប្រាស់ក្នុងផ្ទះ មិនមែនជាទំនិញទេ។ ទាល់តែគាត់យកទៅធ្វើការប្ដូរផ្ដោះនៅទីផ្សារ ទើបកាំបិតពូថៅ នោះក្លាយទៅជាទំនិញ ។

- ស្លាបព្រាដែក និងស្លាបព្រាមាស មានតម្លៃដូចគ្នា ដោយសារការចាយពលកម្មក្នុងការផលិតដូចគ្នា តែដល់យកទៅធ្វើការប្ដូរផ្ដោះ ទើបស្លាបព្រាមាសថ្លៃជាងស្លាបព្រាដែក ដោយសារភាពកម្រនៃមាស ដោយសារភាពថ្លៃថ្នូរក្នុងការប្រើប្រាស់ ។ល។

**សេវា** (service): ផលនៃពលកម្មដែលអរូបី សំដៅបម្រើភាពងាយស្រួលដល់អ្នកប្រើប្រាស់ និងអាចធ្វើឱ្យវត្ថុដែលមានស្រាប់កែប្រែរូបរាង/គុណភាព ។

ផលនៃសេវា គឺអរូបី មិនអាចសន្សំ រក្សាទុក និងដឹក ជញ្ជូន បានទេ ។

**ប្រាក់/លុយ** (monnaie/money): ទំនិញពិសេស (ជាលោហៈឬជាក្រដាស់ដែលមានសញ្ញាពិសេស) ជាខ្នាតវាស់តម្លៃក្នុងពេលទិញលក់ និងមានតួនាទីជាសមមូលទូទៅ (qui joue le rôle d'équivalent general) ពោលគឺបង្ហាញនូវតម្លៃនៃទំនិញ និងសេវា។

ប្រាក់(លុយ) ជាទំនិញពិសេស លុយក្លាយបន្តិចម្ដងៗពីរូបីទៅអរូបី។ យើងសង្កេតឃើញថា អគ្គិសនី ជាទំនិញអរូបី ពេលកុងទ័រវិលទើបគេគិតជាលុយ។ ការលក់ដូរមួយទៀត ដូចជា កាសែតថតសម្លេងលោកស៊ិន ស៊ីសាមុត ក៏ជាទំនិញ។ ពេលទិញ ហើយយកទៅចាក់ស្ដាប់ទើបឮ

សូរចម្រៀង ដែលជាកម្មសិទ្ធិបញ្ញា។ ជាទូទៅ ទំនិញជារូបីយ រីឯសេវាជាអរូបី។

## II- ប្រព័ន្ធសេដ្ឋកិច្ចពិភពលោក (Economic Systems)

សេដ្ឋកិច្ចពិភពលោក បានវិវត្តពីមួយថ្ងៃទៅមួយថ្ងៃដោយសារការផ្លាស់ប្តូរនៃគំនិតរបស់មនុស្ស ដែលរហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រព័ន្ធសេដ្ឋកិច្ចពិភពលោក ត្រូវបានគេស្គាល់និងចែកចេញជា ៤ប្រភេទធំៗ (types of economic system) គឺ៖

- ប្រព័ន្ធសេដ្ឋកិច្ចបែបប្រពៃណីឬសេដ្ឋកិច្ចបុរាណ
- ប្រព័ន្ធសេដ្ឋកិច្ចផែនការ
- ប្រព័ន្ធសេដ្ឋកិច្ចផ្សារ
- ប្រព័ន្ធសេដ្ឋកិច្ចចម្រុះ

### ១. ប្រព័ន្ធសេដ្ឋកិច្ចបែបប្រពៃណីឬសេដ្ឋកិច្ចបុរាណ (Traditional Economic System)

ប្រព័ន្ធសេដ្ឋកិច្ចបែបប្រៃណីឬប្រព័ន្ធសេដ្ឋកិច្ចបុរាណ គឺជាប្រភេទសេដ្ឋកិច្ចដើម កើតចេញពីប្រពៃណី ទំនៀមទម្លាប់ និងជំនឿរបស់ សហគមន៍ ក្រុម កុលសម្ព័ន្ធ ឬសាសនារបស់មនុស្ស និងកំណាត់ពីទំនិញ ឬសេវាកម្មដែលសេដ្ឋកិច្ចនោះត្រូវផលិតនិងចែកចាយ ហើយភាគច្រើនការដោះដូរទំនិញគឺមិនប្រើប្រាស់លុយកាក់ឡើយ។ ប្រទេសដែលប្រើប្រាស់សេដ្ឋកិច្ចរបៀបនេះភាគច្រើន គឺស្ថិតនៅតំបន់ដាច់ស្រយាលនិងរស់នៅដោយពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង ដោយសារពួកគេ

អាចចិញ្ចឹមជីវិតបាន ដោយពុំចាំបាច់មានការប្រើប្រាស់លុយកាក់។ សេដ្ឋកិច្ចរបៀបនេះ គឺមិនសូវមាន ឬគ្មានការអភិវឌ្ឍ ទទួលយកបច្ចេកវិទ្យា និងផ្នែកសុខាភិបាលពីបរទេសតិចតួច ឬគ្មានសោះដោយប្រពៃណីនៃការចិញ្ចឹមជីវិត ការស្លៀកពាក់ ក៏ដូចជាការតាំងទីលំនៅរបស់ពួកគេ ដែលប្រព្រឹត្តទៅតាមមនុស្សជំនាន់មុន។

### ២. ប្រព័ន្ធសេដ្ឋកិច្ចផែនការ (Planned Economic System)

សេដ្ឋកិច្ចរបៀបនេះ គឺរដ្ឋមានសិទ្ធិកាន់កាប់ទៅលើសកម្មភាពទាំងស្រុងនៃសេដ្ឋកិច្ចដោយការសម្រេចចិត្តចែកចាយនិងផលិតគឺធ្វើទៅតាមផែនការរបស់រដ្ឋាភិបាល។ វាមិនសូវមានភាពបត់បែនរហ័សដូចជាសេដ្ឋកិច្ចផ្សារទេ ចំណែកឯប្រតិកម្មផ្លាស់ប្តូរទៅតាមការទិញទំនិញរបស់អ្នកប្រើប្រាស់ និងភាពឡើងចុះនៃការផ្គត់ផ្គង់និងតម្រូវការក៏មានភាពយឺតយ៉ាវផងដែរ។

<u>**ឧទាហរណ៍**</u>៖ ប្រទេសដែលកាន់របបសង្គមនិយម ឬកុម្មុយនីស្ត ហេតុផលចម្បងដែលរដ្ឋាភិបាលជ្រើសរើសសេដ្ឋកិច្ចប្រភេទនេះ គឺដើម្បីអាចកាន់កាប់ ចាត់ចែងធនធានដែលមានតម្លៃរបស់ប្រទេស (មានដូចជា៖ រ៉ែប្រេង រ៉ែ មាស) មិនឱ្យបុគ្គលមួយក្រុមឬឈ្មួញ នាយទុន យកទៅកេងប្រវ័ញ្ច លើអត្ថប្រយោជន៍ប្រជាជនទូទៅ។

ទាំងផ្នែក កសិកម្ម ឧស្សាហកម្ម និងផ្នែកសេដ្ឋកិច្ចធំៗដទៃទៀត គឺប្រជាជនជាអ្នកដឹកនាំ និងចាត់ចែងខ្លួនឯង។

### ៣. ប្រព័ន្ធសេដ្ឋកិច្ចផ្សារ (Market Economic System)

រាល់សកម្មភាពនៃការដោះដូរទំនិញដោយសេរី និងអាស្រ័យទៅលើការឯកភាពគ្នារវាងអ្នកប្រើប្រាស់និងអ្នកផ្គត់ផ្គង់។ ក្រុមហ៊ុនក៏ដូចជាស្ថាប័នឯកជនមានសិទ្ធិកាន់កាប់ក្រុមហ៊ុន ដាក់ថ្លៃទំនិញ គ្រប់គ្រងខ្សែច្រវាក់ផលិតកម្ម ក៏ដូចជាបុគ្គលិកដោយខ្លួនឯង។ ចំណែករដ្ឋាភិបាលមិនមានសិទ្ធិគ្រប់គ្រងធនធានចាំបាច់ កំណត់ថ្លៃទំនិញ ឬវិស័យសំខាន់ៗនៃសេដ្ឋកិច្ចនោះទេ។ វិស័យឯកជនជាអ្នកកំណត់ថាសេដ្ឋកិច្ចត្រូវប្រព្រឹត្តទៅដោយរបៀបណា ការផ្គត់ផ្គង់ត្រូវធ្វើដូចម្តេច និងតម្រូវការអ្វីខ្លះដែលចាំបាច់។ ជាក់ស្តែង មិនមានសេដ្ឋកិច្ចផ្សារសេរីសុទ្ធសាធនៅក្នុងពិភពលោកឡើយ ដោយរដ្ឋាភិបាលនៅតែមានចំណែកចំពោះសេដ្ឋកិច្ចខ្លះៗដដែល។

### ៤. ប្រព័ន្ធសេដ្ឋកិច្ចចម្រុះ (Mixed Economic System)

សេដ្ឋកិច្ចចម្រុះ គឺជាសេដ្ឋកិច្ចដែលរួមបញ្ចូលកិច្ចសហប្រតិបត្តិការរវាងសេដ្ឋកិច្ចផ្សារ និងសេដ្ឋកិច្ចផែនការជាមួយគ្នា ដែលធនធានត្រូវបានគេបែងចែកទៅឱ្យទាំងឯកជនទាំងរដ្ឋ ជាអ្នកត្រួតត្រាតាមវិស័យនីមួយៗៗដែលប្រើប្រាស់គោលការណ៍ល្អបំផុតចំពោះប្រព័ន្ធទាំងពីរ។

វិស័យឯកជន កាន់កាប់អាជីវកម្មភាគច្រើននៃសេដ្ឋកិច្ច ជាងរដ្ឋាភិបាល លើកលែងតែវិស័យសំខាន់ៗមួយចំនួន ដូចជាវិស័យអប់រំ ថាមពល (ជាអាទ៏៖ ប្រព័ន្ធទឹកស្អាត អគ្គិសនីកម្ពុជា) ទូរគមនាគម៍ជាដើម។ វិស័យទាំងនោះមិនអាចឱ្យឯកជនកាន់កាប់ទាំងស្រុងបានទេ ព្រោះវាអាចធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ។ ជាក់ស្តែងយើងឃើញថាវិស័យផ្សេងៗគឺមានទាំងរដ្ឋ និងឯកជន ដូចជា វិស័យអប់រំ។

ទោះបីជាតាមទ្រឹស្តី គឺគេចង់ធ្វើយ៉ាងណាឱ្យវិស័យទាំងពីរអាចទាញយកផលប្រយោជន៍ពីគ្នាទៅវិញទៅមកឱ្យបានល្អយ៉ាងណាក៏ដោយ ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែងគឺមិនងាយនោះឡើយ។ យើងឃើញថាទំហំនៃការគ្រប់គ្រងរបស់រដ្ឋាភិបាលគឺធំដែលជួនកាលអាចមានឥទ្ធិពលលើសពីភាពចាំបាច់ទៅទៀត។

## III- ការរីកចម្រើននៃរដ្ឋដោយភាពចៃដន្យឬដោយប្រាជ្ញារបស់មនុស្ស

នៅក្នុងពិភពលោក មានការរីកចម្រើនដោយចៃដន្យជាច្រើន។ ការរីកចម្រើនរបស់សង្គមមួយ ប្រៀបបានល្បែងផ្សងសំណាង (ល្បែងអាប៉ោង) ដែលពោរពេញទៅដោយសំណាងល្អ និងសំណាងអាក្រក់។

នៅក្នុងធម្មជាតិ យើងមើលហ្វូងសត្វនានាក្នុងព្រៃ ក៏មានសត្វដែលខ្លាំងនិងសត្វដែលខ្សោយ រស់នៅចម្រុះគ្នា។ សត្វណាដែលខ្លាំងបានក្លាយជា អ្នកដឹកនាំនៅក្នុងហ្វូង ដើម្បីការពារសត្វដែលខ្សោយៗ។ ក្នុងពេលនោះ វាក៏អាចជិះជាន់សត្វដែលខ្សោយៗផងដែរ។



មនុស្សបច្ចុប្បន្ន បានចេញមកពី មនុស្ស អូម៉ូ សាព្យាង (Homo Sapient) រួចហើយក៏បានបន្តការអភិវឌ្ឍជាបន្តបន្ទាប់មក។ មនុស្សយើងទាំងអស់គ្នា មានតំណពូជមកពីពពួកដើមតែមួយ។ នេះប្រហាក់ប្រហែលទៅនឹងព្រះគម្ពីរប៊ីប(Bible) បានសរសេរនៅទំព័រទី១ ថា មនុស្សដើម កើតមកពី អាដាម និង អែវ [27] ។

តាមអ្នកវិទ្យាសាស្ត្រ យើងសង្កេតមើលសត្វស្វា សារធាតុ ឌីអិនអេ (DNA) របស់សត្វស្វា (chimpanzee) មានដូចមនុស្សដែរ ខុសប្រមាណតែ ៣% ប៉ុណ្ណោះ។ តែសត្វស្វាមិនអាចបន្តពូជ បង្កាត់ពូជជាមួយនឹងមនុស្សបានទេ។ មានតែមនុស្សទេ ទោះបីជាមានសម្បុរខ្មៅឬស ទោះបីជាជនជាតិ អាហ្វ្រិក អ៊ឺរ៉ុប ឬ អាស៊ី ក៏អាចបន្តពូជជាមួយគ្នាបានដែរ ដោយសារមាន ឌីអិនអេ ដូចគ្នា។

យើងដឹងថាមនុស្សមាន DNA ដូចគ្នា តែមនុស្សមានការគិតខុសគ្នា មានរូបរាងខុសៗគ្នា ពណ៌សម្បុរខុសៗគ្នា។ មនុស្សខ្លះមានប្រាជ្ញាខ្លាំង មនុស្សខ្លះមានប្រាជ្ញាខ្សោយ ហើយកន្លងមកពួកសាសន៍ អឺរ៉ុប មានអ្នកប្រាជ្ញច្រើនជាង នៅអាស៊ីនិងអាហ្វ្រិក។ គេក៏សិក្សាអំពីបញ្ហានេះ។

មនុស្សមានរូបរាង ពណ៌សម្បុរ ការគិតខុសៗគ្នា នេះបណ្តាលមកពីបរិស្ថាន ធម្មជាតិ និងឧបសគ្គនានា ដែលនៅជុំវិញខ្លួនយើង ដូចជា ទឹកដី ម្ហូបអាហារ អាកាសធាតុ វប្បធម៌ ហើយក៏ដោយសារអ្នករស់នៅជុំវិញដែរ។ កត្តាដែលធ្វើឱ្យមនុស្សមានការផ្លាស់ប្តូរ មានប្រាជ្ញាខុសៗគ្នា ដែល

[27] ព្រះគម្ពីរ ប៊ីប ទំព័រទី១

ពេលខ្លះយើងហាក់ដូចជាមើលឃើញថា ជាតិសាសន៍ខ្លះ មនុស្សខ្លះដូចជាមានប្រាជ្ញាឬចេះដឹងជាង មានដូចជា៖

- កត្តាសេដ្ឋកិច្ច កម្រិតជីវភាពរស់នៅ
- បរិស្ថាន ចំណីអាហារ ទីកន្លែងរស់នៅល្អ សុវត្ថិភាព
- កត្តាចិត្តសាស្ត្រ សិទ្ធិសេរីភាព ជំនឿ ការគិត
- ការចិញ្ចឹម អប់រំកូន ថែទាំ បង្រៀន ។ល។

មានទស្សនៈខ្លះយល់ថា ការចែករំលែកធនធាននាំមកនូវសមធម៌ ដូច្នេះគេមានគំនិតចង់យកធនធាន/លុយពីអ្នកមាន ទៅចែកឱ្យអ្នកក្រ ដើម្បីធ្វើឱ្យមនុស្សទូទៅរស់នៅបានល្អប្រសើរជាងនេះ មានការអភិវឌ្ឍបានលឿនលឿន។ គំនិតនេះអាចយកមកអនុវត្តបានដែរ តែលទ្ធផលអាចនឹងមិនដូចការចង់បាន។

ភាគច្រើនគេទទួលស្គាល់ថា ការរីកចម្រើន គឺបានមកពីចំណេះវិជ្ជា បានពីចំណេះដឹង។ ពីបូរាណរហូតមកដល់មជ្ឈឹមសម័យ ចំណេះដឹងនានា បានមកពីការរៀន រៀនតាមគ្នា រៀនតៗគ្នា និងការច្នៃបន្ថែម។ គេសង្កេតឃើញថា កាលពីដើម ជនជាតិអាម៉េរិក បានរៀនចំណេះដឹងច្រើនពីខាងប្រទេសអឺរ៉ុប ចំណែកឯពួកអឺរ៉ុបវិញ កាលពីមុនក៏រៀនចំណេះមកពីខាងពួកមជ្ឈិមបូព៌ាដែរ ។

គេនិយាយថា អ្នកប្រាជ្ញច្រើនតែជាជនជាតិស្បែកស តែអនាគតទៅ គេសន្និដ្ឋានថា ពួកស្បែកពណ៌ផ្សេងៗក៏អាចក្លាយទៅជាអ្នកប្រាជ្ញបានដែរ និងប្រទេសនានាផ្សេងទៀត ក្រៅពីអឺរ៉ុបឬអាម៉េរិក ក៏អាចមានអ្នកប្រាជ្ញច្រើនបានដែរ។ នេះមកពីគេយល់ថា ប្រាជ្ញាមិនមែនមានដោយសារតំណពូជសាសន៍នោះទេ។



មនុស្ស កើតមកអាចមានការវៃឆ្លាតដូចគ្នា តែគឺអាស្រ័យមកពីទឹកដី ទីកន្លែង ដែលផ្តល់ឱកាសដល់ពួកគេ ។ នៅប្រទេសអ្នកមាន ក៏មានមនុស្សល្ងង់ រីឯនៅប្រទេសអ្នកក្រ ក៏មានមនុស្សវៃឆ្លាតដែរ។ ជនជាតិអាស៊ីសព្វថ្ងៃនេះ ក៏ចាប់ផ្តើមមានការរីកចម្រើន។ នៅប្រទេសអ្នកមាន អ្នកខ្លះក៏ចាប់ផ្តើមខ្ជិល មិនសូវចូលចិត្តធ្វើការច្រើនម៉ោង ចូលចិត្តដើរលេងកម្សាន្ត ចូលចិត្តសម្រាកច្រើន។ល។ ឪពុកម្តាយជាអ្នកមាន មិនប្រាកដថាកូននឹងក្លាយទៅជាអ្នកមានទេ ព្រោះថាកូនទាំងនោះ ខ្លះអាចខ្ជិល មិនសូវតស៊ូក្នុងការងារ ហើយក៏អាចក្លាយទៅជាអ្នកក្រវិញដែរ។

បើមើលតាមប្រវត្តិនៃប្រទេសនានាកន្លងមក ប្រសិនបើគេរៀបចំចាត់ចែងការគ្រប់គ្រងប្រទេសបានល្អ ប្រទេសក្រីក្រឬដែលកំពុងអភិវឌ្ឍទាំងនោះ ត្រូវការពេលតែប្រមាណ៥០ឆ្នាំ ក៏នឹងអាចកសាងប្រទេសបានរីកចម្រើន ក្លាយជាប្រទេសអ្នកមានបានដែរ ។

ជាសេចក្តីសន្និដ្ឋាន បើគ្មានមនុស្ស គឺគ្មានសេដ្ឋកិច្ច។ ការរីកចម្រើននៃសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេស គឺអាស្រ័យលើមនុស្សជាអ្នកកសាង។ ធនធានមនុស្ស ចំណេះដឹង មានសារៈសំខាន់សម្រាប់ការរីក

ចម្រើនក្រុមហ៊ុន ក៏ដូចជាការអភិវឌ្ឍប្រទេសជាតិ បច្ចុប្បន្ននេះចំណេះដឹងជាកត្តាចាំបាច់មិនអាចខ្វះបាន។ បើមនុស្សមិនពូកែ ប្រទេសក៏មិនរីកចម្រើនដែរ ប្រទេសដែលប្រជាជនភាគច្រើនមានចំណេះដឹងទាប ការរីកចម្រើនក៏យឺតយ៉ាវ ភាពក្រីក្រមានជាទូទៅនិងយ៉ាងទូលំទូលាយ ហើយឧស្សាហ៍ឈ្លោះគ្នា ច្បាំងគ្នា។ សំខាន់ជាងនេះទៀត គឺអ្នកដឹកនាំប្រទេស អ្នកដឹកនាំដែលឆ្លាតវៃ មានទេពកោសល្យ តាមជំនឿខ្មែរថាមានបុណ្យបារមីដែលអាចដឹកនាំប្រទេសឱ្យបានសុខសន្តិភាព មានការរីកចម្រើនជាក់ស្តែង។

# ជំពូកទី៨

# បញ្ហាជម្លោះដណ្ដើមអំណាចសម័យថ្មី

## ១.ការប្រកួតដណ្ដើមដែនដីអាណានិគមរវាងមហាអំណាច អឺរ៉ុប

នៅចន្លោះសតវត្សរ៍ទី១៦ ប្រទេសមហាអំណាចនៅអឺរ៉ុបបានប្រជែងគ្នាពង្រីកដែនដីអាណានិគមរបស់ខ្លួននៅស្ទើរតែគ្រប់ទីកន្លែង នៅទូទាំងពិភពលោក។ មហាអំណាចអាណានិគមអឺរ៉ុបដែលគេស្គាល់ដំបូងគេ គឺ **អេស្ប៉ាញ និងព័រទុយហ្គាល់** ហើយបន្ទាប់មកទៀត មានហូឡង់ បារាំង និងអង់គ្លេស។ ព័រទុយហ្គាល់និងអេស្ប៉ាញ បានចាប់ផ្តើមពង្រីកអាណានិគមនៅក្នុងទ្វីបអាម៉េរិក ក្រោយពេលដែល លោក **គ្រីស្តូហ្វ កូឡំ** បានរកឃើញទ្វីបនេះនៅចុងសតវត្សរ៍ទី១៥[28]។ អាណានិគមរបស់អេស្ប៉ាញ និងព័រទុយហ្គាល់នៅទ្វីបអាម៉េរិក បានបន្សល់ទុកនូវស្លាកស្នាមរហូតមកទល់នឹងសព្វថ្ងៃ ដោយគេឃើញថា បណ្តាប្រទេសស្ទើរតែទាំងអស់ នៅអាម៉េរិកកណ្តាល និងអាម៉េរិកឡាទីន ចាប់តាំងពីម៉ិចស៊ិក រហូតទៅដល់អាហ្សង់ទីន សុទ្ធសឹងជាប្រទេសនិយាយភាសាអេស្ប៉ាញ ចំណែកប្រេស៊ីលវិញ ដែលមានដែនដីលាតសន្ធឹងស្ទើរតែពាក់កណ្តាលទ្វីបអាម៉េរិកឡាទីន គឺជាប្រទេសនិយាយភាសាព័រទុយហ្គាល់។

ទឹកដីអាម៉េរិកនៅសម័យនោះ គឺជាដែនប្រមាញ់របស់ប្រទេសមហាអំណាចអឺរ៉ុប ដែលប្រកួតប្រជែងគ្នាក្នុងការកាន់កាប់ដែលនាំឱ្យមានវិបត្តិ

[28] ការចេញផ្សាយរបស់វិទ្យុបារាំង RFI នៅថ្ងៃ: 20/10/2013 http://www.rfi.fr/km/discovery-of-america-by-christopher-columbus

នយោបាយ និងសង្គ្រាមរវាងពួកម្ចាស់ស្រុកនឹងពួកអាណានិគមបារាំង អេស្ប៉ាញ និងអង់គ្លេស។ គិតត្រឹមសតវត្សរ៍ទី១៨ ដែនដីអាម៉េរិកខាងជើងភាគច្រើនស្ថិតក្រោមការកាន់កាប់របស់បារាំង ដែលរហូតមកទល់នឹងបច្ចុប្បន្ននេះ គេឃើញមានទីក្រុងធំៗជាច្រើននៅអាម៉េរិកខាងជើង នៅតែរក្សាឈ្មោះជាបារាំង ដូចជា Montréal នៅកាណាដា និង Nouvelle-Orléan (ដែលបច្ចុប្បន្នហៅជាភាសាអង់គ្លេសថា New Orlean), Détroit និង Saint-Louis នៅសហរដ្ឋអាម៉េរិក ជាដើម។

ចំណែកអង់គ្លេសវិញកាន់កាប់ដែនដីតូចជាងបារាំង គឺដែនដីនៅតាមបណ្តោយឆ្នេរប៉ែកខាងកើតសហរដ្ឋអាម៉េរិក ដែលគេហៅថា ដែនដីអាណានិគមទាំង១៣ ហើយដែលក្រោយមកនឹងត្រូវក្លាយជារដ្ឋដំបូងបង្អស់ នៃសហរដ្ឋអាម៉េរិក។

ក្រោយពីការបែងចែកទឹកដីអាណានិគមមិនចុះសម្រុងគ្នា រួមទាំងការងើបឡើងរបស់ពួកម្ចាស់ស្រុកនៅអាម៉េរិក បារាំងក៏ត្រូវបានទទួលបរាជ័យ រីឯអង់គ្លេសដែលទទួលជោគជ័យក្នុងសង្គ្រាមជាមួយបារាំង។ បន្ទាប់មក នៅអាម៉េរិកខាងជើង ក៏មានសង្គ្រាមថ្មីមួយ គឺសង្គ្រាមទាមទារឯករាជ្យរបស់អាម៉េរិក។ សង្គ្រាមនេះក៏ការលូកដៃ ពីសំណាក់បារាំង អេស្ប៉ាញ ហូឡង់ រីឯអង់គ្លេសក៏ទទួលបានជំនួយពីរដ្ឋខ្លះរបស់អាល្លឺម៉ង់ដែរ ។ ដោយមើលឃើញពីបរាជ័យរបស់អង់គ្លេស សភានៃដែនដីអាណានិគមទាំង ១៣ ក៏បានអនុម័តលើសេចក្តីប្រកាសឯករាជ្យពីចក្រភពអង់គ្លេស នៅថ្ងៃទី ៤ ខែកក្កដា ឆ្នាំ១៧៧៦ ដែលត្រូវបានសហរដ្ឋអាម៉េរិកកំណត់ជាថ្ងៃបុណ្យឯករាជ្យរហូតមកទល់នឹងសព្វថ្ងៃ។

## ២. វិបត្តិសង្គ្រាមលោកលើកទី១ (១៩១៤-១៩១៨)

សង្គ្រាមលោកលើកទី១ ដែលចាប់ផ្ទុះឡើងនៅឆ្នាំ១៩១៤ គឺមានមូលហេតុជាច្រើនដែលកើតឡើងតាំងពីមុនមកម្ល៉េះ ជាពិសេសមានឫសគល់ចេញមកពីសង្គ្រាមរវាងបារាំងនិងនគរព្រុស្ស៊ីនៃចក្រភពអាល្លឺម៉ង់ នៅឆ្នាំ១៨៧០-១៨៧១ និងការលេចមុខនៃចក្រភពអាល្លឺម៉ង់ ដែលមានមហិច្ឆតាចង់ក្លាយជាប្រទេសមហាអំណាចអាណានិគម ប្រជែងជាមួយនឹងមហាអំណាចអឺរ៉ុបផ្សេងៗទៀត ការងើបឡើងនៃចលនាជាតិនិយមនៅតាមបណ្ដាប្រទេសនៅអឺរ៉ុប ការប្រជែងសព្វាវុធរវាងអាល្លឺម៉ង់និងអង់គ្លេស ព្រមទាំងការបង្កើតសម្ព័ន្ធមិត្តជាគូប្រជែងដើម្បីការពារខ្លួនពេលមានសង្គ្រាម។

មហាអំណាចសំខាន់ៗនៅពេលនោះ ភាគច្រើនស្ថិតក្នុងតំបន់អឺរ៉ុប រួមមាន៖ បារាំង អង់គ្លេស អាល្លឺម៉ង់ រុស្ស៊ី អូទ្រីសហុងគ្រី ដែលជាតួអង្គសំខាន់ក្នុងសង្គ្រាមលោកលើកទី១។ ម្យ៉ាងទៀតមូលហេតុដែលនាំឱ្យមានសង្គ្រាមលោកលើកទី១ គឺដោយសារការបែកបាក់នៃអាណាចក្រអូត្តូម៉ង់ ដែលបង្ករជាជម្លោះដណ្ដើមដែនដីគ្នារវាងរដ្ឋសហព័ន្ធ ជាអាទិ៍ អូទ្រីសហុងគ្រី សែរប៊ី និងក្រិក ក្នុងការដណ្ដើមដែនដីបូសនី។ ជម្លោះនៃការបែកបាក់នៃដែនដីអាណាចក្រអូត្តូម៉ង់នេះ បាននាំឱ្យមានការចងសម្ព័ន្ធមិត្តផ្សេងគ្នាដោយ អូទ្រីសហុងគ្រីបានចងសម្ព័ន្ធមិត្តជាមួយអាល្លឺម៉ង់ រីឯសែរប៊ី បានចងសម្ព័ន្ធមិត្តជាមួយរុស្ស៊ី ហើយការចងសម្ព័ន្ធមិត្តទាំងនេះ ក៏បាននាំឱ្យមានបញ្ហារវាងមហាអំណាចផ្សេងទៀត។

ដោយសារតែមានការចុះសម្ព័ន្ធភាពប្រទាក់ក្រឡាគ្នា កាលពីមុនសង្គ្រាមរវាងអូទ្រីសហុងគ្រី និងសែរប៊ី បានរាលដាលបន្តិចម្ដងៗ ទៅកាន់ប្រទេសផ្សេងៗទៀត។ ក្រោយពីអូទ្រីសហុងគ្រីប្រកាសសង្គ្រាមលើ

សៃរប៊ី ចក្រភពរុស្ស៊ីបានចាប់ផ្តើមកេណ្ឌកងទ័ព ដើម្បីត្រៀមចូលជួយសៃរប៊ី ដែលជាសម្ព័ន្ធមិត្ត។ ឃើញបែបនេះ អាល្លឺម៉ង់ក៏បានចាប់ផ្តើមកេណ្ឌកងទ័ពរបស់ខ្លួនដែរ ហើយក្នុងពេលជាមួយគ្នា អាល្លឺម៉ង់បានប្រកាសដាក់ឱសានវាទ ១២ម៉ោង ឱ្យរុស្ស៊ីបញ្ឈប់ការត្រៀមខ្លួនធ្វើសង្គ្រាមជួយសៃរប៊ី។ ដោយមិនបានទទួលចម្លើយវិជ្ជមានពីរុស្ស៊ី អាល្លឺម៉ង់ក៏បានប្រកាសសង្គ្រាមលើរុស្ស៊ី នៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩១៤។

ការប្រឈមមុខដាក់គ្នារវាងបារាំង និងអាល្លឺម៉ង់នៅភាគខាងលិច និងអាល្លឺម៉ង់និងរុស្ស៊ីនៅភាគខាងកើត បានស្ថិតក្នុងស្ថានភាពគ្មានអ្នកឈ្នះគ្មានអ្នកចាញ់។ ក៏ប៉ុន្តែ ក្រោយមករុស្ស៊ីបានប្រកាសដកខ្លួនចេញពីសង្គ្រាមលោកលើកទី១ ក្រោយពីការផ្លាស់ប្តូររបបនិងការឡើងកាន់ដំណែងរបស់លោក លេនីន។

ទោះបីជារុស្ស៊ីបានដកខ្លួនពីសង្គ្រាមលោកលើកទី១ក៏ពិតមែន ប៉ុន្តែតួអង្គថ្មី គឺសហរដ្ឋអាម៉េរិក ដែលបានចូលរួមក្នុងសង្គ្រាមនេះដែរ ។

ដោយសារតែមានជំនួយពីកម្លាំងទ័ពអាម៉េរិក ទើបប្រទេសបារាំងនិងអង់គ្លេស ចាប់ផ្តើមមានប្រៀបលើសមរភូមិ ហើយនៅខែសីហា ឆ្នាំ១៩១៨ កងទ័ពសម្ព័ន្ធមិត្តក៏បានចាប់ផ្តើមបើកយុទ្ធនាការទ្រង់ទ្រាយធំ វាយរុញច្រានកងទ័ពអាល្លឺម៉ង់ឱ្យដកថយបន្តិចម្តងៗចេញពីប្រទេសបារាំង។ អាល្លឺម៉ង់ដែលទទួលបរាជ័យនៅស្ទើរតែគ្រប់សមរភូមិ ក៏សុខចិត្តចរចាសុំចុះចាញ់ ហើយ ចុះហត្ថលេខាលើបទឈប់បាញ់ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩១៨ មុននឹងឈានទៅចុះសន្ធិសញ្ញាសន្តិភាព នៅទីក្រុង Versailles (ប្រទេសបារាំង) នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩១៩ ដើម្បីបញ្ចប់សង្គ្រាមលោកលើកទី១ ជាផ្លូវការ។

## ៣. វិបត្តិសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥)

សង្គ្រាមលោកលើកទី២ ដែលត្រូវបានចាប់ផ្ដើមឡើងនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៣៩ នឹងត្រូវបានបញ្ចប់វិញនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៤៥ ហើយមូលហេតុដែលនាំឱ្យមានសង្គ្រាមលោកលើកទី២នេះ គឺមានឫសគល់ជាច្រើនដែលបន្សល់មកពីសង្គ្រាមលោកលើកទី១ផងដែរ។ ក្រោយពីការឡើងកាន់អំណាចរបស់ **អាដុល ហ៊ីត្លែរ** (Adolf Hitler) អាល្លឺម៉ង់បានបន្តមហិច្ឆតារបស់ខ្លួន ចង់ក្លាយជាប្រទេសមហាអំណាចអាណានិគម ដែលនាំឱ្យមានវិបត្តិនយោបាយធ្ងន់ធ្ងរ ជាមួយនឹងប្រទេសអាណានិគមចាស់ ជាពិសេសប្រទេសបារាំង អង់គ្លេស ដែលជាគូអង្គក្នុងសង្គ្រាមលោកលើកទី២។

ប្រការគួរចងចាំដែរគឺថា ក្រោយចាញ់សង្គ្រាមលោកលើកទី១ អាល្លឺម៉ង់ត្រូវបានហាមឃាត់ចំពោះការផលិតអាវុធ និងការពង្រឹងកម្លាំងទ័ព តាមរយៈកិច្ចព្រមព្រៀងទីក្រុង Versailles ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩១៩ ដែលលោក ហ៊ីត្លែរ យល់ថាហាក់ដូចជាមានភាពធ្ងន់ធ្ងរមកលើអាល្លឺម៉ង់ ហើយ លោកហ៊ីត្លែរក៏បានឱ្យអាល្លឺម៉ង់ឈប់អនុវត្ត ដោយលួចផលិតអាវុធ និងពង្រឹងកម្លាំងទ័ពឡើងវិញ។

ប៉ុន្តែដល់ដើមឆ្នាំ១៩៣៩ ក្រោយពីអាល្លឺម៉ង់បានចូលឈ្លានពានកាន់កាប់ប្រទេសអូទ្រីស និងឆេកូស្លូវ៉ាគី ទើបមហាអំណាចអឺរ៉ុប ដែលឈ្នះសង្គ្រាមលោកលើកទី១ គឺបារាំង និងអង់គ្លេស ចាប់ផ្ដើមភ្ញាក់ដឹងខ្លួន ពីមហិច្ឆតាវាតទីនិយមរបស់លោកហ៊ីត្លែរ។

ការប្រកាសរបស់បារាំងនិងអង់គ្លេស មិនបានធ្វើឱ្យលោកហ៊ីត្លែរខ្លាចហើយបញ្ឈប់សកម្មភាពឈ្លានពានរបស់ខ្លួនឡើយ ដោយបន្តចូល

ឈ្លានពានកាន់កាប់ប្រទេសប៉ូឡូញ នៅព្រឹកថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៣៩។ នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៣៩ បារាំងនិងអង់គ្លេសបានដាក់ឱសានវាទឱ្យហ៊ីត្លែរ ដកកងទ័ពចេញពីប៉ូឡូញ ហើយនៅយប់ថ្ងៃដដែលឱសានវាទត្រូវផុតកំណត់ហ៊ីត្លែរមិនដកទ័ព បារាំងនិងអង់គ្លេស ក៏បានប្រកាសសង្គ្រាមលើប្រទេសអាល្លឺម៉ង់ ហើយសង្គ្រាមលោកលើកទី២ ក៏បានចាប់ផ្ទុះឡើងជាផ្លូវការ។[29]

សង្គ្រាមលោកលើកទី២ មានប្រទេសមហាអំណាចធំៗដែលបានចងជាសម្ព័ន្ធមិត្ត ហើយប្រយុទ្ធតតាំងគ្នាដោយក្នុងនោះសម្ព័ន្ធមិត្តខាងបារាំងមាន បារាំង អង់គ្លេស សហរដ្ឋអាមេរិក រុស្ស៊ី (រុស្ស៊ីដែលកាលពីដំបូងគឺជាសម្ព័ន្ធមិត្តជាមួយអាល្លឺម៉ង់) រីឯខាងអាល្លឺម៉ង់វិញមាន អាល្លឺម៉ង់ អ៊ីតាលី និងជប៉ុន (ហៅថា បក្សសម្ព័ន្ធត្រីភាគី)។

នៅក្នុងតំបន់អឺរ៉ុប សង្គ្រាមលោកលើកទី២ បានបញ្ចប់នៅខែឧសភា ឆ្នាំ១៩៤៥ ក្រោយពេលដែលកងទ័ពសហភាពសូវៀត និងកងទ័ពសម្ព័ន្ធមិត្តលោកខាងលិចបានវាយកាន់កាប់ប្រទេសអាល្លឺម៉ង់ ហើយពុះដែនដីអាល្លឺម៉ង់ចែកគ្នាកាន់កាប់ គឺប្រទេសអាល្លឺម៉ង់ខាងលិច និងប្រទេសអាល្លឺម៉ង់ខាងកើត។

នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកវិញ សង្គ្រាមបានបន្តរហូតដល់ខែសីហា ទើបអធិរាជជប៉ុនព្រមចុះចាញ់សង្គ្រាម ក្រោយពីអាមេរិកបានទម្លាក់គ្រាប់បែកនុយក្លេអ៊ែរលើទីក្រុងហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី។ នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ កិច្ចព្រមព្រៀងចុះចាញ់សង្គ្រាមដោយឥត

[29] អត្ថបទដោយលោក **សេង ឌីណា** ចុះផ្សាយ 25/07/2014

លក្ខខណ្ឌត្រូវបានជប៉ុន តំណាងដោយរដ្ឋមន្ត្រីការបរទេស ចុះហត្ថលេខានៅលើនាវាចម្បាំងអាម៉េរិក ។

សង្គ្រាមលោកលើកទី២ត្រូវបានគេចាត់ទុកថាជាសង្គ្រាម ដែលបានសម្លាប់មនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់បំផុត នៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។ ចំនួនអ្នកស្លាប់ នៅក្នុងសង្គ្រាមលោកលើកទី២ ត្រូវបានគេវាយតម្លៃផ្សេងៗគ្នា នៅក្នុងចន្លោះពី ៥០លាន ទៅ ៦០លាននាក់ ដោយនៅក្នុងចំណោមនោះមានជាងពាក់កណ្ដាលគឺជាជនស៊ីវិល។[30]

ប្រជាជនដែលទទួលរងគ្រោះធ្ងន់ធ្ងរជាងគេ គឺសហភាពសូវៀត និងចិន ដែលប្រទេសនីមួយៗ មានប្រជាជនប្រមាណ ពី ១០ លាន ទៅជិត ២០ លាននាក់ ត្រូវស្លាប់ដោយសង្គ្រាម ក្នុងនោះពាក់កណ្ដាលគឺជាជនស៊ីវិល។ បើគិតតាមសមាមាត្រនៃចំនួនប្រជាជនសរុបវិញ ប៉ូឡូញ គឺជាប្រទេសដែលមានអត្រាស្លាប់ខ្ពស់ជាងគេ គឺរហូតដល់ទៅជិត ២០% ហើយក្នុងចំណោមប្រជាជនប៉ូឡូញទាំងជិត ៦លាននាក់ ដែលត្រូវស្លាប់ក្នុងសង្គ្រាម មានពាក់កណ្ដាល គឺជាជនជាតិជ្វីហ្វ ដែលត្រូវទទួលរងការសម្លាប់រង្គាល ពីសំណាក់របបណាហ្ស៊ីហ៊ីត្លែរ។

អាល្លឺម៉ង់ផ្ទាល់ ក៏ទទួលរងនូវការខូចខាតយ៉ាងច្រើន ដោយមានប្រជាជនស្លាប់រហូតដល់ទៅ ៦លាននាក់ ប៉ុន្តែ អ្នកស្លាប់ភាគច្រើនលើសលុប គឺជាទាហាន។ ដូចគ្នាដែរចំពោះសម្ព័ន្ធមិត្តហ៊ីត្លែរនៅអាស៊ី គឺចក្រភពជប៉ុន ដែលមានទាហានស្លាប់ប្រមាណ ២លាននាក់ ឯជនរងគ្រោះស៊ីវិលមានប្រមាណជា ៥០ម៉ឺននាក់ ក្នុងនោះមានប្រមាណជា ១២ ម៉ឺននាក់ជា

---

30 អត្ថបទដោយ **សេង ឌីណា** ចុះផ្សាយ 10/11/2014

ជនរងគ្រោះក្នុងការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរនៅហ៊ីរ៉ូស៊ីម៉ា និងណាហ្កាសាគី។

សង្គ្រាមលោកលើកទី២បានបញ្ចប់នៅឆ្នាំ១៩៤៥ ក៏ប៉ុន្តែ បានបន្សល់ទុកនូវមរតកយ៉ាងច្រើនដល់ពិភពលោក និងជាមេរៀនសម្រាប់ច្រើនទសវត្សរ៍ក្រោយៗមកទៀត។ សង្គ្រាមលោកបានដាស់ស្មារតីសហគមន៍អន្តរជាតិឱ្យយល់ពីសារៈសំខាន់នៃការបង្កើតយន្តការដោះស្រាយជម្លោះដោយសន្តិវិធីជាជាងការប្រើកម្លាំងទ័ព។ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៤៥ (ជាងមួយខែក្រោយពីចប់សង្គ្រាមលោកលើកទី២) អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើង ដោយមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់ប្រទេសចំនួន ៥១ នៅទូទាំងពិភពលោក។

សហរដ្ឋអាម៉េរិក គឺជាប្រទេសដែលទទួលរងការខូចខាតដោយសង្គ្រាមតិចតួចជាងគេ។ ទឹកដីរបស់អាម៉េរិក នៅដាច់ឆ្ងាយពីគេឯង និងមានមហាសមុទ្រពីរជារនាំងការពារ បានចៀសផុតទាំងស្រុងពីការវាយប្រហាររបស់សត្រូវ។ រោងចក្រ សហគ្រាស ព្រមទាំងសកម្មភាពសេដ្ឋកិច្ចផ្សេងទៀត បន្តដំណើរការដោយគ្មានអាក់ខាន នៅពេញក្នុងអំឡុងសង្គ្រាម ហើយនៅក្រោយសង្គ្រាម ការរីកចម្រើននៃវិស័យឧស្សាហកម្មដែលមានទាំងនៅក្នុងវិស័យស៊ីវិល និងក្នុងវិស័យយោធា បានធ្វើឱ្យអាម៉េរិកក្លាយខ្លួនទៅជាមហាអំណាចសេដ្ឋកិច្ច និងយោធាដ៏ធំបំផុតនៅលើពិភពលោក។

## ៤. សម័យសង្គ្រាមត្រជាក់

ពាក្យថា "សង្គ្រាមត្រជាក់" ត្រូវបានប្រើជាដំបូង នៅឆ្នាំ១៩៤៥ ដោយអ្នកនិពន្ធអង់គ្លេសម្នាក់ ឈ្មោះថា George Orwell ។ ក្រោយមក

ពាក្យថា "សង្គ្រាមត្រជាក់" នេះ ត្រូវបានគេយកមកប្រើជាទូទៅ ដើម្បីសំដៅលើការប្រឈមមុខដាក់គ្នា រវាងមហាអំណាចធំៗពីរ នៅក្រោយសង្គ្រាមលោកលើកទី២ គឺសហរដ្ឋអាម៉េរិក និងសហភាពសូវៀត។

អ្នកប្រវត្តិសាស្ត្រមានការយល់ឃើញផ្សេងៗគ្នា ជុំវិញដំណើរដើមហេតុ ដែលបង្កឱ្យមានសង្គ្រាមត្រជាក់ ដោយអ្នកខ្លះយល់ថា សង្គ្រាមត្រជាក់បានចាប់ផ្តើមដុះពន្លកឡើង នៅក្រោយសង្គ្រាមលោកលើកទី២ ចំណែកឯអ្នកខ្លះទៀតយល់ថា ឫសគល់នៃការប្រឈមមុខដាក់គ្នា រវាងសហរដ្ឋអាម៉េរិក និងសហភាពសូវៀត បានចាប់មានឡើង តាំងពីមុនសង្គ្រាមលោកលើកទី២ គឺចាប់តាំងពីឆ្នាំ១៩១៧ នៅពេលដែលក្រុមកុម្មុយនិស្តរុស្ស៊ី ធ្វើបដិវត្តន៍ផ្តួលរំលំស្តេចត្សារ៍ ដណ្តើមអំណាចយកមកកាន់កាប់ រួចហើយបង្កើតជាសហភាពសូវៀត ដែលជារដ្ឋកុម្មុយនិស្ត។

បដិវត្តន៍ខែតុលា ឆ្នាំ១៩១៧ គឺជាចំណុចរបត់ដ៏សំខាន់មួយ នៅក្នុងទំនាក់ទំនង រវាងរុស្ស៊ី និងមហាអំណាចលោកខាងលិច ដែលធ្លាប់តែជាសម្ព័ន្ធមិត្តនឹងគ្នានៅក្នុងសង្គ្រាមលោកលើកទី១។

ម្យ៉ាងទៀត មហាអំណាចលោកខាងលិច និងសហភាពសូវៀតមានចំណុចខ្វែងគ្នាដ៏ធំមួយ គឺមនោគមន៍វិជ្ជានយោបាយ។ លើសពីនេះនៅឆ្នាំ១៩១៩ បក្សកុម្មុយនិស្តសូវៀតបានបង្កើតអង្គការអន្តរជាតិមួយឈ្មោះថា Comintern (Communist International) ក្នុងគោលដៅផ្សព្វផ្សាយលទ្ធិកុម្មុយនិស្តនៅទូទាំងពិភពលោក ដើម្បីប្រជែងជាមួយនឹងលទ្ធិមូលធននិយមលោកខាងលិច។

ទាំងនេះជាមូលហេតុនៃការប្រឈមមុខដាក់គ្នា រវាងសហភាពសូវៀត និងមហាអំណាចលោកខាងលិច។ នៅក្រោយសង្គ្រាមលោកលើក

ទី១ សហភាពសូវៀតត្រូវបានគេផាត់ចេញពីក្នុងចំណោមប្រទេសឈ្នះសង្គ្រាម។ សូវៀតមិនមានចំណែកក្នុងការចរចាសន្ធិសញ្ញាក្រុងវែរសៃ (Versailles)។ សូវៀតមិនត្រូវបានគេអនុញ្ញាតឱ្យចូលជាសមាជិកសង្គមប្រជាជាតិ។ សូវៀតក៏ខឹងនឹងប្រទេសលោកខាងលិច ដែលមិនចាត់ទុកខ្លួនជាប្រទេសមហាអំណាចមួយដែលបានឈ្នះសង្គ្រាមនិងគេ។

នៅក្នុងសង្គ្រាមលោកលើកទី២ សហភាពសូវៀត និងសហរដ្ឋអាម៉េរិកបានសហការគ្នា ក្នុងការច្បាំងទល់នឹងអាល្លឺម៉ង់ ក៏ប៉ុន្តែ ការសហការគ្នានេះត្រូវធ្វើឡើងដោយសារតែកាលៈទេសៈតម្រូវតែប៉ុណ្ណោះ មិនមែនធ្វើឡើងក្នុងលក្ខណៈជាមិត្តភាពនឹងគ្នានោះទេ។ សហភាពសូវៀត និងសហរដ្ឋអាម៉េរិកសហការគ្នា ក្នុងសង្គ្រាមលោកលើកទី២ គឺដោយសារតែនៅពេលនោះ ប្រទេសទាំងពីរមានសត្រូវរួមគ្នា គឺហ៊ីត្លែរ ប៉ុន្តែធាតុពិត ទំនាក់ទំនងរវាងមហាអំណាចទាំងពីរ គឺជាទំនាក់ទំនងដែលប្រកបទៅដោយភាពតានតឹងនិងការមិនទុកចិត្តគ្នា។

នៅក្រោយពេលដែលសង្គ្រាមលោកលើកទី២ត្រូវបញ្ចប់ តំបន់អឺរ៉ុបត្រូវពុះខណ្ឌចែកជាពីរ គឺអឺរ៉ុបខាងកើតស្ថិតក្រោមឥទ្ធិពលរបស់សហភាពសូវៀត និងអឺរ៉ុបខាងលិចស្ថិតក្រោមឥទ្ធិពលរបស់សហរដ្ឋអាម៉េរិក។ អាល្លឺម៉ង់ណាហ្ស៊ីដែលជាសត្រូវរួម ត្រូវដួលរលំ សហភាពសូវៀត និងសហរដ្ឋអាម៉េរិកក៏បង្វែរពីការសហការគ្នា ទៅជាការប្រកួតប្រជែងគ្នា ដើម្បីបង្កើនឥទ្ធិពលរៀងៗខ្លួន ដែលបង្កឱ្យមានការប្រណាំងប្រជែងផ្នែកសព្វាវុធ ទាំងគ្រឿងសព្វាវុធធម្មតា និងអាវុធនុយក្លេអ៊ែរ ការប្រណាំងប្រជែងគ្នាតាំងពីលើផែនដីរហូតដល់ទីអវកាស ព្រមទាំងការរុក

គូនគ្នា បង្កើតឱ្យមានជាសង្គ្រាមស៊ីវិលនៅតាមបណ្តាប្រទេសជាច្រើន នៅទូទាំងពិភពលោក។

## ៥. ពិភពលោកក្រោយសម័យសង្គ្រាមត្រជាក់

ទោះបីជាសង្គ្រាមដោយអាវុធផ្ទាល់មិនកើតមានឡើងមែន ប៉ុន្តែ មហាអំណាចសហរដ្ឋអាម៉េរិក និងសហភាពសូវៀតតែងតែធ្វើសង្គ្រាម នឹងគ្នាដោយប្រយោលដោយបង្កើតឱ្យមានជាសង្គ្រាមស៊ីវិល នៅតាមបណ្តា ប្រទេសតូចៗជាច្រើននៅទូទាំងពិភពលោក។ ការបញ្ចប់សង្គ្រាមត្រជាក់ នៅឆ្នាំ**១៩៩១** គឺជាកត្តាដ៏ចម្បងមួយ ដែលជំរុញឱ្យមានដំណោះស្រាយ នយោបាយបញ្ចប់សង្គ្រាមស៊ីវិលអស់ទាំងអស់ ក្នុងនោះក៏មានសង្គ្រាម ស៊ីវិលដ៏រ៉ាំរ៉ៃ នៅក្នុងប្រទេសកម្ពុជាមួយផងដែរ ដែលដំណើរការចរចា សន្តិភាពក្នុងសង្គ្រាមស៊ីវិលកម្ពុជាបានចាប់ផ្តើមធ្វើឡើង នៅអំឡុងឆ្នាំ ១៩៨៧ ក៏ប៉ុន្តែការចរចានេះត្រូវជួបនឹងបញ្ហាស្មុគស្មាញច្រើន ដោយសារ តែភាគីជម្លោះសុទ្ធតែមានមហាអំណាចបរទេសនៅពីខាងក្រោយ គឺចិន និងអាម៉េរិក គាំទ្រពួកខ្មែរក្រហម ចំណែកឯរដ្ឋាភិបាលសាធារណរដ្ឋ ប្រជាមានិតកម្ពុជាវិញ មានប្រទេសវៀតណាម និងសហភាពសូវៀតនៅ ពីក្រោយ។

សង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ក៏ពិតមែន ប៉ុន្តែសង្គ្រាមស៊ីវិល និង សង្គ្រាមតាមតំបន់ ដែលកើតចេញពីសង្គ្រាមត្រជាក់នៅតែបន្តកើតមាន ដូចជា៖

- សង្គ្រាមរវាងកូរ៉េខាងត្បូង និងកូរ៉េខាងជើង
- សង្គ្រាមយូហ្គោស្លាវី ពីឆ្នាំ១៩៩១ រហូតដល់ឆ្នាំ២០០១

- សង្គ្រាមកើតចេញពីការបាក់បែកនៃរដ្ឋសហព័ន្ធយូហ្គោស្លាវី ដែលបច្ចុប្បន្នក្លាយទៅជាប្រទេសឯករាជ្យដាច់ពីគ្នា គឺរួមមាន ក្រូអាស៊ី ស៊ែរប៊ី ម៉ុងតេណេហ្គ្រោ ស្លូវេនី បូស្នី ម៉ាសេដ្វាន និងចុងក្រោយ គឺ កូសូវ៉ូ ជាដើម។
- សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ឆ្នាំ២០២២
- សង្គ្រាមអ៊ីស្រាអែល-ហាម៉ាស ឆ្នាំ២០២៣

នៅក្រោយសង្គ្រាមត្រជាក់ សហភាពសូវៀតត្រូវដួលរលំ សហរដ្ឋអាម៉េរិកក៏បានក្លាយទៅជាមហាអំណាចផុតលេខ ដោយបានគ្រប់គ្រងពិភពលោកទាំងមូល ទាំងខាងវិស័យយោធា សេដ្ឋកិច្ច ការទូត និងខាងផ្នែកវប្បធម៌ ហើយវប្បធម៌របស់អាម៉េរិកត្រូវរីកសាយភាយទៅស្ទើរតែគ្រប់ទីកន្លែងនៅទូទាំងពិភពលោក គឺដោយសារតែការរីកចម្រើននៃបច្ចេកវិទ្យាខាងទូរគមនាគមន៍ ព្រមទាំងចរន្តដ៏សំខាន់មួយ ដែលគេស្គាល់ជាទូទៅថា "សកលភាវូបនីយកម្ម"។

នៅពេលដែលសង្គ្រាមត្រជាក់ត្រូវបញ្ចប់ ការប្រឈមមុខដាក់គ្នារវាងមហាអំណាចទាំងពីរក៏លែងមាន រីឯបច្ចេកវិទ្យាជាច្រើនក៏ត្រូវបានគេបង្វែរមកប្រើប្រាស់នៅក្នុងវិស័យស៊ីវិល ពិភពលោកក៏បានស្គាល់នូវដំណើរវិវឌ្ឍន៍ដ៏សំខាន់មួយ ដែលអ្នកប្រវត្តិសាស្ត្រជាច្រើនដាក់ឈ្មោះថាជា "បដិវត្តន៍បច្ចេកវិទ្យា" ឬ "បដិវត្តន៍ឌីជីថល"។

ដំណើរវិវឌ្ឍន៍ខាងបច្ចេកវិទ្យា ដែលនាំមកនូវការផ្លាស់ប្តូរដ៏ធំជាងគេនៃពិភពលោកក្រោយសម័យសង្គ្រាមត្រជាក់ គឺការរីកចម្រើននៃប្រព័ន្ធកុំព្យូទ័រ ទូរសព្ទដៃ និងជាពិសេសបំផុត គឺបណ្តាញអ៊ីនធឺណិត

ដែលអាចនាំឱ្យមនុស្សទូទាំងពិភពលោកមានការប្រាស្រ័យទាក់ទងគ្នារហូតមកទល់ពេលបច្ចុប្បន្ន។

ធម្មជាតិរបស់មនុស្ស គឺបដិបក្ខភាព (antagonism) ជម្លោះតាមរូបភាពចាស់បានបាត់ទៅ ជម្លោះតាមរូបភាពថ្មីបានកើតឡើង ហើយចេះតែកើតមានជាបន្តបន្ទាប់។ សព្វថ្ងៃនេះ ប្រទេសធំៗនិងប្រទេសនានាជាច្រើន ក៏ខិតខំបង្កើនចំណាយលើវិស័យកងទ័ព ការបង្កើត បង្កើន ការទិញសព្វាវុធថ្មីៗ ទំនើបៗ ទោះបីជាមិនទាន់មានសង្គ្រាមក៏ដោយ។ ការចងជាចង្កោមជាប្លុកជួយគ្នាផ្នែកយោធា មានកាន់តែច្រើនឡើង កាន់តែពង្រឹងនិងពង្រីករហូត។ នេះគឺជាការប្រឈមថ្មីរបស់ពិភពលោកយើងទន្ទឹងនឹងមានជាចលនាពហុប៉ូលលើច្រើនទិដ្ឋភាព ដែលកំពុងមានសកម្មភាពប្រឈមគ្នាយ៉ាងខ្លាំងនៅលើពិភពលោកយើងបច្ចុប្បន្ននេះ។

# ជំពូកទី៩
# បដិវត្តន៍ឧស្សាហកម្មសតវត្សរ៍ទី១៨ និងទី១៩

បដិវត្តន៍ឧស្សាហកម្ម (industrial revolution) បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំង នូវរបៀបរបបរស់នៅរបស់មនុស្សរបៀបសម័យបូរាណ ដែលធ្លាប់ឆ្លងកាត់អស់ពេលជាង៨០០០ឆ្នាំមកហើយ ទៅជាការរស់នៅថ្មី ជឿនលឿន តែក្នុងរយៈពេលប្រមាណ២០០ឆ្នាំ។



ការបង្កើតរថយន្តដំបូង

## ការវិវត្តផ្នែកគំនិតសេដ្ឋកិច្ច

ការវិវត្តសំខាន់បំផុតរបស់មនុស្សក្នុងប្រវត្តិសាស្ត្រ គឺបដិវត្តន៍ឧស្សាហកម្ម ដែលស្ថិតនៅចន្លោះសតវត្សរ៍ទី១៨ និងសតវត្សរ៍ទី១៩ ដោយកើតចេញពីការវិវត្តនៃគំនិតច្នៃប្រឌិតរបស់មនុស្ស។ គិតមកត្រឹមសតវត្សរ៍ទី១៨ មនុស្សជាតិនៅលើពិភពលោកភាគច្រើនរស់ទីជនបទ និងប្រកបរបរ

ចិញ្ចឹមជីវិត តាមរយៈរបរកសិកម្ម ការចិញ្ចឹមសត្វ ឬសកម្មភាពសិប្បកម្មផ្សេងៗទៀត។ មនុស្សក៏ចេះបង្កើតសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ដោយខ្លួនឯង ហើយក៏នាំឱ្យមានសកម្មភាពដោះដូរសម្ភារៈទាំងនោះពីមួយថ្ងៃទៅមួយថ្ងៃរហូតមកដល់ពេលបច្ចុប្បន្ន។ ការកែច្នៃ និងបង្កើតរបស់របរប្រើប្រាស់ផ្សេងនៅពេលនោះ គឺត្រូវធ្វើឡើងដោយដៃ ដោយកម្លាំងមនុស្ស ឬសត្វចិញ្ចឹម (គោ ក្របី សេះ ដំរីជាដើម) ជាលក្ខណៈគ្រួសារដែលផ្តល់នូវលទ្ធផលនិងប្រាក់ចំណូលបានតិចតួច ហើយប្រជាជនភាគច្រើនមានជីវភាពខ្សត់ខ្សោយនៅឡើយ។

ក៏ប៉ុន្តែ នៅចុងសតវត្សរ៍ទី១៨ ពិភពលោកបានស្គាល់នូវការវិវឌ្ឍដ៏សំខាន់បំផុត ដែលគេឱ្យឈ្មោះថា "**បដិវត្តន៍ឧស្សាហកម្ម**" ជាចំណុចរបត់នៃការផ្លាស់ប្តូររបៀបរស់នៅរបស់មនុស្សជាតិ ពីការពឹងផ្អែកជាចម្បងលើសកម្មភាពកសិកម្ម ទៅជាការប្រកបរបរចិញ្ចឹមជីវិត ដោយសកម្មភាពឧស្សាហកម្មដែលមានលក្ខណៈទំនើបនិងប្រសើរជាងមុន។




រោងចក្រដំបូងនៅប្រទេសអង់គ្លេស

ការចាប់ផ្តើមដំបូងនៃបដិវត្តន៍ឧស្សាហកម្មនៅពេលនោះ គឺនៅចក្រភពអង់គ្លេសដោយសារកត្តាច្រើនយ៉ាង ក្នុងនោះមានដូចជា៖

**<u>កត្តាទី១</u>**៖ «វត្ថុធាតុដើម»

ចក្រភពអង់គ្លេស គឺជាប្រទេសដែលសម្បូរទៅដោយរ៉ែធ្យូងថ្ម និងរ៉ែដែក ដែលជាវត្ថុធាតុដើមដ៏សំខាន់បំផុតសម្រាប់ដំណើរការនៃវិស័យឧស្សាហកម្ម។

**<u>កត្តាទី២</u>**៖ «ចំណេះដឹង»

នៅក្នុងអំឡុងសតវត្សរ៍ទី១៨ ប្រទេសអង់គ្លេសមានអ្នកប្រាជ្ញល្បីៗជាច្រើន ដូចជា **អ៊ីសាក់ ញូវតុន** (Isaac Newton) ដែលជាអ្នកប្រាជ្ញមានឈ្មោះល្បីល្បាញបំផុតរហូតមកទល់បច្ចុប្បន្ននេះគឺជាអ្នកប្រាជ្ញអង់គ្លេស។ ក្រៅពីនោះមានអ្នកប្រាជ្ញល្បីៗផ្សេងទៀត ខាងផ្នែករូបវិទ្យា និងវិស្វកម្ម ដែលចំណេះដឹងរបស់អ្នកប្រាជ្ញទាំងនេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតបច្ចេកវិទ្យាថ្មីៗជាច្រើន ដូចជា ការបង្កើនប្រសិទ្ធភាពក្នុងការប្រើថាមពលទឹក ការប្រើធ្យូងថ្មជាប្រភពថាមពលជំនួសអុស ការបង្កើតម៉ាស៊ីនដើរដោយចំហាយទឹក បច្ចេកទេសក្នុងការផលិតដែកជាលក្ខណៈឧស្សាហកម្ម ព្រមទាំងបច្ចេកទេសខាងផ្នែកមេកានិកក្នុងការបង្កើតគ្រឿងម៉ាស៊ីនផ្សេងទៀត ដែលអាចធ្វើឱ្យការផលិតទទួលបានទិន្នផលច្រើនជាងការផលិតដោយដៃរាប់រយ ឬរហូតដល់រាប់ពាន់ដង។

**<u>កត្តាទី៣</u>**៖ «កត្តានយោបាយ និងសង្គម»

ចាប់តាំងពីមានបដិវត្តន៍បង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញនៅចុងសតវត្សរ៍ទី១៧ អង់គ្លេស គឺជាប្រទេសមួយដែលមានស្ថិរភាពទាំងផ្នែកនយោបាយ និងសង្គម ហើយរដ្ឋាភិបាលអង់គ្លេសតែងតែ

ប្រកាន់យកនូវនយោបាយបើកចំហក្នុងវិស័យឯកជន ជំរុញលើកទឹកចិត្ត ដល់អ្នកបង្កើតសហគ្រាសឯកជន និងអ្នកបង្កើតទ្រឹស្តី ឬបច្ចេកវិទ្យាថ្មីៗ ដែលអាចបង្កើនប្រសិទ្ធភាពក្នុងការផលិត។

ទាំងអស់ខាងលើនេះហើយ ដែលនាំឱ្យវិស័យឧស្សាហកម្មនៅអង់គ្លេសស្គាល់នូវភាពជឿនលឿនជាងគេ នៅអំឡុងចុងសតវត្សរ៍ទី១៨ និងដើមសតវត្សរ៍ទី១៩។ នៅពេលនោះ រដ្ឋាភិបាលអង់គ្លេសបានព្យាយាមទប់ស្កាត់មិនឱ្យបច្ចេកវិទ្យាឧស្សាហកម្មរបស់ខ្លួនត្រូវរីកសាយភាយទៅកាន់ប្រទេសផ្សេង។

ក្រោយៗមក បដិវត្តន៍ឧស្សាហកម្មក៏បានរីកសាយភាយចេញពីអង់គ្លេសទៅកាន់ប្រទេសផ្សេងទៀតនៅអឺរ៉ុប ដោយចាប់ផ្តើមពី**បែលហ្ស៊ិក** បន្តទៅដល់**បារាំង អាល្លឺម៉ង់** និង**ស៊ុយអែដ** ហើយបន្ទាប់មកទៀត ចេញពីអឺរ៉ុប ទៅដល់**សហរដ្ឋអាម៉េរិក**។[31]

គិតត្រឹមពាក់កណ្តាលសតវត្សរ៍ទី១៩ បដិវត្តន៍ឧស្សាហកម្មបានចាក់គ្រឹះយ៉ាងមាំ នៅទូទាំងតំបន់អឺរ៉ុបខាងលិច និងនៅឆ្នេរប៉ែកខាងកើតនៃសហរដ្ឋអាម៉េរិក។ វិស័យដែលមានការជឿនលឿនខ្លាំងជាងគេ នៅពេលនោះ គឺវិស័យវាយនភ័ណ្ឌ ការផលិតដែក លោហធាតុ និងបច្ចេកវិទ្យាក្នុងការផលិតម៉ាស៊ីន ជាពិសេស ម៉ាស៊ីនដើរដោយចំហាយទឹក។ នេះជំរុញឱ្យសង្គមមនុស្សកាន់តែរីកចម្រើនយ៉ាងឆាប់រហ័ស សកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម ក៏កាន់តែជឿនលឿនមានការតភ្ជាប់យ៉ាងឆាប់រហ័ស ពីតំបន់មួយទៅតំបន់មួយទៀតនៅក្នុងពិភពភពលោក។

[31] អត្ថបទរបស់ **សេង ឌីណា** វិទ្យុបារាំង RFI



រថភ្លើងដំបូង

កាលពីមុន មនុស្សធ្វើដំណើរ ឬដឹកជញ្ជូនទំនិញ ពីកន្លែងមួយ ទៅកន្លែងមួយ ដោយថ្មើរជើង ឬដោយរទេះសេះ រីឯការធ្វើដំណើរតាមផ្លូវទឹកវិញ ត្រូវធ្វើឡើងតាមទូកដោយប្រើក្ដោង ឬចែវ។ ក៏ប៉ុន្តែ បដិវត្តន៍ឧស្សាហកម្មបាននាំទៅរកការបង្កើតមធ្យោបាយដឹកជញ្ជូនថ្មី ដែលអាចដឹកទំនិញបានច្រើន បានលឿន និងក្នុងរយៈចម្ងាយឆ្ងាយជាងមុន។

បើនិយាយខាងផ្នែកសង្គមវិញ បដិវត្តន៍ឧស្សាហកម្មបានធ្វើឱ្យប្រជាជន ដែលកាលពីមុនរស់នៅតាមទីជនបទ នាំគ្នាមករស់នៅប្រមូលផ្ដុំគ្នា នៅតាមទីក្រុង ដែលជាកន្លែងសម្បូររោងចក្រ និងសម្បូរការងារធ្វើ។ ការកើនឡើងនៃសមត្ថភាពផលិតបានធ្វើឱ្យថ្លៃសម្ភារៈប្រើប្រាស់ ជាពិសេសក្រណាត់ និងសម្លៀកបំពាក់ មានការធ្លាក់ចុះ។ ប្រជាជនទូទៅមានប្រាក់ចំណូលច្រើន និងមានជីវភាពធូរធារជាងមុន។ នៅសហរដ្ឋអាម៉េរិកវិញ ការកើនឡើងនៃសកម្មភាពផលិតនៅក្នុងវិស័យវាយនភ័ណ្ឌបាន ធ្វើឱ្យតម្រូវការកប្បាសមានការកើនឡើងខ្លាំង ហើយការទិញដូរទាសករ

ស្បែកខ្មៅ ដើម្បីយកទៅធ្វើការក្នុងចម្ការកប្បាសក៏មានការកើនឡើងខ្លាំង។ បញ្ហាទាសករ ដែលធ្លាប់ជាបញ្ហាចម្រូងចម្រាសស្រាប់ ចាប់តាំងពីពេលកកើតសហរដ្ឋអាមេរិក ក៏បានក្លាយជាបញ្ហាកាន់តែធំ រហូតរាលដាលទៅជាសង្គ្រាមស៊ីវិល រវាងរដ្ឋរបស់អាមេរិក នៅឆ្នាំ១៨៦១។

បច្ចុប្បន្ន ដោយសារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និវានុវត្តន៍ កាន់តែជឿនលឿនទៅមុខយ៉ាងឆាប់រហ័ស បដិវត្តន៍ឧស្សាហកម្ម បានឈានដល់ដំណាក់កាលទី៤ ហើយ (Industrial Revolution 4.0) ។

# ជំពូកទី១០
# ការវិវត្តសង្គមកម្ពុជា

## ១- កម្ពុជាបុរេប្រវត្តិសាស្ត្រ

(៤២៩០ឆ្នាំមុនគ.ស.ដល់ឆ្នាំ៥២នៃគ.ស.)

សម័យបុរេប្រវត្តិ គឺជាសម័យកាលដ៏យូរលង់មួយដែលមនុស្សមិនបានកត់ត្រាអំពីហេតុការណ៍អ្វីឡើយ។ ការសិក្សាអំពីបុរេប្រវត្តិខ្មែរគឺពុំមានការកត់ត្រាជាសំណេរឡើយ ដោយសារពេលនោះខ្មែរយើងពុំទាន់ចេះបង្កើតតួអក្សរសម្រាប់កត់ត្រាប្រវត្តិសាស្ត្ររបស់ខ្លួននៅឡើយ។ នៅភូមិភាគអាស៊ីអាគ្នេយ៍កាលពីមុនគេបានប្រទះឃើញមានពំនើងផ្ទត់កាឡេដូន្យាង (Plissement caledonien) និងពំនើងផ្ទត់ អែរស៊ីន្យាង (Plissement hercynien) ដែលនាំឱ្យលិចឡើងនូវខ្ពង់រាបនិងជួរភ្នំនានាពាសពេញប្រទេសខ្មែរសព្វថ្ងៃ។ បន្ទាប់មកក៏បានលិចទៅវិញទៅក្នុងសមុទ្រនៅស័កទី៣។ នៅស័កទី៤ ដីក៏ផុសចាប់ពីភូមិភាគហេមពាន្ត (Himalaya) រហូតដល់អាស៊ីអាគ្នេយ៍ទាំងមូល។ ដីខ្មែរក៏ដុះឡើងពី៧០០-៨៨០ម៉ែត្រ។ ក្នុងស័កទី៤ មានលំនាច និងជំនោរទឹកសមុទ្រដែលជាមូលហេតុធ្វើឱ្យដីលិចហើយផុសឡើងវិញសាជាថ្មីម្តងទៀត។ នៅចន្លោះពី ៦០០,០០០-៥,០០០ឆ្នាំ មុនគ.ស.ទឹកសមុទ្របាននាចថយទៅពី ១៣០-១៨០ម៉ែត្រ (បើធៀបទៅនឹងកម្ពស់ទឹកសមុទ្រសព្វថ្ងៃនេះ)។

អ្នកភូគព្ភវិទូខ្លះបានយល់ថា កាលនោះគ្មានសមុទ្រខណ្ឌភូមិភាគឥណ្ឌូចិន និងប្រជុំកោះ អាំងស៊ុយឡាំង (Insulinde) ស្ថិតនៅជាប់គ្នារហូត គឺគ្មានសមុទ្រខណ្ឌដូចយើងឃើញសព្វថ្ងៃនេះទេ។ នៅប្រមាណ

១៥,០០០ឆ្នាំមុនគ.ស.ទឹកសមុទ្រជោរបានកម្ពស់ ១៥ម៉ែត្រ ដែលបណ្តាលឱ្យទឹកដីកម្ពុជាក្រោម និងវាលទំនាបប្រទេសខ្មែរមួយចំនួន បានលិចទៅក្នុងទឹកវិញ។ នៅសតវត្សរ៍ទី៣ មុនគ.ស.ទឹកសមុទ្របាននាចទៅវិញបន្តិចៗម្តង។ ពេលនោះ ទន្លេមេគង្គបាននាំដីល្បាប់មកចាក់បំពេញបន្តិចៗម្តង ក្លាយជាដីសណ្តបន្តដេញតាមទឹកសមុទ្រស្រក។ គេអាចដឹងព្រឹត្តិការណ៍ផ្សេងៗ ក្នុងសម័យបុរេប្រវត្តិ តាមការសិក្សាលើគ្រោងឆ្អឹងមនុស្សប្រដាប់ប្រដា សម្ភារៈ កម្ទេចសំណល់គ្រប់បែបយ៉ាង ដែលមនុស្សជំនាន់មុនបានបន្សល់ទុក។

នៅក្នុងវប្បធម៌យុគថ្មរំលីង ដែលប្រហែលជាមានការធ្វើចំណាកស្រុកពីចិនភាគអាគ្នេយ៍ ទៅឧបទ្វីបឥណ្ឌូចិន។ នៅសតវត្សទី១ នៃគ.ស. ពួកអ្នកស្រុកបានអភិវឌ្ឍ និងរៀបចំសង្គម ដែលបានចាកហួសឆ្ងាយពីដំណាក់កាលនៃយុគដំបូងខាងវប្បធម៌ និងជំនាញបច្ចេកទេស។ ពួកក្រុមដែលរីកចម្រើនបំផុត បានរស់នៅតាមបណ្តោយឆ្នេរ និងនៅតាមជ្រលងដងទន្លេមេគង្គក្រោម និងតំបន់ដីសណ្តដែលជាកន្លែងពួកគេបានធ្វើការដាំដុះស្រូវ និងចិញ្ចឹមថែទាំសត្វពាហនៈមួយចំនួន។ អ្នកប្រវត្តិវិទូបានគិតថា ពួកមនុស្សទាំងនេះបានមកដល់មុន ពួកអ្នកជិតខាងវៀតណាម ថៃនិងឡាវទៅទៀត។ ពួកមនុស្សទាំងនេះ ប្រហែលគឺជាជនជាតិអាស៊ីខាងត្បូងដើមកំណើត និងមានទំនាក់ទំនងទៅនឹងបុព្វការីជននៃក្រុមមួយចំនួនដែលតឡូវតាំងទីលំនៅ នៅអាស៊ីអាគ្នេយ៍ តាមកោះ និងប្រជុំកោះជាច្រើននៃមហាសមុទ្រប៉ាស៊ីហ្វិក។ ពួកគេបានស្លលោហៈ រួមមាន ដែកនិងសំរិទ្ធិ និងចេះជំនាញនាវាចរណ៍ច្បាស់លាស់ទៀតផង។

ការស្រាវជ្រាវថ្មីៗបានស្រាយបំភ្លឺនូវរបកគំហើញនៃដីលើកសិប្បនិមិត្ត រាងមូល ដែលចុះកាលកំណត់សម័យកាលយុគថ្មរំលីងនៃកម្ពុជា។

តាមរយៈការសិក្សារបស់អ្នកបុរាណវិទ្យា គេរកឃើញថា នៅត្រង់ទឹកដីនៃប្រទេសកម្ពុជាបច្ចុប្បន្ន មានមនុស្សរស់នៅដើមដំបូង តាំងពីប្រមាណជា ៤២០០ឆ្នាំមុនគ.ស.ពោលគឺ ប្រមាណជាជាង ៦ពាន់ឆ្នាំមុនសម័យកាលបច្ចុប្បន្ន។ ប្រជាជននៅតំបន់នេះបានចាប់ផ្តើមងាកចេញពីការរស់នៅបែបបុរេប្រវត្តិ មកចាប់ប្រកបរបរកសិកម្ម រួចហើយបន្តិចម្តងបានបង្កើតទៅជារដ្ឋមួយឡើង នៅអំឡុងសតវត្សរ៍ទី១គ.ស.គឺនគរគោកធ្លក (ឬនគរភ្នំ) ដែលក្នុងឯកសារចិនហៅក្លាយមកជា "ហ្វូណន"។ ឯកសារចិនឱ្យដឹងថា ភូមិខ្មែរព័ទ្ធជុំវិញដោយកំពែងធ្វើអំពីដី មានគូទឹក ឬស្រះធំៗព័ទ្ធជុំវិញ ដែលមានចិញ្ចឹមក្រពើជាច្រើនផង។ នៅក្នុងបរិវេណភូមិ មានស្រះទឹកសម្រាប់ប្រើរួមគ្នា។ ផ្ទះសង់អំពីឈើបន្តើតខ្ពស់ផុតពីដីហើយប្រក់ស្លឹក។

នៅក្នុងសិលាចារឹកជាភាសាសំស្ក្រឹត គេបានរកឃើញនូវកំណត់ត្រាអំពីដំណើររឿងនៃអាពាហ៍ពិពាហ៍ រវាងម្ចាស់ស្រុក គឺព្រះនាងសោមាជាមួយនឹងព្រាហ្មណ៍ម្នាក់ឈ្មោះ កោណ្ឌញ្ញ ដែលធ្វើដំណើរតាមទូក មកពីទិសខាងត្បូង (អាចមកពីកោះជ្វា ឬស៊ូម៉ាត្រា)។ ចំណែកឯកសារចិនវិញមានកត់ត្រា អំពីអាពាហ៍ពិពាហ៍រវាងព្រះបាទហ៊ុនទៀន និងព្រះនាងលីវយី។ អ្នកប្រាជ្ញខ្លះយល់ថា ដំណើររឿងទាំង៣ខាងលើនេះ គឺជារឿងតែមួយ គ្រាន់តែមានការកត់ត្រាឈ្មោះខុសៗគ្នា។ ក៏ប៉ុន្តែ អ្នកខ្លះទៀត យល់ថា រឿងនេះអាចជាដំណើររឿងផ្សេងគ្នា ដែលកើតឡើងនៅក្នុងទឹកដីខ្មែរដូចគ្នា ប៉ុន្តែក្នុងកាលវេលាខុសគ្នា។

ដោយសារបានទទួលឥទ្ធិពលឥណ្ឌា ដល់ទៅពីរដង គឺដើមសតវត្សទី១ និងដើមសតវត្សទី៥ របបនយោបាយរបស់អាណាចក្រភ្នំ គឺរាជានិយមតាមបែបឥណ្ឌា។ មហារាជមានងារជាស្តេចចក្រវាល ឬកុរុងភ្នំ សោយរាជ្យលើអាណាចក្រដែលមានសាមន្តរដ្ឋ ឬរដ្ឋចំណុះជាច្រើន ក្នុងនោះមានទាំងសាមន្តរដ្ឋចេនឡា ទៀតផង។ ព្រះរាជាគង់ក្នុងព្រះរាជវាំងដែលមានដំណាក់ច្រើនជាន់ មានរបងជុំវិញ។

កំពង់ផែសំខាន់របស់អាណាចក្រភ្នំ គឺអូរកែវ ស្ថិតនៅខាងត្បូងភ្នំបាថេ ក្នុងដែនដីកម្ពុជាក្រោមសព្វថ្ងៃ លើតំបន់ស្ថានីយបុរេប្រវត្តិសាស្ត្រសម័យយុគថ្មរំលីង ដែលអ្នកដើរសមុទ្រជាតិឥណ្ឌា បានស្គាល់តាំងពីយូរលង់ណាស់មកហើយ។ កំពង់ផែនេះមិនមែនគ្រាន់តែទទួលសំពៅធំៗពីប្រទេសចិន ម៉ាឡាយូ និងឥណ្ឌា ប៉ុណ្ណោះទេ ព្រមទាំងបានទទួលនាវាសមុទ្រធំៗ ដែលដឹកទំនិញមកពីចក្រភពរ៉ូម៉ាំង ស្ថិតត្រង់ព្រំប្រទល់សមុទ្រក្រហមថែមទៀតផង។ នៅកំពង់ផែអូរកែវ គេបានរកឃើញត្រាមានអក្សរសំស្ក្រឹត មេដាយមាស មានកាលបរិច្ឆេទឆ្នាំ១៥២ មានរូបសំណាកព្រះចៅ អង់តូនីន និងចម្លាក់ថ្មផ្សេងៗ មកពីតំបន់មេឌីទែរ៉ាណេថែមទៀតផង។

ខាងវិស័យសេដ្ឋកិច្ចវិញ ក្នុងសម័យនគរភ្នំមានឈ្មោះថាថ្កុំថ្កើងរុងរឿងណាស់។ កសិកម្មមានការរីកលូតលាស់ចម្រើនខ្លាំង ដោយសារតែមានជោគជ័យក្នុងនយោបាយទឹក រហូតដល់ឯកសារចិន កត់ត្រាថាគេព្រោះមួយឆ្នាំ គេច្រូតបានបីរដូវ។ ខាងពាណិជ្ជកម្ម ក្រៅពីកំពង់ផែអូរកែវ ដែលជាកំពង់ផែអន្តរជាតិទទួលនាវាផ្ទុកទំនិញធំៗពីគ្រប់ទិសទី

អាណាចក្រភ្នំមានបច្ចេកទេសក្នុងការធ្វើសំពៅធំៗ ដើរតាមសមុទ្រ ដែលតាមឯកសារចិន បញ្ជាក់ថា សំពៅមានប្រវែង ៣០ម៉ែត្រ ដែលមានក្បាល និងកន្ទ្រៃមានរាងជាក្បាល និងកន្ទុយត្រី។

ខាងវិស័យស្ថាបត្យកម្ម និងចម្លាក់វិញ ក្រៅពីប្រាសាទដែលសង់ដោយលុងភ្នំ គ្មានប្រាសាទណានៅគង់វង្សល្អទេ តែគេសន្និដ្ឋានថា ប្រាសាទទាំងឡាយក្នុងសម័យនោះ កសាងឡើងដោយឥដ្ឋ ដោយគេអាចរកឃើញខឿនសំណង់ផ្សេងៗអំពីឥដ្ឋ នៅកំពង់ផែអូរកែវ និងនៅអង្គរបុរី។

ខាងសិល្បៈបដិមា គេបានរកឃើញព្រះពុទ្ធរូប និងទេវរូបជាច្រើន នៅតំបន់ភ្នំដា ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចជាព្រះពុទ្ធរូបវត្តរំលក រូបព្រះវិស្ណុ ព្រះពលរាម ព្រះកល្កិន ព្រះក្រិស្ណ គោវធន។ ស្នាដៃទាំងអស់នេះនៅមានលក្ខណៈជាឥណ្ឌានៅឡើយ ពោលគឺរូបទាំងនោះមានរាងធាត់ៗ កាច់ចង្កេះ និងមានធ្នូ ឬក្រចកសេះ ឬចន្ទល់ទ្រថែមទៀតផង។

## ២- សង្ខេបប្រវត្តិកម្ពុជា

កម្ពុជា ជាដែនដីអាណាចក្រដ៏ធំមួយ ក្នុងចំណោមដែនអាណាចក្រក្នុងពិភពលោក ដែលត្រូវបានអ្នកបុរាណវិទូ និងអ្នកប្រវត្តិសាស្ត្រជាច្រើនបានរកឃើញតាមរយៈការសិក្សាអំពីបុរេប្រវត្តិទាំងតាមរយៈបុរាណវត្ថុ និងទាំងជាសំណេរ។ នៅសម័យមុនសំណេរដែលគេហៅថា សម័យបុរេប្រវត្តិចន្លោះឆ្នាំ៤២៩០ មុនគ.ស.ដល់ឆ្នាំ៥២ នៃគ.ស.នោះ កម្ពុជាត្រូវបានអ្នកប្រវត្តិសាស្ត្រជាទូទៅចាត់ទុកជាដែនដីបុរាណមួយ ដែលមានប្រជាជនរស់នៅតាំងពីសម័យយុគថ្មរំលីងម្លេះ។

អស់រយៈពេលក្រោយៗមកទៀត ប្រជាជនកម្ពុជាសម័យនោះមានការវិវត្តទាំងខាងភាសា និងរបរចិញ្ចឹមជីវិត ព្រមទាំងគំនិតដឹកនាំគ្រប់គ្រងសង្គម រហូតនាំឱ្យមានការបែងចែកវណ្ណៈសង្គម រាស្ត្រ ស្តេច និងជំនឿសាសនាផ្សេងៗ។ ដោយសារការវិវត្តនេះហើយដែលនាំឱ្យមានការចាត់ចែងរបៀបរបបគ្រប់គ្រងសណ្តាប់ធ្នាប់ របៀបរៀបរយ និងសន្តិសុខដើម្បីធានាការរស់នៅរបស់ប្រជាជន។ ប៉ុន្តែ ការវិវត្តនេះក៏បាននាំឱ្យកម្ពុជាមានការប្រែប្រួលទាំងនយោបាយ ទាំងសេដ្ឋកិច្ច និងភូមិសាស្ត្រ ដោយមានការឈ្លោះដណ្តើមអំណាចគ្រប់គ្រង រហូតបែកបាក់ផ្ទៃក្នុង និងការឈ្លានពានពីបរទេសថែមទៀតផង។

កម្ពុជាសម័យអតីតកាល ដែលត្រូវបានគេស្គាល់ និងកត់ត្រាក្នុងឯកសារប្រវត្តិសាស្ត្រ ដូចជា សម័យហ្វូណន ឬសម័យនគរភ្នំ ដែលចាប់ផ្តើមពីចន្លោះឆ្នាំ៥២ នៃគ.ស.រហូតដល់ ឆ្នាំ៥៥០នៃគ.ស.និងជាសម័យកាលដែលខ្មែរបានស្គាល់នូវភាពរុងរឿងបន្តិចម្តងៗ បន្ទាប់ពីឆ្លងកាត់សម័យបុរេប្រវត្តិដ៏យូរលង់នោះ។

ឆ្នាំ៥៥០ នៃគ.ស.ដល់ ៨០២នៃគ.ស. ជាការចាប់ផ្តើមនៃសម័យចេនឡា ដែលត្រូវបានអ្នកប្រវត្តិសាស្ត្រស្គាល់ថាជាសម័យដ៏រុងរឿងមួយ និងបានចាប់ផ្តើមជំនួញជួញដូរច្រើនទាំងផ្លូវទឹកទាំងផ្លូវគោក ហើយចេនឡានេះក៏បានបែកបាក់ទៅជាចេនឡាដីគោក និងចេនឡាទឹក ដែលបង្ហាញពីភាពប្រេះឆាក្នុងប្រវត្តិនៃអាណាចក្រខ្មែរយើងផងដែរ។

រហូតមកដល់កំឡុងឆ្នាំ៨០២ ដែលជាការចាប់ផ្តើមសករាជនៃសម័យអាណាចក្រអង្គរ ដែលជាសម័យប្រវត្តិសាស្ត្រដ៏រុងរឿងបំផុតទាំងវិស័យវប្បធម៌ អរិយធម៌ សង្គម និងទាំងវិស័យសេដ្ឋកិច្ច។ អាណាចក្រ

អង្គរដែលរុងរឿងបំផុត ចាប់ផ្តើមពីការដឹកនាំរបស់ព្រះបាទ ជ័យវរ្ម័នទី២ (រជ្ជកាលគ្រងរាជគ.ស.៨០២-៨៥០)។ ប៉ុន្តែ ទោះជាយ៉ាងណាមុនពេលកាន់អំណាចព្រះបាទជ័យវរ្ម័នទី២ ក៏ធ្លាប់បានច្បាំងគ្នាជាច្រើនលើកច្រើនសារក្នុងចំណោមអតីតស្តេចត្រាញ់ក្នុងតំបន់ ដែលជាអ្នកបានត្រួតត្រាលើទឹកដីកម្ពុជក្នុងភូមិភាគផ្សេងៗ។

**សម័យអង្គរ** ( ៨០២ គ.ស. ដល់ ១៤៣៤ គ.ស. )

នាសម័យនគរហ្វូណន កម្ពុជាមានរាជធានីនៅម៉ុ្ក បាភ្នំ (ខេត្តព្រៃវែងបច្ចុប្បន្ន) ហើយមានវប្បធម៌លាយចម្រុះគ្នា រវាងវប្បធម៌របស់ជនជាតិខ្មែរដើម និងវប្បធម៌ទទួលឥទ្ធិពលពីឥណ្ឌា។ សាសនាក៏ដូចគ្នាដែរ ប្រជារាស្ត្រនៃហ្វូណនគោរពតាមជំនឿសាសនាដើមរបស់ខ្លួនផង ដែលគេហៅថា សាសនាអ្នកតា និងតាមជំនឿសាសនាពីឥណ្ឌាផង គឺដំបូងព្រហ្មញ្ញសាសនានិងបន្ទាប់មកទៀតពុទ្ធសាសនា។

តាមពិត នគរហ្វូណនគឺជាអាណាចក្រមួយ ដែលមាននគរច្រើនជាចំណុះ។ នគរទាំងនេះគ្រប់គ្រងដោយក្សត្រផ្សេងគ្នា មានឯករាជដាច់ចេញពីគ្នា ហើយពេលខ្លះ ថែមទាំងធ្វើសង្គ្រាមរវាងគ្នាទៀតផង គឺដូចជាសង្គ្រាមរវាងស្តេចក្រាញ់ នៅតំបន់អឺរ៉ុប ក្នុងយុគសម័យកណ្តាល ក្រោយការដួលរលំនៃចក្រភពរ៉ូមដូច្នោះដែរ។ បន្តពីសម័យហ្វូណន ជាសម័យចេនឡាដែលមានការរីកចម្រើនច្រើនជាងមុន និងបន្តដោយសម័យដ៏ខ្ពង់ខ្ពស់គឺសម័យអង្គរ។

បន្ទាប់ពីសម័យអង្គរ គេឃើញមានសម័យកាលបន្តបន្ទាប់ក្រោមការដឹកនាំរបស់ស្តេចផ្សេងៗគ្នា ក្នុងនោះមាន៖ សម័យចតុមុខ (គ.ស.

១៩៣៩ ដល់ ១៥២៩ ) សម័យលង្វែក (គ.ស.១៥២៩ ដល់ គ.ស.១៦២០) សម័យឧត្តុង្គ (ឆ្នាំ១៦២០ ដល់ ឆ្នាំ១៨៦៣) សម័យអាណាព្យាបាលបារាំង (ឆ្នាំ១៨៦៣ ដល់ ឆ្នាំ១៩៥៣) សម័យសង្គមរាស្ត្រនិយម (ឆ្នាំ១៩៥៥ ដល់ ឆ្នាំ១៩៧០) សម័យសាធារណរដ្ឋខ្មែរ (ឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥) សម័យកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (ឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៨៩) សម័យរដ្ឋកម្ពុជា (ឆ្នាំ១៩៨៩ ដល់ ឆ្នាំ១៩៩១) និងសម័យអន្តរកាល ឬ (UNTAC) (ឆ្នាំ១៩៩១ ដល់ ឆ្នាំ១៩៩៣)។

នេះគ្រាន់តែជាការលើកឡើងត្រួសៗប៉ុណ្ណោះ អំពីសម័យកាលដែលប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់រាប់ចាប់ពីឆ្នាំ៤២៩០ មុនគ.ស. រហូតដល់ឆ្នាំ១៩៩៣ ប៉ុន្តែអាចនឹងមានសម័យកាលផ្សេងទៀតដែលមិនមានសរសេរក្នុងឯកសារប្រវត្តិសាស្ត្រកម្ពុជា ព្រោះសម័យបុរេប្រវត្តិកម្ពុជាពេលនោះមិនមានសំណេរ ឬភស្តុតាងជាក់លាក់ណាមួយដែលនិយាយច្បាស់អំពីប្រវត្តិសាស្ត្ររបស់មនុស្សដែលដឹកនាំនិងគ្រប់គ្រងដែនដីឈ្មោះថា កម្ពុជាឬខ្មែរនោះឡើយ។ ម្យ៉ាងវិញទៀត នៅក្នុងសម័យកាលនីមួយៗដែលបានលើកឡើងខាងលើនេះក៏នៅមានភាពស្មុគស្មាញចំពោះការសរសេររបស់អ្នកប្រវត្តិសាស្ត្រដែរ ដោយអ្នកប្រវត្តិសាស្ត្រនិងអ្នកនិពន្ធខ្លះសរសេរបានចំពោះតែហេតុការណ៍ និងទិដ្ឋភាពមួយផ្នែកដែលខ្លួនឆ្លងកាត់និងបានដឹងតែប៉ុណ្ណោះ។

## ៣- កម្ពុជាសម័យថ្មី

(គ.ស.១៩៩៣ ដល់ បច្ចុប្បន្ន )

ក្រោយការបោះឆ្នោតជាសកល ដោយសេរី និងយុត្តិធម៌ ឆ្នាំ ១៩៩៣ ក្រោមកិច្ចអន្តរាគមន៍របស់អង្គការសហប្រជាជាតិ (UNTAC) ដែលបង្កើតឱ្យមានរបបគ្រប់គ្រងថ្មី និងមានការចូលរួមពីគណបក្សនយោបាយច្រើនការបោះឆ្នោតពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៣ ក្នុងនោះមានៈ គណបក្សហ៊្វុនស៊ិនប៉ិច (សម្តេចនរោត្តម រណឫទ្ធិ) គណបក្សប្រជាជនកម្ពុជា (អតីតរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា) គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា (លោកតា សឺន សាន) គណបក្សម៉ូលីណាកានិងអ្នកតស៊ូខ្មែរ។

ក្រោយពីការបោះឆ្នោត សភាធម្មនុញ្ញបានរៀបចំតាក់តែងរដ្ឋធម្មនុញ្ញថ្មី និងបានអនុម័តនាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

ផ្អែកលើរដ្ឋធម្មនុញ្ញនេះហើយ ដែលប្រទេសកម្ពុជាបានក្លាយទៅជា«ព្រះរាជាណាចក្រកម្ពុជា» ប្រកាន់លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងអាស្រ័យរដ្ឋធម្មនុញ្ញ។

## <u>ការកសាងសន្តិភាពពិត</u>

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនិងអាស្រ័យរដ្ឋធម្មនុញ្ញ ដែលទទួលស្គាល់ជាផ្លូវការពីប្រទេសនានាលើសកលលោក ក៏ប៉ុន្តែកម្ពុជានៅមិនទាន់មានសន្តិភាពពេញលេញនៅឡើយទេ ព្រោះពួកខ្មែរក្រហមដែលកាន់កាប់តំបន់មួយភាគធំតាមព្រំដែនខ្មែរ ថៃ នៅប៉ែកខាងជើង និងប៉ែកពាយ័ព្យនៃប្រទេសកម្ពុជា មិនព្រមចូលរួមក្នុងការបោះឆ្នោត និងនៅតែបន្តគំរាមកំហែងសន្តិ

សុខជាតិ។ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៤ សភាជាតិបានសម្រេចដាក់ពួកខ្មែរក្រហមឱ្យនៅក្រៅច្បាប់។

ដើម្បីសន្តិសុខនិងការរួបរួមមួយដ៏ពិតប្រាកដ រាជរដ្ឋាភិបាលនៅតែបន្តចរចារជាមួយពួកខ្មែរក្រហមតាមគោលនយោបាយឈ្នះ-ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែន។ រហូតមកដល់នៅចុងឆ្នាំ១៩៩៨ និងដើមឆ្នាំ១៩៩៩ ទើបក្រុមខ្មែរក្រហមបានធ្វើសមាហរណកម្មទាំងស្រុងចូលរួមជាមួយរាជរដ្ឋាភិបាល ហើយកម្ពុជាបានទទួលនូវសន្តិភាពពេញលេញបន្ទាប់ពីការអនុវត្តនូវគោលនយោបាយឈ្នះ-ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែន។

ជារួម គោលនយោបាយឈ្នះ-ឈ្នះ បានប្រែក្លាយប្រទេសកម្ពុជាឱ្យមានសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គមពេញលេញ ហើយអនុញ្ញាតឱ្យកម្ពុជាមានឱកាសក្នុងការកសាងនិងអភិវឌ្ឍន៍រហូតមកដល់ពេលបច្ចុប្បន្ននេះ។

## ៤- សម័យកាលប្រវត្តិសាស្ត្រ

ប្រវត្តិសាស្ត្រកម្ពុជា តាមកាលសម័យកំណត់ ដូចខាងក្រោម ៖

- កម្ពុជាបុរេប្រវត្តិសាស្ត្រ (៤២៩០ឆ្នាំមុនគ.ស. ដល់ឆ្នាំ៥២នៃគ.ស.)
- សម័យហ្វូណន (៥២ គ.ស. ដល់ ៥៥០ )
- សម័យនគរចេនឡា (សវត្សទី៦-សវត្សទី៩)
- សម័យចេនឡា (គ.ស.៥៥០ ដល់ ៧០៦ )
- ចេនឡាទឹកលិច (គ.ស.៧០៦ -៨០២)
- សម័យអង្គរ (គ.ស.៨០២ ដល់ ១៤៣៤)

- សម័យចតុមុខ ( គ.ស.១៤៣៤ ~ ១៥២៨ )
- សម័យលង្វែក ( គ.ស.១៥២៨ ~ ១៦២០)
- សម័យឧត្តុង្គ (គ.ស.១៦២០ ~ ១៨៦៣ )
- សម័យអាណាព្យាបាលបារាំង ( គ.ស.១៨៦៣ ~ ១៩៥៣ )
- សម័យសង្គមរាស្ត្រនិយម ( គ.ស.១៩៥៥ ~ ១៩៧០ )
- សម័យសាធារណរដ្ឋខ្មែរ ( គ.ស.១៩៧០ ~ ១៩៧៥ )
- សម័យកម្ពុជាប្រជាធិបតេយ្យ ( គ.ស.១៩៧៥ ~ ១៩៧៩ )
- សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា(គ.ស.១៩៧៩ ~ ១៩៨៩ )
- សម័យរដ្ឋកម្ពុជា ( គ.ស.១៩៨៩ ~ ១៩៩១ )
- សម័យអន្តរកាលគ្រប់គ្រងដោយ UNTAC (គ.ស.១៩៩១ ~១៩៩៣ )
- សម័យព្រះរាជាណាចក្រកម្ពុជាទី២ ( គ.ស.១៩៩៣ ~ បច្ចុប្បន្ន )

## សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេលប្រមាណជាជាង ៦០០ឆ្នាំ ចាប់តាំងពីដើមសតវត្សរ៍ទី៩ រហូតដល់ពាក់កណ្តាលសតវត្សរ៍ទី១៥ អាណាចក្រខ្មែរបានស្គាល់នូវភាពរុងរឿង ក្នុងឋានៈជាមហាអំណាច នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ នៅក្នុងអំឡុងពេលនោះ អាណាចក្រខ្មែរបានគ្រប់គ្រងទឹកដីដ៏ធំ ដែលគ្របដណ្តប់លើទឹកដីកម្ពុជា ថៃ ឡាវ និងប៉ែកខាងត្បូងប្រទេសវៀតណាមបច្ចុប្បន្ន។ ព្រំដែននៃអាណាចក្រខ្មែរលាតសន្ធឹងរហូតទៅដល់ប្រទេសចិន នៅប៉ែកខាងជើង ភូមា នៅប៉ែកខាងលិច ម៉ាឡេស៊ី នៅប៉ែកខាងត្បូង និងនគរចម្ប៉ានៅខាងកើត។

នេះជាប្រវត្តិនៃប្រទេសកម្ពុជា ដែលបានរៀបរាប់ត្រួសៗយ៉ាង

សង្ខេប ដើម្បីយើងអាចយល់បាន អំពីប្រវត្តិកម្ពុជា ជាមួយនឹងពិភពលោកយ៉ាងដូចម្តេច និងជាមួយប្រវត្តិនៃភពផែនដី យ៉ាងដូចម្តេច។ ប្រទេសកម្ពុជា ជាប្រទេសមួយ នៅក្នុងចំណោមប្រទេសនានាជាច្រើននៅ ក្នុងពិភពលោក និងស្ថិតនៅក្នុងចក្រវាលផងដែរ ។

អាណាចក្រអង្គរដ៏រុងរឿង (Angkor Empire) បានត្រូវរលំរលាយក្រោយសម័យអង្គរ និងជាពិសេសក្រោយសម័យលង្វែក ។ កម្ពុជាទើបនឹងងើបឡើងវិញបានក្នុងសម័យព្រះបាទ នរោត្តម សីហនុ ហើយក៏ត្រូវរលាយខ្ទេចខ្ទី ដោយសង្គ្រាមនៅសម័យលោក លន់ នល់ និងសម័យប៉ុល ពត បន្ទាប់មកក៏បានរុងរឿងឡើងវិញ នៅសម័យសម្តេចតេជោហ៊ុន សែន។

# ជំពូកទី១១
# អនាគតនៃប្រទេសក្នុងតំបន់និងក្នុងពិភពលោក

## ការព្យាករអនាគតប្រទេសនានាជាទូទៅ

ការទស្សន៍ទាយពីអនាគតរបស់ប្រទេសខ្លួនឱ្យប្រាកដ ក្នុងរយៈពេលវែងឆ្ងាយ រាប់ម៉ឺនឆ្នាំ ជាការលំបាក ទាយមិនត្រូវ ។

សម្រាប់១០០ឆ្នាំទៅមុខ គេអាចទស្សន៍ទាយបានតាមរយៈការប្រមើលមើល សម្រាប់អនាគតប្រទេសរបស់ខ្លួន ប៉ុន្តែមិនមានប្រទេសណា គេធ្វើផែនការអភិវឌ្ឍន៍ ឬគោលនយោបាយសម្រាប់រយៈពេល ១០០ឆ្នាំទេ។ ប្រទេសខ្លះ ក៏គេប្រកាសអំពីមិត្តភាពម៉ឺនឆ្នាំ នេះគ្រាន់តែជាឆន្ទៈនយោបាយទេ ឬជាការលើកទឹកចិត្តប្រជាជន។

សម្រាប់១,០០០ឆ្នាំ គេគ្រាន់តែអាចប្រមើលមើល ដោយប៉ាន់ស្មានប្រហាក់ប្រហែល ព្រោះថា ប្រវត្តិសាស្ត្រមនុស្សជាតិ ក្នុង១០សតវត្សចុងក្រោយនេះ ប្រទេសជាច្រើន មានការប្រែប្រួលខ្លាំងណាស់។ ប្រទេសមួយចំនួនក៏បានរលាយបាត់ ប្រទេសថ្មីមួយចំនួនក៏បានកើតឡើង។

ប៉ុន្តែសម្រាប់១០,០០០ឆ្នាំទៅមុខ គេមិនអាចទាយឱ្យប្រាកដបានទេ ប្រទេសខ្លះបានតែធ្វើការប្តេជ្ញា តែតាមការពិត គឺវាអាស្រ័យយ៉ាងខ្លាំង ទៅលើធម្មជាតិ ធាតុអាកាស សង្គ្រាម និងកត្តាសត្យានុម័តជាច្រើនទៀត ។

អរិយបុគ្គលជាច្រើននៅក្នុងសាសនានានា បានធ្វើការទស្សន៍ទាយច្រើនដែរ ចំពោះអនាគតនៃពិភពលោក។ ភាគច្រើននៃសាសនាគេតែងនិយាយអំពីភ្លើងឆេះកប្ប គឺជាការរលាយឆេះនៃភពផែនដី ដែលបណ្តាលមកពីមនុស្សចេះតែប្រព្រឹត្តអំពើបាបកម្ម កាន់តែច្រើនឡើងៗ។

ប៉ុន្តែ ការនិយាយទស្សន៍ទាយនេះ គ្រាន់ជាការគិតការស្រមៃ របស់ថ្នាក់ដឹកនាំសាសនា ដែលជាអ្នកចេះដឹង ជាអ្នកឆ្លាតវៃតែប៉ុណ្ណោះ តែមិនមានមូលដ្ឋានវិទ្យាសាស្ត្រ ឬភស្តុតាងបង្ហាញទេ ។

ចំណែកខាងវិទ្យាសាស្ត្រវិញ គេអាចប៉ាន់ស្មានដឹងច្រើនជាង ដោយប្រើនូវបទពិសោធន៍ ទ្រឹស្តី របកគំហើញ និងឧបករណ៍ទំនើបៗនានា ។

មានប្រទេសថ្មីៗជាច្រើនកើតឡើង ដែលពីមុនមកគ្មានអ្នកណាបានស្មានឬទស្សន៍ទាយដឹងមុន ហើយប្រទេសទាំងនោះ ក៏រីកចម្រើនយ៉ាងរហ័ស ដូចជា សហរដ្ឋអាម៉េរិក ប្រទេសកាណាដា ប្រទេសអូស្ត្រាលី ជាដើម។

ប្រទេសចាស់ៗមួយចំនួនទៀត បានបែកបាក់គ្នា ចុះខ្សោយ ហើយក៏រលាយបាត់ទៅ ដូចជាចក្រភពរ៉ូមាំង អូតតូម៉ាន់ ជាដើម។

មនុស្សខិតខំកសាងសហគមន៍ កសាងប្រទេសរបស់ខ្លួន តែវាសនា ជាអ្នកកំណត់ ថាប្រទេសនោះ នឹងក្លាយទៅជាយ៉ាងណា។

អ្នកដឹកនាំ ជាមនុស្ស ជាកត្តាសំខាន់ណាស់ ក្នុងការដឹកនាំប្រទេសឱ្យមានការរីកចម្រើន ឬសុខសន្តិភាព ។

លោក នួន ឃឿន ជាសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រ ដែលបានសរសេរសៀវភៅមួយឈ្មោះថា ដំណើរឆ្ពោះទៅទិសខាងលិច គាត់បានទស្សន៍ទាយថា ប្រទេសកម្ពុជានៅឆ្នាំ២០០០ នឹងត្រូវរលាយបាត់ពីផែនទីពិភពលោក។ តែការទស្សន៍ទាយ របស់គាត់មិនត្រឹមត្រូវទេ ប្រទេសកម្ពុជាមិនបានរលាយ ដូចជាគាត់សរសេរនោះទេ។ អ្វីៗប្រែប្រួល និងអាចកើតឡើងទៅផ្សេង ដែលមនុស្សមិនអាចទស្សន៍ទាយត្រូវបាន។

ចក្រភពខ្មែរជាចក្រភពកើតឡើងក្រោយគេ ពី ស.វ. ទី ៧ ដល់ ស.វ. ទី១២ បានរយៈពេល៥០០ឆ្នាំ ហើយក្រោយមកក៏បានដួលរលំទៅ ដោយសារតែកត្តាធំមួយ គឺការបាក់បែកផ្ទៃក្នុង។ ជាភ័ព្វសំណាង ចក្រភពខ្មែរមិនបានរលាយសូន្យទៅ ដូចជាចក្រភពធំៗនានា លើពិភពលោកទេ ពោលគឺបាននៅសល់ទឹកដីខ្លះដែរ ដូចមានសព្វថ្ងៃនេះ។

## ការឡើងកម្តៅនៃធាតុអាកាសប្រទេសកម្ពុជា

តាមការអង្កេតរបស់អ្នកវិទ្យាសាស្ត្រ បង្ហាញថា ផែនដីយើងមានការឡើងកម្តៅ កម្ពុជាក៏ទទួលរងឥទ្ធិពល និងជួបបញ្ហានេះដែរ [32]។ អ្នកស្រាវជ្រាវខ្លះបានទស្សន៍ទាយថា កម្តៅនឹងកើនឡើង ខ្លាំងជាងការរំពឹងទុក។ ក្នុង៥០ឆ្នាំទៀត បើមនុស្សមិនខិតខំដោះស្រាយបញ្ហាបរិស្ថានបច្ចុប្បន្ននេះទេ នោះនៅឆ្នាំ២០៧០ គេទស្សន៍ទាយថាប្រទេសដែលមនុស្សរស់នៅលែងបាន គឺប្រទេសដែលស្ថិតនៅជិតខ្សែអេក្វាទ័រ។ ឥឡូវនេះ នៅលើផែនដីយើង មានកន្លែងតែ១%ទេ ដែលមិនអាចរស់នៅបាន ប៉ុន្តែដល់ឆ្នាំ២០៧០ នឹងមានទៅដល់២០% ដែលរស់នៅមិនបាន ហើយកម្ពុជា ក៏មានចូលក្នុងនោះដែរ។ ២០% ប៉ះពាល់ជីវិតមនុស្ស ដល់ទៅជិត១,០០០លាននាក់ ហើយមនុស្សទាំងអស់ត្រូវតែចាកចេញពីទឹកដីទាំងនោះ ទៅរកកន្លែងរស់ថ្មី ព្រោះកន្លែងចាស់វាក្តៅខ្លាំងពេក ។

---

[32] The Kanitha Show, July 25, 2020

គេទស្សន៍ទាយថា នៅឆ្នាំ២០៧០ ស្ថានភាពកម្ដៅនៅតាមប្រទេសស្ថិតក្បែរខ្សែអេក្វាទ័រក្នុងនោះក៏មានកម្ពុជាដែរ សីតុណ្ហភាពនឹងកើនឡើងច្រើនជាងបច្ចុប្បន្ននេះ ដែលជះឥទ្ធិពលខ្លាំងដល់វិស័យកសិកម្ម។

តាមការសង្កេត ចាស់ៗនិយាយថា ពីមុនមិនមែនក្ដៅដូចសព្វថ្ងៃនេះទេ។ ឥឡូវនេះ អាកាសធាតុកាន់តែក្ដៅឡើង។ ការឡើងកម្ដៅនៃផែនដី គឺមានម្ដងបន្តិចៗ។ ឆ្នាំខ្លះឡើង ឆ្នាំខ្លះចុះ ធ្វើឱ្យមនុស្សលោកមិនសូវចាប់អារម្មណ៍។ អ្នកវិទ្យាសាស្ត្រ បានវាស់ កាបូនឌីអុកស៊ីដ ($CO_2$) គេបានវាស់និងកត់ត្រា គេឃើញថា មានការកើនឡើងកើនឡើងរហូត ។ មូលហេតុ ដោយសារមនុស្សយើង ដុតហ្វូសស៊ីល ធ្យូងថ្ម ប្រេងកាត .. ចេញជាផ្សែង ហោះចូលទៅក្នុងបរិយាកាស ដូច្នេះ ពន្លឺព្រះអាទិត្យដែលបាញ់ចូលមកក្នុងបរិយាកាសនៃផែនដី មិនអាចផ្លាតចេញទៅវិញរួចដោយសារផ្សែងឡាននិងផ្សែងនានា ចាប់ពន្លឺព្រះអាទិត្យជាប់។ យូរទៅៗ អាកាសធាតុនៃផែនដី មានការប្រែប្រួល ទៅជាកាន់តែក្ដៅ។ ដល់ពេលនោះ នៅលើផែនដីយើង ក៏ឧស្សាហ៍មានខ្យល់ព្យុះធំៗច្រើនជាងមុន ភ្លៀងក៏ខ្លាំងជាងមុន កន្លែងខ្លះរាំងស្ងួតខ្លាំង កន្លែងខ្លះទឹកភ្លៀងធ្លាក់ច្រើនពេក ក៏កើតជា គ្រោះទឹកជំនន់ ការលិចលង់។ ឧទាហរណ៍ ជាក់ស្ដែង កាលពីប្រមាណ៥០ឆ្នាំមុន នៅតាមបឹងបួរនានា មានទឹកច្រើន ឥឡូវនេះ បឹងបួរនានា ហួតហែងអស់ ឬក៏ទឹករាក់ជាងមុនច្រើន ។ កន្លែងខ្លះ ប្រជាជនក៏ទៅធ្វើស្រែនៅកណ្ដាលបឹង ដែលពីកាលពីមុន មានទឹកជ្រៅៗ។

ហេតុដូចម្ដេច ក៏មនុស្សលោកមិនមានវិធានការទប់ស្កាត់ ។ ក្នុងបរិការណ៍នេះ មានមូលហេតុច្រើន មូលហេតុមួយចំនួន គឺមកពីអ្នកខ្លះគិត

តែពីចង់បានប្រាក់ចំណេញ សម្រាប់ខ្លួនឯងជាមុនសិន ដោយមិនទាន់គិតពីប្រយោជន៍រួមទេ ឧទាហរណ៍ ក្រុមហ៊ុនលក់ប្រេងឆៅ ក្រុមហ៊ុនផលិតរថយន្ត ផលិតធ្យូងថ្ម ក្នុង១០០ឆ្នាំនេះ ក្រុមហ៊ុនទាំងនេះ ទិញទឹកចិត្តរដ្ឋាភិបាល ក្នុងពិភពលោក ហើយគេបានខិតខំកែប្រែច្បាប់ ធ្វើម៉េចឱ្យពួកគេរកស៊ីមានបានចំណេញច្រើន។ ដោយសារការឡើងកម្តៅនៃភពផែនដីដែលមានម្តងបន្តិចៗ មិនងាយនឹងមើលឃើញច្បាស់ដោយភ្នែកទទេភ្លាមៗទេ។ ទើបតែបច្ចុប្បន្ននេះ ទើបគេចាប់ផ្តើមប្រើជា ថាមពលសឡា ឬខ្យល់ ឬបរមាណូ។ល។ ជំនួសវិញ។

ប្រទេសជឿនលឿន ណែនាំឱ្យប្រទេសក្រីក្រ ឬប្រទេសកំពុងអភិវឌ្ឍ ដូចជា ចិន ឥណ្ឌា ឬប្រទេសតូចៗ ទាំងឡាយ ឱ្យឈប់ប្រើឬកាត់បន្ថយ ការប្រើប្រេងឥន្ធនៈ ធ្យូងថ្ម ឬហ្វូស៊ីល តទៅទៀត។ ប៉ុន្តែប្រទេសតូចៗមិនព្រម គេថាប្រទេសជឿនលឿន បានអភិវឌ្ឍប្រទេសរបស់ខ្លួនរួចហើយ ទើបបានមកឃាត់គេមិនឱ្យអភិវឌ្ឍ។ ដូច្នេះ នេះជាបញ្ហាដែលមិនមែនបញ្ចប់ដោយងាយទេ។ គេនិយាយថា បើចាំអភិវឌ្ឍប្រទេសបានទាំងអស់គ្នាហើយទើបបានឈប់ប្រើចំហេះហ្វូសស៊ីល គឺវាហួសពេលហើយ។ សម្រាប់ប្រទេសត្រជាក់ គេមិនសូវព្រួយបារម្ភអំពីការឡើងកម្តៅទេ តួយ៉ាង ដូចប្រទេស រុស្ស៊ី កាណាដា ជាដើម។ ប្រទេសដែលពិបាក គឺប្រទេសនៅតំបន់ក្តៅ តំបន់ម្តុំខ្សែអេក្វាទ័រ។

ទឹកសមុទ្រនឹងកើនឡើងខ្ពស់ជាងមុន ឧទាហរណ៍ ប្រទេស បង់ក្លាដេស ប្រជាជនរត់គេចទៅប្រទេស ឥណ្ឌា ភូមា ឬប្រទេសជិតខាងផ្សេងទៀត ។

អ្នកបរិស្ថានបានព្យាករថា ដល់ឆ្នាំ២០៧០ នៅតំបន់ដីសណ្តទន្លេមេគង្គ ពេលដែលកម្រិតទឹកទន្លេធ្លាក់ចុះទាប ប្រទេសវៀតណាមផ្នែកខាងត្បូង ទឹកសមុទ្រអាចនឹងចូលមកកាន់តែជ្រៅ ចូលមកក្នុងទន្លេ និងដៃទន្លេនានា ហើយប្រជាជន១២លាននាក់ត្រូវរត់គេចចេញ ដោយបុព្វហេតុកសិកម្ម។ ទឹកប្រៃអាចឈានចូលតាមទន្លេមេគង្គមកដល់ ក្រុងអ្នកលឿង ប្រទេសកម្ពុជា។ ដើម្បីជួយកាត់បន្ថយបញ្ហាបរិស្ថាន សម្រាប់ប្រទេសកម្ពុជា ការដាំដើមឈើឱ្យបានច្រើននិងគ្រប់ទីកន្លែង អាចជាការចូលរួមជួយកាត់បន្ថយកម្រិតកម្តៅបានដែរ។

# ជំពូកទី១២
# និយមន័យជីវិតនៅលើផែនដី

មានអ្នកដែលមានប្រាជ្ញា អ្នកស្រាវជ្រាវ អ្នកប្រាជ្ញធំៗ ជាច្រើន បានខំពិចារណា អំពីជីវិតនៅលើផែនដី អំពីការរស់នៅ អំពីភពផែនដី ដោយឈរលើ ការគិត ព័ត៌មាន ឧបករណ៍ និងបទពិសោធន៍នានា។

មុនគ្រិស្តសករាជ មានអ្នកប្រាជ្ញជាច្រើន ក៏បានគិតពីទស្សនវិជ្ជានេះដែរ ដូចជា លោក សូក្រាត (Socrates: 469-399 BC); លោក ប្លាតុង ជនជាតិក្រិក (Plato: 429-347 BC); អារីស្តូត (Aristotle: 384-322 BC); លោក ពីតាហ្គ័រ; ខុងជឺ ប្រទេសចិន។

នៅប្រទេសឥណ្ឌា ប្រមាណកាលពី២៥៦៤ឆ្នាំមុន (៥៦៤ឆ្នាំមុនគ្រិស្តសករាជ) ព្រះពុទ្ធ(Buddha) លោកបានខិតខំពិចារណារឿងជីវិតមនុស្ស សត្វ ដែរ។ លោកជាព្រះរាជបុត្រ របស់ព្រះអធិរាជដ៏មានអំណាច និងមានទ្រព្យសម្បត្តិមហាសាល។ លោកធ្លាប់គង់និងបានរៀនសូត្រនៅក្នុងព្រះបរមរាជវាំង ជាមួយរាជគ្រូធំៗដែលជាកន្លែងប្រភពនៃចំណេះវិជ្ជា អ្នកចេះដឹង គម្ពីរ សាស្ត្រា ចំណេះដឹងទូលំទូលាយ។ល។

ប៉ុន្តែបន្ទាប់មក ព្រះពុទ្ធលោកបានបោះបង់ចោលរាជសម្បត្តិ ដើម្បីស្វែងរកសេចក្តីពិតនៃជីវិត។ លោកសង្កេតឃើញថា មានជីវិត គឺមានទុក្ខ «អនិច្ចំ ទុក្ខំ អនត្តា » ។ តើត្រូវធ្វើដូចម្តេច ដើម្បីឱ្យបានចាកផុតទុក្ខវេទនា សព្វបែបយ៉ាងដែលមនុស្សកំពុងមានសព្វថ្ងៃ ។ លោកបានស្វែងរកលោកគ្រូធំៗល្បីៗជាច្រើនទៀត បានរៀនអស់ហើយ តែនៅតែរកមិនឃើញ។ នៅអាយុ ២៩ឆ្នាំ ព្រះអង្គបានទៅអង្គុយធ្វើសមាធិ ធ្វើវិបស្សនា

ចំណាយអស់ពេល៦ឆ្នាំ ចុងក្រោយទើបលោករកឃើញសេចក្តីពិត បានត្រាស់ដឹង ហើយក៏បានផ្សព្វផ្សាយប្រាប់គេឯងអំពីរឿងនេះ។ ព្រះពុទ្ធលោកមានព្រះជន្មបាន៨០ព្រះវស្សា។

ចំពោះ ព្រះយេស៊ូ (Jesus Christ) ក៏លោកបានខិតខំពន្យល់សេចក្តីពិត និងបានធ្វើការផ្សព្វផ្សាយដំណឹងល្អពីព្រះវរបិតា (God Father) ដល់សាធារណជនទាំងអស់ អំពីអ្វីដែលជា ផ្លូវត្រូវ អំពើល្អ តើត្រូវរស់នៅដោយរបៀបណាឱ្យបានសុខ សន្តិភាព សុភមង្គល ក្នុងជីវិត។ ព្រះយេស៊ូមានព្រះជន្មបាន៣៣ឆ្នាំ។

ចំណែកឯព្រះមហាម៉ាត់ (ឆ្នាំ៥៧០-ឆ្នាំ៦៣២) លោកបានទទួលបន្ទូលផ្ទាល់ពីព្រះអាទិទេព(ព្រះអ័លឡោះ) រួចក៏យកព្រះបន្ទូល មកបានបង្រៀនដល់មនុស្សនានា អំពីការប្រព្រឹត្តល្អ វិន័យល្អ តើត្រូវធ្វើម៉េចឱ្យរស់នៅប្រកបដោយ សុខសន្តិភាព សុភមង្គល។ ព្រះមហាម៉ាត់ លោកមានព្រះជន្មបាន៦៣ឆ្នាំ។

ដូច្នេះ បុព្វការីជនធំៗ អរិយបុគ្គលនានា តែងតែប្រើខួរក្បាល ខំគិតអំពីថាតើត្រូវរស់នៅរបៀបណា? ព្រោះថា ឃើញសត្វក្នុងធម្មជាតិ រស់នៅតាមយថាកម្ម មិនមានគោលការណ៍ច្បាស់លាស់ ស៊ីសាច់ហុតឈាមគ្នា សត្វធំខ្លាំងរំលោបធ្វើបាបសត្វតូចទន់ខ្សោយ ។ល។

ទស្សនៈខ្លះ ដូចជា ព្រះពុទ្ធសាសនា ជាដើម បានគិតថា សូម្បីតែរុក្ខជាតិ ក៏មានជីវិតដែរ។ ការសម្លាប់ រុក្ខជាតិ ក៏ជាអំពើបាបដែរ កាលពីនៅជំនាន់ដើម គេមិនដឹងថា ពួកសត្វល្អិតតូចៗ ដូចជា អាមីប បាក់តេរី ឬវីរុស ក៏ជាសត្វមានជីវិតដែរ បើយើងប្រើថ្នាំ លេបថ្នាំសម្លាប់វា ដើម្បី

ព្យាបាលជំងឺ ក៏ជាការសម្លាប់ជីវិតមួយដែរ តែក៏មានការពន្យល់ដោយឡែកនិងបកស្រាយខុសៗគ្នា។

## និយាយពីជីវិតក្រោយពេលស្លាប់

អ្នកប្រាជ្ញខាងសាសនាជាច្រើនបានគិតនិងយល់ឃើញខុសៗគ្នា។ ខាងគ្រិស្តសាសនា និងខាងអ៊ិស្លាមសាសនា គេជឿថា ក្រោយពេលស្លាប់ ព្រលឹងរបស់មនុស្ស នឹងហោះទៅឋានសួគ៌ ទៅជួបនឹងព្រះវិញ ឬក៏ចុះទៅឋាននរក ហើយគ្មានការចាប់ជាតិឡើងវិញទេ។ រីឯព្រះពុទ្ធសាសនា ហិណ្ឌូ ព្រហ្មញ្ញសាសនា ជឿថានឹងមានការចាប់ជាតិឡើងវិញទៅជាមនុស្ស ឬសត្វ ផ្សេងៗ ។ល។ ជីវិតក្រោយពេលស្លាប់ មានតែព្រះពុទ្ធ និងព្រះអរហន្តទេ ដែលព្រះអង្គលោកចូលនិព្វាន គឺសូន្យ គ្មានការកើត ចាប់ជាតិឡើងវិញទេ។

ចំណែកឯខាងអ្នកវិទ្យាសាស្ត្រវិញជឿថា ក្រោយពេលស្លាប់ គឺសូន្យ គ្មានមានព្រលឹងវិញ្ញាណអ្វីទេ ព្រោះក្រោយពេលស្លាប់ កោសិកាខួរក្បាល បែកធ្លាយ ដាច់សរសៃអស់ គ្មានលទ្ធភាពក្នុងការគិតអ្វីទៀតបានទេ ។ កោសិកា ម៉ូលេគុល អាតូម ក៏បែកដាច់ចេញពីគ្នា។ យោងតាមអាណាតូមី (anatomy) ខួរក្បាលរបស់មនុស្សមាន ១៧ផ្នែកឬក្លែប (lobe) ដែលផ្នែកនីមួយៗ មានភារកិច្ចខុសៗគ្នា។ មានផ្នែករក្សាការចងចាំ ផ្នែកគិតពិចារណា ផ្នែកឆ្លើយតប ផ្នែកទទួលព័ត៌មានពីភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ផ្នែកបញ្ជាទៅអវយវៈ។ល។ បើផ្នែកណាមួយ ក្នុងចំណោមផ្នែកទាំង១៧នេះ ខូចលែងធ្វើការ គឺមនុស្សនោះត្រូវពិការកន្លែងណាមួយហើយ។

ផ្នែកវេជ្ជសាស្ត្រ បានគូសសង្ខេបទម្រង់សង្ខេបនៃខួរក្បាលរបស់មនុស្សដូចរូបភាពខាងក្រោម ដែលបញ្ជាក់ពីទីតាំងនិងមុខងារ។




ខួរក្បាលរបស់មនុស្ស

សាសនាខ្លះមិនទទួលស្គាល់មុខងារនេះទេ គេជឿថាចិត្តនិងការគិត ស្ថិតនៅក្នុងបេះដូងរបស់មនុស្សទៅវិញ។

ខាងអ្នកវិទ្យាសាស្ត្រគេជឿថា រូបធាតុកើតមុន វិញ្ញាណកើតក្រោយ។ មនុស្សកើតមុន ទើបព្រះអាទិទេពកើតក្រោយ។ មនុស្សកើតហើយទើបបានមនុស្សនាំគ្នាបង្កើតជា ព្រះអាទិទេពដើម្បីគោរពបូជា។ គេសិក្សាថា កាលពីជំនាន់សត្វដាយណូស័រ ឬជំនាន់ទើបនឹងកកើតបាក់តេរីដំបូងលើផែនដី កាលនោះក៏មិនទាន់មានអាទិទេពដែរ។ ទាល់តែមានកកើតជាមនុស្ស មនុស្សចេះគិត ហើយចាប់ផ្តើមមានជំនឿ មានការគោរពព្រះអាទិត្យ ព្រះចន្ទ ខ្យល់ រន្ទះ។ល។ បន្ទាប់មកក៏មានជាព្រះអាទិទេពជាច្រើនផ្សេងៗគ្នា ហើយសាសនាក៏មានកើតឡើងជាច្រើនផងដែរ។

អ្នកវិទ្យាសាស្ត្រជឿថា ឋានសួគ៌គ្មានទេ ព្រោះក្រៅពីភពផែនដី ភពផ្សេងទៀតក្នុងប្រព័ន្ធព្រះអាទិត្យ មិនអាចមានជីវិតរស់បានទេ។ រីឯនៅក្នុងហ្គាឡាក់ស៊ីផ្សេងទៀត ក៏គេមិនទាន់រកឃើញវត្តមាននៃជីវិតដែរ។ អ្នកវិទ្យាសាស្ត្រយល់ថា ទោះបីជាមានការចាប់ជាតិជាមនុស្សថ្មីម្នាក់ទៀត ក៏មនុស្សថ្មីនោះ មិនដឹងថាខ្លួនពីជាតិមុនជាអ្នកណាដែរ ពោលគឺគេបាត់អត្តសញ្ញាណរបស់ខ្លួនអស់ទៅហើយ។ ដូច្នេះ នេះគ្មានភាពជាប់គ្នាទេ (continuity) ។

**ការចាប់ជាតិ (la reincarnation)**

ជារួម មានតែព្រះពុទ្ធសាសនានិងសាសនាហិណ្ឌូទេ ដែលបានកំណត់និងជឿថា មនុស្សមានការចាប់ជាតិ ឡើងវិញសារជាថ្មី ។ រីឯសាសនាដទៃទៀត ដូចជា គ្រិស្តសាសនាឬអ៊ិស្លាមសាសនា បានកំណត់ជឿថា មនុស្សមិនមានការចាប់ជាតិ ច្រើនជាតិតទៀតទេ ។

**ជាតិនេះចាំថាខ្លួនជាអ្នកណា / ជាតិនេះអត់ចាំថាជាតិមុនជាអ្នកណា (ការបាត់អត្តសញ្ញាណ)**




នៅពេលមនុស្សម្នាក់ បាត់ការចងចាំឬមានបញ្ហាខួរក្បាលធ្ងន់ធ្ងរ តុលាការ គេលើកលែងទោសឱ្យទាំងអស់ ព្រោះថាមនុស្សនោះ ទុកដូច

ជា មនុស្សរុក្ខជាតិ។ គេមិនដែល កាត់ទោស សត្វឆ្កែ ឬសត្វមាន់ទេ ដោយសារសត្វមិនមានសតិសម្បជញ្ញៈ។ បើឆ្កែឆ្កួត គេវាយសម្លាប់ ដោយសារខ្លាចវា ទៅខាំគេតទៅទៀត ឬក៏គេមិនដែលកាត់ទោស ដើមឈើដែរ។

ក្នុងព្រះពុទ្ធសាសនា ជាទូទៅគេយល់ថានិព្វានគឺសូន្យ មិនមានការចាប់ជាតិឡើងវិញទេ និព្វានជាគោលបំណងខ្ពស់បំផុតនៅក្នុងព្រះពុទ្ធសាសនា ដោយសារនៅក្នុងគម្ពីរសរសេរថាអ្នករស់នៅឋានសួគ៌ ចុងក្រោយក៏គង់តែធ្លាក់មកចាប់ជាតិមកនៅលើផែនដីវិញទេ។ ប្រកបដោយប្រាជ្ញាដ៏កំពូល ព្រះពុទ្ធលោកពន្យល់មនុស្សម្នាក់ៗ ទៅតាមឧបនិស្ស័យរៀងៗខ្លួន សម្រាប់អ្នកមិនសូវមានប្រាជ្ញា លោកពន្យល់ដោយនិទានរឿងឱ្យស្តាប់ សម្រាប់អ្នកចេះដឹងច្រើន លោកពន្យល់ជាគំនិតពិចារណាជ្រៅៗ ។ល។ លោកបានជួបជាមួយ លោកគ្រូធំៗខាងព្រហ្មញ្ញសាសនា លោកពន្យល់របៀបជាសំណួរ-ចម្លើយ ។ល។ កាលជំនាន់នោះ ពួកគេមួយចំនួនធំ បានយល់ ជឿ គោរពព្រះអង្គ និងដើរតាមមាគ៌ាព្រះអង្គ។

ប្រសិនបើ ព្រះពុទ្ធលោកបានមកកើតនិងរស់នៅសម័យ ស.វ. ទី២១ នេះ លោកប្រហែលជានឹងការពន្យល់ថ្មីៗបន្ថែមទៀត ទៅតាមរបៀបវិទ្យាសាស្ត្រទំនើប។ តាមការសង្កេត ចិត្តរបស់មនុស្សតាំងពី ២៥០០ឆ្នាំមុន និង២៥០០ឆ្នាំក្រោយ ក៏ចិត្តមនុស្សនៅតែដដែល ដូចជា លោភៈ មោហៈ ទោសៈ ។ល។ ចំណែកឯតទៅមុខច្រើនពាន់ម៉ឺនឆ្នាំទៀត ក៏ចិត្តមនុស្សនៅតែដូច្នេះដដែល។

# ជំពូកទី១៣
# អវសានកាលនៃជីវិតក្នុងប្រព័ន្ធព្រះអាទិត្យ

## ១- ការទស្សន៍ទាយអនាគតនៃផែនដី

បច្ចុប្បន្ន មនុស្សលោកដែលកំពុងរស់នៅលើផែនដីនេះ ហាក់មិនសូវចាប់អារម្មណ៍ អំពីអនាគតនៃផែនដីរបស់ខ្លួនទេ។ គេគិតតែពីបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ ប្រទេសនីមួយៗ គេគិតតែពីបញ្ហាក្នុងប្រទេស និងបញ្ហាអន្តរជាតិពាក់ព័ន្ធនឹងប្រទេសរៀងៗខ្លួន។ នេះដោយសារថា វាគឺជារយៈពេលដ៏វែងឆ្ងាយពេក ហួសពីកម្មវិធីសម្រាប់គិត សម្រាប់ធ្វើផែនការ។ មានតែសាសនាទេ ដែលបានយកបញ្ហាទាំងនេះមកគិត និងបានប្រមើលពីបញ្ហាអនាគតនៃផែនដីនេះ ក៏ប៉ុន្តែមេសាសនាធំៗកាលពីជំនាន់នោះ មិនអាចនឹងគិតដល់ ដោយសារថា វិទ្យាសាស្ត្រ បច្ចេកវិទ្យាកាលនោះ មិនទាន់មានការរីកចម្រើននៅឡើយ ហើយការនិយាយរបស់ពួកលោកក៏គ្មានសក្ខីកម្មជាមូលដ្ឋានវិទ្យាសាស្ត្រ មកបង្ហាញដែរ។ ដូច្នេះ ទោះបីជាពួកអរិយបុគ្គល លោកមានប្រាជ្ញាខ្លាំងយ៉ាងណាក៏ដោយ ក៏ពួកលោកមិនមានមូលដ្ឋានវិទ្យាសាស្ត្រច្បាស់លាស់ ដើម្បីគិតគូរពិចារណា ដែលធ្វើឱ្យលោកទស្សន៍ទាយអំពីអនាគតនៃពិភពលោក ទៅតាមការយល់ឃើញផ្ទាល់ខ្លួនប៉ុណ្ណោះ។ ដូចជា នៅក្នុងព្រះពុទ្ធសាសនាជាដើម គេបានទស្សន៍ទាយថា នៅក្រោយសម័យព្រះសិអារមេត្រី នឹងមានភ្លើងឆេះកល្ប ធាតុអាកាសក្ដៅខ្លាំងណាស់ សុទ្ធតែភ្លើង ធ្វើឱ្យហួតទឹកទន្លេ បឹងបួរ សមុទ្រ ធ្វើឱ្យមនុស្សលោក សត្វ ស្លាប់អស់ រលាយព្រៃឈើ ។ល។ ទាល់តែ រាប់សែនកប្ប រាប់អសង្ខេយ្យ ទើបមានផែនដីថ្មីកើត

ឡើង ជីវិតថ្មីកើតវិញមានឡើងម្តងទៀត។ ខាងគ្រិស្តសាសនាក៏មានការទស្សន៍ទាយអំពីការរលាយនៃភពផែនដីដែរ ។

យើងត្រឡប់មកមើលអនាគតនៃផែនដីយើង តាមបែបតារាវិទ្យា និងវិទ្យាសាស្ត្រវិញ តើដំណើរការនេះមានទៅយ៉ាងដូចម្តេច។



## ២- អនាគតនៃផែនដីនិងព្រះអាទិត្យ

ព្រះអាទិត្យជាប្រភពនៃកម្តៅ និងពន្លឺ ។ នេះជាកត្តាសំខាន់ណាស់ និងជាប្រភពនៃជីវិតនៅលើផែនដីយើង។ ព្រះអាទិត្យជាអ្នកជួយបង្កើតជីវិត និងក៏ជាអ្នកសម្លាប់ជីវិតបន្តិចម្តងៗទៅវិញដែរ។

កម្តៅនិងពន្លឺនៃព្រះអាទិត្យ បានមកពីប្រតិកម្ម នុយក្លេអ៊ែរ (nulear fusion) នៃការរួមបញ្ចូលគ្នា អាតូម អ៊ីដ្រូសែន (hydrogen) ឱ្យក្លាយទៅជា អាតូម អេល្យូម (helium) ។ ក្នុង១វិនាទី ប្រើអស់ ៦០០លាន តោន អ៊ីដ្រូសែន ។ ពិតមែនតែ ព្រះអាទិត្យមានទំហំនិងម៉ាស់យ៉ាងធំសម្បើម គឺ

ជាង ៩៩% នៃម៉ាស់សរុប នៃប្រព័ន្ធព្រះអាទិត្យ យើងទាំងមូល ។ មកដល់សព្វថ្ងៃនេះ ចំហេះនេះមានរយៈពេល ៩៥០០លាន ឆ្នាំមកហើយ ប៉ុន្តែក៏មិនមែនបានន័យថា អ៊ីដ្រូសែន នៅក្នុងព្រះអាទិត្យមិនចេះអស់នោះទេ។ នៅថ្ងៃណាមួយ បរិមាណអ៊ីដ្រូសែន នៅក្នុងព្រះអាទិត្យត្រូវអស់ ពេលនោះប្រតិកម្មនុយក្លេអ៊ែរក៏លែងមាន នៅពេលនោះហើយ គឺជាតំណាក់កាលចុងក្រោយនៃជីវិតនៃព្រះអាទិត្យរបស់យើង។ តាមរយៈការសិក្សាលើផ្កាយផ្សេងទៀត ដែលមានទំហំប្រហាក់ប្រហែលគ្នា អ្នកវិទ្យាសាស្រ្ត បានឱ្យដឹងថា ព្រះអាទិត្យយើងនេះនឹងមិនចប់ជីវិតទៅនៅក្នុងភាពស្ងាតស្ងៀមទេ។ ផ្ទុយទៅវិញ នៅតំណាក់កាលចុងក្រោយនៃជីវិត ព្រះអាទិត្យ ពេលប្រើអស់អ៊ីដ្រូសែននៅក្នុងស្នូល ព្រះអាទិត្យនឹងមានទំហំរីកកាន់តែធំឡើងៗ រហូតក្លាយទៅជាផ្កាយដ៏ធំមួយ គេហៅថាផ្កាយយក្សក្រហម (Red Giant)។



នៅក្នុងតំណាក់កាល (Red Giant) នេះ ព្រះអាទិត្យនឹងមាឌរីកធំឡើងៗ រហូតអាចលេបត្របាក់ភពពុធ និងភពព្រះសុក្រ។ ពេលនោះមុខកាត់របស់ព្រះអាទិត្យ នឹងត្រូវលាតសន្ធឹងកាន់តែធំ ធំរហូតដល់តារាវិថីនៃភពផែនដីរបស់យើង។ រហូតមកដល់បច្ចុប្បន្ននេះ អ្នកវិទ្យាសាស្ត្រនៅមិនទាន់ មានការឯកភាពគ្នានៅឡើយទេ ថាតើ ភពផែនដីរបស់យើងនឹងត្រូវព្រះអាទិត្យ លេបត្របាក់យក ដូចជា ភពពុធនិងភពសុក្រដែរ ឬយ៉ាងណាទេ។ ប៉ុន្តែ ទោះបីជាមិនត្រូវព្រះអាទិត្យ លេបត្របាក់យកទាំងមូលក៏ដោយ ក៏ភពផែនដី និងជីវិត លើភពផែនដីយើង នឹងមិនអាចទ្រាំទ្រនឹងកម្ដៅរបស់ព្រះអាទិត្យដ៏ធំមហិមា ជាផ្កាយយក្សក្រហមនេះបានឡើយ។ ទោះជាយ៉ាងណា អ្នកវិទ្យាសាស្ត្រ បានព្យាករថា ជីវិតព្រះអាទិត្យយើងនេះ មិនមែនចប់នៅពេលឆាប់ៗខាងមុខនេះទេ ដោយគេដឹងថា ផ្កាយដែលមានម៉ាស់ប្រហាក់ប្រហែលទៅនឹងម៉ាស់របស់ព្រះអាទិត្យយើង អាចមានសារធាតុគ្រប់គ្រាន់ឱ្យមានប្រតិកម្មនៅក្នុងស្នូលក្នុងរយៈពេលដល់ទៅ៩,០០០លានឆ្នាំ ឬ១០,០០០លានឆ្នាំ ឯណោះ។ ហើយដោយសារព្រះអាទិត្យយើង មានអាយុមកដល់ពេលនេះ បាន ៤,៥០០លានឆ្នាំ ដូច្នេះ គេគណនាព្យាករថា ប្រមាណ ៥,០០០លានឆ្នាំទៀត ទើបព្រះអាទិត្យប្រើអស់អ៊ីដ្រូសែន ទើបក្លាយទៅជា ផ្កាយយក្សក្រហម (Red Giant)។

ដំណើរការផ្ទែកតារាសាស្ត្របន្តទៅមុខទៀត មិនទាន់បញ្ឈប់ត្រឹមតែផ្កាយយក្សក្រហម (Red Giant) ប៉ុណ្ណោះទេ។



នៅក្រោយដំណាក់កាលផ្កាយយក្សក្រហមនេះ ផ្កាយខ្លះអាចផ្ទុះទៅជា ស៊ុបភើ ណូវ៉ា (Super Nova) ឬក៏ក្លាយទៅជា ប្រហោងខ្មៅ (Black Hole) ប៉ុន្តែករណីទាំងនេះ វាអាចកើតមានឡើងតែចំពោះផ្កាយធំៗតែប៉ុណ្ណោះ ដែលមានម៉ាស់ធំជាងព្រះអាទិត្យយើងចាប់ពី ១០ដងឡើងទៅ។ ចំណែកព្រះអាទិត្យយើង មិនមានម៉ាស់គ្រប់គ្រាន់ ដើម្បីបង្កើតជាស៊ូភើណូវ៉ា បានទេ ហើយក៏រឹតតែមិនអាច ក្លាយទៅជា ប្រហោងខ្មៅ បានដែរ។ ក្នុងរយៈពេលប្រហែល២០០លានឆ្នាំ ដែលព្រះអាទិត្យបានក្លាយជាផ្កាយយក្សក្រហម ស្រទាប់ខាងក្រៅបង្អស់នឹងត្រូវភាយចេញ ជា ណេប៊ុយឡា (Nebula)[33] ហើយបន្សល់ទុកតែស្នូលប៉ែកខាងក្នុងតែប៉ុណ្ណោះ។ ស្នូលដែលនៅសល់ចុងក្រោយនេះ វាមានម៉ាស់ប្រហែលជាពាក់

[33] Nebula: ពពកនៃធូលីនិងឧស្ម័នយ៉ាងធំដែលស្ថិតនៅចន្លោះផ្កាយនានា និងជាកន្លែងផ្តល់កំណើតជាផ្កាយ

កណ្តាលម៉ាស់របស់ព្រះអាទិត្យបច្ចុប្បន្ន ប៉ុន្តែទំហំរបស់វាវិញ គឺប្រហាក់ប្រហែលនឹងទំហំផែនដីរបស់យើងតែប៉ុណ្ណោះ។ នៅក្នុងដំណាក់កាលនេះ ព្រះអាទិត្យរបស់យើង ដែលពីមុនជាផ្កាយយក្សក្រហម នឹងត្រូវប្រែក្លាយទៅជា ប្រភេទផ្កាយមួយទៀត ដែលគេឱ្យឈ្មោះថាជាកូនផ្កាយ "ស" (white dwaf) ។



ដំណើរនេះប្រព្រឹត្តទៅយ៉ាងយឺតៗយូរឆ្នាំ ដែលភ្នែកមនុស្សធម្មតាមិនអាចមើលឬសង្កេតឃើញក្នុងរយៈពេលខ្លីបានទេ ទាល់តែប្រើឧបករណ៍និងការគណនាច្បាស់លាស់។

និយាយសរុបមក ព្រះអាទិត្យរបស់យើង ដែលគេបានចាត់បញ្ចូលថាជា កូនផ្កាយលឿង ឬ (Yellow Dwarf) នៅពេលដែលវាប្រើអស់សារធាតុ អ៊ីដ្រូសែន រយៈពេលប្រមាណជា៥ពាន់លានឆ្នាំខាងមុខ វានឹងក្លាយជា ផ្កាយយក្សក្រហម មុននឹងត្រូវបញ្ចប់ជីវិតរបស់ខ្លួន ជាកូនផ្កាយ "ស" ។ កូនផ្កាយ "ស" នឹងត្រូវថមថយពន្លឺបន្តិចម្តងៗ នៅក្នុងដំណើរការយឺតៗ

បំផុត ដែលអាចបាត់បង់ទៅក្នុងរាប់ពាន់លានឆ្នាំបន្ទាប់ទៅទៀត ទើបវាត្រូវអស់ពន្លឺទាំងស្រុង ហើយក្លាយទៅជាដុំស្វែរឧស្ម័នមួយ មិនបញ្ចេញពន្លឺអ្វីទាំងអស់ ហើយគេឱ្យឈ្មោះថា កូនផ្កាយខ្មៅ (Black Dwarf)។ នេះជាចុងបញ្ចប់នៃជីវិតរបស់ព្រះអាទិត្យយើង[34] ។

### ៣- ប្រហោងខ្មៅ (Black hole)

ប្រហោងខ្មៅ គឺជាកន្លែងឬវត្ថុមួយដែលមានទំនាញខ្លាំង គ្មានអ្វីអាចចាកចេញពីវាបានសូម្បីតែពន្លឺ ហើយវាកើតពីសំណល់របស់ផ្កាយធំៗដែលស្លាប់ទៅដោយសារបន្ទុះស៊ុបពៃណូវ៉ា ។



ប្រហោងខ្មៅជាវត្ថុដែលមានទំនាញខ្លាំងគ្មានអ្វីអាចចាកចេញពីវាបាន សូម្បីតែពន្លឺ។ វាកើតមាននៅពេលផ្កាយដែលមានម៉ាសធំជាងព្រះ

[34] អត្ថបទ Cambo Space and Science Education

អាទិត្យ៨០ដងស្លាប់ ហើយបន្សល់ទុកនៅម៉ាសដែលមានទំហំធំជាងព្រះអាទិត្យ៥ដង។ ទំនាញដ៏ខ្លាំងរបស់ម៉ាសនេះទាញឧស្ម័នឱ្យហាប់ណែនទៅៗ ហើយពន្លឺមិនអាចចាកចេញពីវាបាន។ សំណល់របស់ផ្កាយនេះក្លាយទៅជាប្រហោងខ្មៅ។

គេរាប់ឃើញមាន ប្រហោងខ្មៅ ប្រហែលជា១០០លាន នៅក្នុងហ្គាឡាក់ស៊ី យើង (Milky Way)។

ទាក់ទងទៅនឹងប្រហោងខ្មៅ តាមរយៈយានសង្កេតការណ៍ចាន់ដ្រា (Chandra X- ray Observatory) អ្នកវិទ្យាសាស្ត្របានរកឃើញថា ប្រហោងខ្មៅជាច្រើន មានទំហំប៉ុនផ្កាយ។ គេក៏បានរកឃើញប្រហោងខ្មៅធំៗមានម៉ាស់ធំជាងព្រះអាទិត្យពីរាប់លានដងទៅរាប់ពាន់លានដងផងដែរ ។



ផ្កាយណឺត្រុង (neutron star) គឺជាការកើតឡើងពីរូបធាតុដែលនៅសេសសល់បន្ទាប់ពីផ្កាយមានម៉ាសធំៗផ្ទុះ(ផ្កាយយក្ស)។ ផ្កាយណឺត្រុងមានម៉ាសតូច និងហាប់ណែនជាង ផ្កាយក្រិសពណ៌ស។ ផ្កាយណឺត្រុងមានម៉ាសច្រើនជាងព្រះអាទិត្យយើង៣ដង ប៉ុន្តែវាមានអង្កត់ផ្ចិតត្រឹមតែ ២៥Km ប៉ុណ្ណោះ។

ស៊ុបពែណូវ៉ា (supernova) គឺជាការផ្ទុះ (explosion) នៃផ្កាយ ដោយថាមពលនិងពន្លឺយ៉ាងខ្លាំង មានប្រហែលតែប៉ុន្មានខែប៉ុណ្ណោះ គឺជារយៈពេលដ៏ខ្លី បើប្រៀបធៀបទៅនឹងអាយុនៃផ្កាយ។ នេះជាដំណាក់កាលចុងក្រោយនៃជីវិតរបស់ផ្កាយធំៗ ឬក៏នៅពេលដែលកូនភពពណ៌ស (white dwarf) អស់សារធាតុឆេះ (nuclear fusion)។ ក្រោយពេលផ្ទុះ ផ្កាយនោះក៏ក្លាយទៅជា ផ្កាយណឺត្រុង ឬក៏ទៅជា ប្រហោងខ្មៅ ឬក៏ត្រូវរលាយអស់រលីងតែម្តង។ នៅក្នុង ហ្គាឡាក់ស៊ីមីលគីវេ ជាមធ្យម មាន ស៊ុបពែណូវ៉ាកើតឡើង ៣ដង ក្នុងពេលមួយសតវត្ស។

កូនភពពណ៌ស ឬផ្កាយក្រិសពណ៌ស មានទំហំប្រហែលប៉ុនផែនដី ប៉ុន្តែវាមានម៉ាសច្រើនដូចព្រះអាទិត្យ។ ផ្កាយទាំងនោះពុំមានឥន្ធនៈទេ ប៉ុន្តែវាឆេះព្រៀងៗដោយសារថាមពលដែលនៅសេសសល់។ ផ្កាយក្រិសពណ៌សតូចៗ គឺជាផ្កាយដែលបញ្ចេញពន្លឺពណ៌សហើយត្រជាក់។

## ៤- អនាគតនៃភព

តទៅនេះជាការទស្សន៍ទាយរបស់អ្នកវិទ្យាសាស្ត្រ ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើបអំពីដំណើរប្រវត្តិនាពេលអនាគត របស់ផែនដីយើង ។ នៅ១ពាន់លានឆ្នាំទៅមុខ ព្រះអាទិត្យនឹងមានកម្តៅកាន់តែក្តៅ

ខ្លាំងឡើងៗ។ ពេលនោះ ដងទន្លេ បឹង សមុទ្រ នៃភពផែនដី នឹងរីងហួតអស់។ ដូច្នេះ គ្មានជីវិតណាអាចរស់នៅបានទេ។ ការវិវត្តនៃព្រះអាទិត្យមានឥទ្ធិពលខ្លាំង ដល់ភពនានានិងព្រះចន្ទនានា នៅក្នុងប្រព័ន្ធព្រះអាទិត្យ។ ទំហំព្រះអាទិត្យ កាន់តែរីកធំទៅៗ ទៅតាមពេលវេលា។ ទំហំព្រះអាទិត្យបច្ចុប្បន្ន ស្មើនឹងផែនដី ១,៣លានដង មានបន្ទាត់ផ្ចិត ១,៤លានគីឡូម៉ែត្រ។ ពេលដែលព្រះអាទិត្យ ប្រែក្លាយទៅជាផ្កាយក្រហម បន្ទាត់ផ្ចិតអាចរីកដល់ទៅ ៣៣៣,០០០,០០០គីឡូម៉ែត្រ ។ ពេលនោះ ទំហំព្រះអាទិត្យ លាតសន្ធឹងដល់ គោចរ (orbit) ឬគន្លងវិលនៃផែនដី ។ ពេលនោះគឺព្រះអាទិត្យ នឹងលេបត្របាក់យកភពពុធ (Mercury) និងភពសុក្រ (Venus) ដែលនៅជិតព្រះអាទិត្យជាងគេ ហើយបន្ទាប់មកក៏អាចលេបយកផែនដីយើងផងដែរ។ ភពពុធ (Mercury) មានចម្ងាយពីព្រះអាទិត្យ ៤៦-៧០លានគីឡូម៉ែត្រ និងបច្ចុប្បន្នមានសីតុណ្ហភាព ពេលយប់និងពេលថ្ងៃ គឺពី -180 °C ទៅ +167 °C ។



ប្រសិនបើ ព្រះអាទិត្យមិនរីកមកដល់ផែនដីទេនោះ ក៏ពេលនោះផែនដីនឹងមានសីតុណ្ហភាពយ៉ាងក្ដៅបំផុត ។

មានការទស្សន៍ទាយថា នៅ ១០,០០០ ឆ្នាំទៅមុខទៀត គ្រោះមហន្តរាយនៃការកើនឡើងកម្ដៅផែនដី នេះធ្វើឱ្យទឹកកកនៅតំបន់ប៉ូលរលាយកាន់តែខ្លាំង ហើយនៅរយៈពេលច្រើនសតវត្សទៅមុខទៀត ទឹកកកនៅតំបន់ប៉ូលនឹងរលាយអស់ ពេលនោះទឹកសមុទ្រនឹងកើនឡើងពី ៣ ទៅ៩ម៉ែត្រនិងអាចធ្វើឱ្យភាវៈរស់នៅលើផែនដីជាច្រើនផុតពូជ។

នៅ ៦០០ លានឆ្នាំខាងមុខទៀត ពន្លឺដ៏ខ្លាំងក្លានៃព្រះអាទិត្យនឹងជះចូលលើផែនដីនឹងការពារមិនឱ្យកាបូណាស៊ីលីកាត ជ្រៀតចូលមកហើយកត្តានេះបាននាំឱ្យឧស្ម័នកាបូនិកជាប់នៅពេញដីទាំងអស់នៅលើផែនដី ហើយវានឹងងាយឱ្យមានការរំហួតទឹកលឿនទៀតផង នោះដីនៅលើផែនដី នឹងខ្លាចជាដីដែលរឹងស្ងួតហួតហែងលែងមានជីវជាតិ ហើយបន្ទុះភ្នំភ្លើងក៏លែងមានតទៅទៀត ជាហេតុធ្វើឱ្យឧស្ម័នកាបូនិកមានការថយចុះបន្តិចម្ដងៗ ដែលអាចធ្វើឱ្យរុក្ខជាតិ ៩៩% ងាប់ដោយសារគ្មានសមត្ថភាពធ្វើរស្មីសំយោគបាន ។

អនាគត ៨០០ លានឆ្នាំខាងមុខទៀត ពេលណាឧស្ម័នកាបូនិចថយចុះនោះ គ្រប់រុក្ខជាតិលែងអាចធ្វើរស្មីសំយោគបាន ជាហេតុធ្វើឱ្យផែនដីលែងមានឧស្ម័នអុកស៊ីសែនតទៅមុខទៀត ហើយស្រទាប់អូសូនក៏បាត់បង់ដូចគ្នា។ ពេលនោះ មានពពួកសត្វមួយចំនួននៅបាតសមុទ្រអាចនឹងមានជីវិតរស់រាន តែក៏មិនអាចរស់បានយូរផងដែរ ព្រោះមិនមានចំណីនិងអុកស៊ីសែន ទីបញ្ចប់ជីវិតនៅលើផែនដីនឹងត្រូវបាតបង់ស្ទើរតែទាំងអស់។




១ពាន់លាន ឆ្នាំទៅមុខទៀត ពន្លឺនឹងកម្តៅនៃព្រះអាទិត្យនឹងកើនឡើង១០% ដោយអាចធ្វើឱ្យផែនដីមានសីតុណ្ហភាពជាមធ្យម +50 °C ហើយទឹកនៅក្នុងមហាសមុទ្រអាចរំហួតលឿន តែនៅតំបន់ប៉ូលអាចនៅសល់ទឹកមួយចំនួនសម្រាប់ភាវរស់ដែលនៅសេសសល់។

ផែនដីនៅ ៣ពាន់លាន ឆ្នាំទៅមុខទៀត សីតុណ្ហភាពនៅលើផែនដីអាចកើនឡើង +150 °C ដែលសីតុណ្ហភាពប៉ុណ្ណេះធ្វើឱ្យភាវៈទាំងអស់នៅលើផែនដីមិនអាចមានជីវិតរស់រានតទៅទៀត ហើយនៅជិត ៥ពាន់លានឆ្នាំទៅមុខទៀត សីតុណ្ហភាពលើផែនដីនឹងកាន់តែកើនឡើងរហូតដល់ +1300 °C ដែលកម្តៅនេះអាចគ្រប់គ្រាន់នឹងធ្វើឱ្យថ្មរលាយបាន។

នៅ ៥ ពាន់លានឆ្នាំទៅមុខទៀត អ៊ីដ្រូសែន (H2) នៅក្នុងស្នូលរបស់ព្រះអាទិត្យនឹងដុតកាន់តែក្តៅខ្លាំងឡើងៗ រហូតដល់ព្រះអាទិត្យមានរូបរាង្គដូចជាភពយក្សក្រហមដ៏សន្ធោសន្ធៅ។

នៅ ៧ ពាន់លានឆ្នាំទៅមុខទៀត ព្រះអាទិត្យមានមាឌធំទៅៗកើនឡើងដល់ទៅ២៥៦ដង។ សម្រាប់ភពអង្គារ ក៏ក្លាយជាភពមានកម្ដៅខ្លាំងដោយសារទំហំព្រះអាទិត្យកើនធំជាងមុនរាប់រយដង។ ភពផែនដីនឹងភពអង្គារ នឹងត្រូវបានបំផ្លាញដោយសារការកើនឡើងកម្ដៅនៃព្រះអាទិត្យ ហើយសីតុណ្ហភាពនៃផែនដីនៅពេលនោះគឺមាន +២១០០ ℃ ដែលអាចធ្វើឱ្យសម្បកផែនដីមួយចំនួន ត្រូវរលេសចេញទៅលំហអាកាស តែភពសៅអាចនឹងក្លាយជាកន្លែងដល់ល្អសម្រាប់ភាវៈមានជីវិតរស់នៅ។




សម្រាប់ភពព្រហស្បតិ (Jupiter) វិញ ដែលមានព្រះចន្ទចំនួនប្រមាណ៧៩ អាចលែងត្រជាក់ដូចមុនហើយ ដូច្នេះអាចមានស្ថានភាពល្អ។ ព្រះចន្ទ យូរ៉ូប៉ា (Europa) ឬ ហ្គានីម៉ែដ (Ganymede) នៃភពព្រហស្បតិអាចរក្សាផ្ទៃទឹកបានខ្លះៗ ។ អាចមានបរិយាកាសព័ទ្ធជុំវិញនិងខ្យល់អុកស៊ីហ្សែន ។ ដោយឡែក ភពសាទូន (Saturn) គឺមានស្ថាន

ភាពល្អ ដែលពីមុនមានសីតុណ្ហភាព -179 អង្សាសេ ។ វាអាចនឹងមាន ទឹកនៅលើភព ទីតាន (Titan) ដែលជាព្រះចន្ទមួយនៃភពសាទូន ហើយ អាចមានសភាព ដូចផែនដី បច្ចុប្បន្ន។ ភពអ៊ុយរ៉ានុស (Uranus) និងព្រះ ចន្ទវា មនុស្សមិនអាចរស់នៅបានទេ ដោយសារវាតូច និងមានទំនាញ ខ្សោយ ។ ភពណិបទូន (Neptune) មិនអាចទេ ព្រោះ អាចប៉ះនឹងកូនភព ព្លុយតុង។ កូនភព ព្លុយតុង (Pluto) នឹងមាន អាហ្សូតរាវ ដែលរលាយនៅ សីតុណ្ហភាព-210 °C ទឹកនៅតែកកដដែល ។ នៅ៣០០០លានឆ្នាំ ទៀត ជីវិតនៅតែអាចមាននៅក្នុងប្រព័ន្ធព្រះអាទិត្យ។ ជីវិតអាចនៅមានបន្តនៅ ក្នុងប្រព័ន្ធព្រះអាទិត្យតទៅទៀត ដល់៨០០០លានឆ្នាំ រហូតដល់ព្រះ អាទិត្យផ្ទុះបែកសម្បកខាងក្រៅ [35] ។

៨០០០លានឆ្នាំទៅមុខទៀត អំឡុងពេលនោះព្រះអាទិត្យក៏បាន ក្លាយទៅជាផ្កាយតូចពណ៌ស កម្តៅតិចវិញ ហើយបើនៅពេលនោះផែន ដីនៅមិនទាន់រលាយអស់ នោះសីតុណ្ហភាពនៅលើផែនដី នឹងកាត់ បន្ថយបន្តិចម្តងៗ នេះមិនត្រឹមតែផែនដីមួយទេ គឺសម្រាប់គ្រប់ភពទាំង អស់នៅក្នុងប្រព័ន្ធព្រះអាទិត្យ ព្រោះព្រះអាទិត្យកាត់បន្ថយថាមពលជាង ពីមុន។

នៅ ៩ ៥០០ លានឆ្នាំទៅមុខទៀត ព្រះអាទិត្យនឹងប្រែពណ៌ទៅជា ពណ៌ខ្មៅ ព្រោះតែពេលដែលវាមានពន្លឺពណ៌សវាមិនអាចផ្តល់ពន្លឺនឹង កម្តៅគ្រប់គ្រាន់ ជាហេតុធ្វើឱ្យព្រះអាទិត្យអស់ថាមពលនឹងក្លាយជាផ្កាយ ងាប់ស្ពូកស្ពឹង។

---

[35] ដកស្រង់ពីអត្ថបទ Cambo Space and Science Education

ពេលនោះ ភពទីតាន នឹងអស់មានកម្តៅ ហើយក៏ចុះត្រជាក់ ។ ព្រះចន្ទ យូរ៉ូប៉ា នឹងកកសមុទ្រឡើងវិញ ។ នេះជា អវសានន្តនៃជីវិតនៅភព ទីតាន ។ ភពនៅក្នុងប្រព័ន្ធព្រះអាទិត្យ នឹងគ្មានប្រភពថាមពល ហើយជីវិតគឺត្រូវចប់ជាអវសាន្ត ហើយភពនិងព្រះចន្ទនានា នឹងអណ្តែតត្រសែតគ្មានគោលដៅ នៅក្នុងលំហនៃទីងងឹត ។

ទោះបីជា ជីវិតអាចទប់ទល់នឹងភាពស្ងួតនិងត្រជាក់ យ៉ាងណាក៏ដោយ ក៏៥០០០លានឆ្នាំទៀត មានការបុកគ្នារវាង ហ្គាឡាក់ស៊ី មីគីវេ (Milky Way Galaxy) និង ហ្គាឡាក់ស៊ី អង់ដ្រូមេដា (Andromeda Galaxy) ហើយបង្កើតបានជា ហ្គាឡាក់ស៊ី ថ្មីមួយទៀត គឺមីដ្រូមេដា។ ប៉ុន្តែ ភពទាំងអស់នៅប្រព័ន្ធព្រះអាទិត្យ មិនមានប៉ះពាល់អ្វីទេនៃការរួមបញ្ចូលគ្នានេះ ។

ចក្រក្រវាល (Galaxy) យើង ទើបកើតបានអាយុ ១៣,៨០០លានឆ្នាំ។ នៅ ១១,៦ ពាន់លានឆ្នាំទៅមុខទៀត នៅទីបញ្ចប់ នៅក្នុងលំហអាកាសទាំងអស់ដូចជាហ្គាឡាក់ស៊ី ផ្កាយនឹងភពត្រូវដាច់ចេញពីគ្នា នៅពេលនោះលំហអាកាសនឹងមានភាពធំទូលាយ ហើយគ្រប់ផ្កាយទាំងអស់នឹងត្រូវរលាយទៅជាអាតូម ដែលអាតូមនោះនឹងអាចរលាយខ្ទេចទៅជាធូលីបានដែរ។

នៅរយៈពេល ១០០ពាន់លានឆ្នាំទៅមុខទៀត ភាពធំទូលាយនៃលំហអាកាសនេះអាចធ្វើឱ្យគ្រប់ហ្គាឡាក់ស៊ីទាំងអស់ត្រូវដាច់ចេញពីផ្លូវមីគីវ៉េ (Milky Way) ហើយពួកវាក៏បាត់ខ្លួនបាត់ពីលំហអាកាសជារៀងរហូត ដោយលំហអាកាសនៅសល់តែកំហាប់វិទ្យុសកម្មដ៏ក្រាស់ដែលមានសីតុណ្ហាភាព - ២៧០ ទៅ -២៧២ °C ។

១.០០០ ពាន់លានឆ្នាំទៅមុខទៀត នៅវេលានេះហើយជាពេលដែលបញ្ចប់នៃសកលលោកទាំងមូល ដោយសកលលោកក្នុងលំហអាកាសត្រូវបានបែកខ្ទេចខ្ទី រហូតដល់កម្ទេចកម្ទីទាំងនោះបានរួមបញ្ចូលគ្នាកើតបានជាផ្កាយផ្សេងៗ ចំណែកឯកំហាប់នៃវិទ្យុសកម្មនៅលើលំហមេឃនោះក៏កើនឡើងសីតុណ្ហភាពដល់ទៅ ១០.០០០°C រហូតធ្វើឱ្យផ្កាយដែលទើបនឹងកើត ក៏ត្រូវផ្ទុះ បន្ទាប់មកកម្ទេចកម្ទីទាំងអស់ នឹងត្រូវបានចូលទៅក្នុងរន្ធខ្មៅ (Black Hole) នៅក្នុងលំហអាកាស ដែលជាចំណុចមួយនៅការកកើតនៅសកលលោកថ្មីម្តងទៀត។

*នេះជាទីអវសាន្តនៃចក្រវាលក្នុងវិញ្ញាណមនុស្ស*
*ប៉ុន្តែពេលវេលាចេះតែបន្តទៅមុខដោយមិនខ្វល់ពីវត្តមាន*
*ឬការគិតរបស់មនុស្សទេ*

# សេចក្ដីសន្និដ្ឋាន

សៀវភៅនេះបង្ហាញទស្សនវិទ្យានិងទស្សនទានជាច្រើន បង្ហាញពីដំណើរវិវត្តន៍ មនុស្ស សង្គម សេដ្ឋកិច្ច និងប្រវត្តិសាស្ត្រនានាកន្លងទៅកម្រិតជាតិនិងអន្តរជាតិ។ ចាប់តាំងពីទសវត្សរ៍ទី២០ រហូតដល់ក្រោយពេលសង្គ្រាមលោកលើកទី២ យើងពិនិត្យឃើញថា ស្ថានភាពសេដ្ឋកិច្ចមានការប្រែប្រួលជាវិជ្ជមាន។ បែបផែនសេដ្ឋកិច្ចកាលនោះ បានដំណើរការឡើងតាមលក្ខណៈមូលធននិយម។

កម្ពុជាជាប្រជាជាតិមួយមានប្រវត្តិសាស្ត្រយូរលង់ណាស់មក ហើយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ កម្ពុជាធ្លាប់ជាអាណាចក្រដែលមានទឹកដីធំទូលំទូលាយ អារ្យធម៌ឧត្តុង្គឧត្តម ថ្កុំថ្កើងរុងរឿង និងល្បីល្បាញចាប់ពីសតវត្សរ៍ទី១នៃគ្រិស្តសករាជមក កម្ពុជាបានឆ្លងកាត់នូវដំណាក់កាលសំខាន់ៗជាច្រើននៃប្រវត្តិសាស្ត្រ ជាពិសេសនាសម័យហ្វូណន ដែលជាសក្ខីកម្មបញ្ជាក់ឱ្យឃើញថា កម្ពុជាគឺជាប្រទេសដំបូងគេបង្អស់ក្នុងតំបន់នេះ។

ការសង្កេតអំពីសង្គមមនុស្សនិងសេដ្ឋកិច្ច ក្នុងសៀវភៅដ៏តូចនេះ អាចជាគំនិតពិចារណាបែបទស្សនវិទ្យាសេដ្ឋកិច្ចមួយសម្រាប់តម្រង់ទិសនៃការអភិវឌ្ឍ ជំរុញកំណើននិងបរិយាបន្នក្នុងសង្គម ហើយជាក៏កញ្ចក់ឆ្លុះបញ្ចាំងបង្ហាញនូវកាលានុវត្តភាព បញ្ហាប្រឈម និងការបង្ហាញផ្លូវសម្រាប់អនាគតកម្ពុជា។ ការស្រាវជ្រាវធ្វើឱ្យយើងបានដឹងពីព្រឹត្តិការណ៍

ជាច្រើនជាមេរៀនសម្រាប់កម្ពុជា បានជួយដល់ការយល់ដឹងកាន់តែទូលំទូលាយផ្នែកសេដ្ឋកិច្ចជាតិនាអតីតកាល បច្ចុប្បន្ន និងអនាគត។

ឆ្លងកាត់មហន្តរាយ សង្គ្រាម ការបែកបាក់បំផ្លិចបំផ្លាញ អស់រយៈពេលជាង៥០០ឆ្នាំមក កម្ពុជាក៏បានទទួលការផ្សះផ្សាជាតិ សុខសន្តិភាព និងឯកភាពជាតិ។ ឆ្លងកាត់សោកនាដកម្មនេះ ប្រជាជនកម្ពុជាយល់ច្បាស់ថា សង្គ្រាមងាយបង្កើតតែលំបាកបញ្ចប់ និងសន្តិភាពពិបាករកតែងាយបាត់បង់។ ដូច្នេះ លទ្ធផលនៃការសិក្សាស្រាវជ្រាវ ការចងក្រងប្រវត្តិសាស្ត្រនិងទស្សនវិទ្យាសេដ្ឋកិច្ច ធ្វើឱ្យយើងចងចាំមេរៀនជូរចត់នៃប្រវត្តិសាស្ត្រកម្ពុជាកន្លងមក ជាពិសេសសម្រាប់ក្មេងៗជំនាន់ក្រោយ។ ក្មេងៗមួយចំនួន ពេលចាស់ៗនិយាយប្រាប់រឿងពីអតីតកាល ពួកគាត់ហាក់ដូចជាមិនជឿថាខ្មែរមានរបបប៉ុលពតប្រល័យពូជសាសន៍ដ៏សាហាវបែបនេះទេ។ ខ្មែរយើងជាភាគច្រើនប្រជាជនស្លូតត្រង់ ឆាប់ជឿ ឆាប់អាណិតគេ សណ្តោសមេត្តា ជួនកាលទៀតអាចឆាប់ភ្លេចអំពីព្រឹត្តិការណ៍មហន្តរាយដែលប្រទេសខ្លួនបានធ្លាប់ឆ្លងកាត់កន្លងមក។

បច្ចុប្បន្ននេះ តាំងពីសង្គ្រាមត្រជាក់បានចប់ទៅ ការប្រើអំណាចនៃប្រទេសធំៗមានកាន់តែសាហាវ ប្រទេសមានសេដ្ឋកិច្ចខ្លាំង ប្រទេសអភិវឌ្ឍន៍រំលោភលើប្រទេសតូចតាចទន់ខ្សោយជាងខ្លួន ដោយប្រើលេសគ្រប់បែបយ៉ាង ហើយគ្មានអង្គការអន្តរជាតិឬប្រទេសណាមួយយកចិត្តទុកដាក់ ជួយអន្តរាគមន៍ជាដុំកំភួនឱ្យច្បាស់លាស់ ដោយសារប្រទេសនិមួយៗគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន សីលធម៌សព្វថ្ងៃក្នុងពិភពលោកនេះមានតែនៅលើបបូរមាត់។

ជារួមសម្រាប់កម្ពុជា យើងទាំងអស់គ្នាត្រូវខិតខំថែរក្សាសន្តិភាព ពង្រឹងឯកភាពជាតិ កុំបែកបាក់ ដាស់តឿនខ្លួនឯង ឱ្យចេះរស់ ឱ្យចេះកសាង ឱ្យចេះថែរក្សាការពារ និងមានស្មារតីស្នេហាជាតិ គ្មានអ្នកណាជួយខ្មែរជាងខ្មែរខ្លួនឯងទេ សម្រាប់អនាគតយូរអង្វែងទៅមុខ។




ជីវិតនិងការងារ